**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# បណ្តឹងឧបាស្រ័យ

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ **សុខ ស៊ីវម៉ី**

**ចៅ ពិសិដ្ឋសត្យា**

ថ្នាក់បរិញ្ញាបត្រ ៖ **នីតិសាស្ត្រ**

ជំនាន់ទី ២១

សាស្ត្រាចារ្យណែនាំ៖

លោក **ញឹក ឧុត្តម**

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **សុខ ស៊ីវម៉ី** និង **ចៅ ពិសិដ្ឋសត្យា** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី២១ នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ឆ្នាំសិក្សា ២០១៧-២០២១។

**យើងខ្ញុំសូមធ្វើការថ្លែងអំណរគុណ និង សម្តែងនូវកតញ្ញូតាធម៌ ជូនចំពោះ ៖**

**លោកឪពុក សុខ ធំ** និង **អ្នកម្តាយ ហេង មុយសៀង** រួមទាំង **លោកឪពុក ចៅ ពិសិដ្ឋ** និង **អ្នកម្តាយ តាន់ ម៉ាន់ឌី** ជាទីគោរព និងស្រលាញ់របស់កូនៗទាំងទ្វេ ដែលលោកអ្នកមានគុណបានផ្តល់កំណើតដល់រូបកូនទាំងពីរ និងបានចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ប្រៀនប្រដៅ ថែមទាំងបានផ្តល់ក្តីស្រលាញ់ជូនចំពោះរូបកូនៗបានយ៉ាងល្អឥតខ្ចោះតាំងពីពេលចាប់កំណើត រហូតមកដល់ពេលបច្ចុប្បន្ននេះ។ លើសពីនេះទៅទៀត លោកអ្នកមានគុណបានខិតខំប្រឹងប្រែង និងលះបង់គ្រប់បែបយ៉ាងនូវកម្លាំងកាយកម្លាំងចិត្ត ជាពិសេសពេលវេលាជាច្រើនដើម្បីផ្គត់ផ្គង់ដល់ជីវភាពរស់នៅរបស់កូនៗ និងឧបត្ថម្ភគ្រប់សព្វបែបយ៉ាង ដូចជាសម្ភារៈសិក្សាបានគ្រប់គ្រាន់ដើម្បីឱ្យកូនៗបានសិក្សា និងទទួលបានចំណេះវិជ្ជាដោយមិនគិតពីភាពនឿយហត់អស់ទាំងបញ្ញា និងស្មារតី។ លោកអ្នកមានគុណបានផ្តល់នូវកម្លាំងចិត្តដល់កូនៗប្រកបដោយគុណធម៌ និងទឹកចិត្តស្រលាញ់ចង់ឱ្យកូនល្អតាំងពីកុមារភាពរហូតដល់រូបកូនៗបានបញ្ចប់ការសិក្សាកម្រិតថ្នាក់បរិញ្ញាបត្រ និងកំពុងអភិវឌ្ឍន៍ ក៏ដូចជាក្លាយខ្លួនទៅជាធនធានមនុស្សដ៏សំខាន់ដល់សង្គមជាតិ។

យើងខ្ញុំ សូមថ្លែងអំណរគុណដល់ **ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការង ថ្នាក់ដឹកនាំ និង លោក លោកស្រីសាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការបណ្តុះបណ្តាល ចែករំលែក ព្រមទាំងផ្តល់នូវការអប់រំ ចំណេះដឹង បទពិសោធន៍ និងដំបូន្មានដ៏ល្អជាច្រើន រួមទាំងការណែនាំបង្ហាត់បង្រៀនដល់រូបយើងខ្ញុំ យ៉ាងយកចិត្តទុកដាក់បំផុត ដើម្បីឱ្យរូបយើងខ្ញុំបានសិក្សារៀនសូត្រ ក្រេបយកចំណេះវិជ្ជា រហូតដល់បានបញ្ចប់ការសិក្សាប្រកបដោយភាពជោគជ័យ។

យើងខ្ញុំ សូមថ្លែងអំណរគុណដល់ **លោកសាស្ត្រាចារ្យ ញឹក ឧុឌ្ឍី** ដែលជាសាស្ត្រាចារ្យណែនាំរបស់រូបយើងខ្ញុំផ្ទាល់លើកិច្ចការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ ដោយលោកសាស្ត្រាចារ្យបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោក ដើម្បីដឹកនាំ ផ្តល់ការប្រឹក្សា និងកែតម្រូវនូវរាល់ចំណុចខ្វះខាតទៅលើការស្រាវជ្រាវ និងចងក្រងកិច្ចការសារណាបញ្ចប់ការសិក្សាមួយនេះ តាំងពីពេលចាប់ផ្តើមរហូតមកដល់ពេលដែលយើងខ្ញុំបានបញ្ចប់ និងសម្រេចបាននូវកិច្ចការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ ដោយទទួលបាននូវលទ្ធផលល្អប្រសើរ។

ជាចុងបញ្ចប់ ដើម្បីជាកិច្ចតបស្នង និងការដឹងគុណ យើងខ្ញុំមានតែសូមជូនពរដល់ លោកអ្នកមានគុណ ឯកឧត្ដម លោក លោកស្រី និង សាស្ត្រាចារ្យទាំងអស់ ឱ្យជួបតែសំណាងល្អគ្រប់ពេលវេលា ជួបប្រទះតែសេចក្ដីសុខ សេចក្ដីចំរើន ជោគជ័យគ្រប់ភារកិច្ច និងសូមប្រសិទ្ធិពរជ័យ សេរីមង្គល បវរមហាប្រសើរ សូមឱ្យជួបនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

✍📖✍

# អារម្ភកថា

ក្រោយពីទទួលបានការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រអស់រយៈពេលជិត៤ឆ្នាំ កន្លងមក នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំទាំងពីរទទួលបានចំណេះវិជ្ជាជាច្រើន និងទទួលបានចំណាត់ថ្នាក់ដែលបានតម្រូវឱ្យសរសេរសារណាដើម្បីបញ្ចប់ការសិក្សាផងដែរ។ ហេតុនេះនៅក្នុងចំណោមមុខវិជ្ជាដែលបានសិក្សានាពេលកន្លងមក យើងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងលើវិវាទក្នុងរឿងក្តីរដ្ឋប្បវេណីដែលទាក់ទងនឹងបណ្តឹងរបស់គូភាគី ដោយយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយដែលមានចំណងជើងថា "**បណ្តឹងឧបាស្រ័យ**" និងដើម្បីបំពេញកិច្ចក្នុងការសរសេរសៀវភៅសារណា ក៏ដូចជាដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រជំនាន់ទី២១នេះផងដែរ។ មូលហេតុដ៏ចម្បងមួយទៀតដែលយើងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទមួយនេះ ដើម្បីយកមករៀបរៀងជាសៀវភៅសារណាដើម្បីបញ្ចប់ការសិក្សានោះ គឺយើងខ្ញុំយល់ឃើញថានីតិវិធីលើបណ្តឹងឧបាស្រ័យក្នុងរឿងក្តីរដ្ឋប្បវេណីទៅតុលាការជាន់ខ្ពស់ គឺជានីតិវិធីមួយដ៏សំខាន់ ដែលអ្នកវិជ្ជាជីវៈ អ្នកសិក្សា និងប្រជាពលរដ្ឋគ្រប់រូបត្រូវតែយល់ដឹងឱ្យបានច្បាស់អំពីលំហូរនៃនីតិវិធីបណ្តឹងឧបាស្រ័យក្នុងរឿងក្តីរដ្ឋប្បវេណីទៅសាលាជម្រះក្តីជាន់ខ្ពស់ ពោលគឺសាលាឧទ្ធរណ៍តាមតំបន់ និងតុលាការកំពូល។

យើងខ្ញុំពិតជាមានសេចក្តីសោមនស្សដែលបានរៀបចំ និងធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ ដោយហេតុនេះយើងខ្ញុំបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង និងសកម្មផងដែរក្នុងការរៀបចំចងក្រងសៀវភៅសារណាបញ្ចប់ការសិក្សាមួយនេះយ៉ាងសម្រិតសម្រាំង ថែមទាំងប្រមូលផ្តុំដោយបានចងក្រងឡើងយកនូវខ្លឹមសារសំខាន់ៗ ដែលបានដកស្រង់ចេញពីឯកសារដែលពាក់ព័ន្ធជាច្រើន ដូចជាច្បាប់នៃព្រះរាជាណាចក្រកម្ពុជាដែលបានចូលជាធរមាន សៀវភៅ ជាពិសេសឯកសារមួយចំនួនទៀតដែលរៀបរៀងនៅក្នុងអ៊ីនធើណេត ឬ វេបសាយជាច្រើនទៀតដែលសុទ្ធសឹងតែជាឯកសារអាចយកមកធ្វើជាមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវបាន។

យើងខ្ញុំសង្ឃឹមថា ស្នាដៃសារណាបញ្ចប់ការសិក្សាមួយនេះនឹងអាចក្លាយជាឯកសារមួយដ៏សំខាន់ដែលជួយផ្តល់ចំណេះដឹងជាច្រើន ព្រមទាំងជំនួយស្មារតី និងជួយសម្រួលដល់អ្នកសិក្សាស្រាវជ្រាវ មិត្តអ្នកអាន និងនិស្សិតជំនាន់ក្រោយទាំងអស់ រួមទាំងប្រជាពលរដ្ឋគ្រប់រូប ដែលបានសិក្សាស្រាវជ្រាវលើប្រធានបទ ឬ បញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងលំហូរនីតិវិធីបណ្តឹងឧបាស្រ័យនៃរឿងក្តីរដ្ឋប្បវេណីទៅសាលាជម្រះក្តីជាន់ខ្ពស់។

យ៉ាងណាមិញ ទោះជាយើងខ្ញុំបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក៏ដោយ ក៏សៀវភៅសារណាមួយនេះគង់តែមាននូវចំណុចខ្វះខាត និងកំហុសមួយចំនួនពុំខានឡើយ ដែលជាកំហុសលើផ្នែកអក្ខរាវិរុទ្ធ ដោយអចេតនា។ ហេតុនេះហើយយើងខ្ញុំសូមមេត្តាខន្តីអភ័យទោសទុកជាមុននូវរាល់កំហុសខុសឆ្គងដែលកើតមានឡើងដោយអចេតនា ហើយយើងខ្ញុំមានសេចក្តីសោមនស្សរីករាយក្នុងការរង់ចាំទទួលនូវរាល់ការរិះគន់ដើម្បី

ស្តាបនាទាំងឡាយពីសំណាក់ ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ អ្នកសិក្សាស្រាវជ្រាវ មិត្តអ្នកអាន និងសិស្សនិស្សិតទាំងអស់។

ជាចុងបញ្ចប់ យើងខ្ញុំសូមជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ អ្នកសិក្សាស្រាវជ្រាវ មិត្តអ្នកអាន និងសិស្សនិស្សិតទាំងអស់ ឱ្យជួបប្រទះតែសំណាងល្អ និងទទួលបាននូវភាពជោគជ័យគ្រប់ភារកិច្ច។

✍🕮✍

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃបណ្តឹងឧបាស្រ័យ**

**ផ្នែកទី១៖ និយមន័យនៃបណ្តឹងឧបាស្រ័យ** ........ ៣

១. ការប្រើប្រាស់បណ្តឹងឧបាស្រ័យ ........ ៣

២. គោលបំណងនៃបណ្តឹងឧបាស្រ័យ ........ ៤

**ផ្នែកទី២៖ ភាពខុសគ្នារវាងបណ្តឹងឧបាស្រ័យ និងបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី** ........ ៥

១. បណ្តឹងឧបាស្រ័យ ........ ៥

២. បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ........ ៥

**ផ្នែកទី៣៖ ប្រភេទនៃបណ្តឹងឧបាស្រ័យ** ........ ៦

**ជំពូកទី២**

**បណ្តឹងឧទ្ធរណ៍**

**ផ្នែកទី១៖ និយមន័យនៃបណ្តឹងឧទ្ធរណ៍** ........ ៧

**ផ្នែកទី២៖ មូលហេតុ និងកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍** ........ ៨

១. មូលហេតុនៃបណ្តឹងឧទ្ធរណ៍ ........ ៨

២. កម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ........ ១០

**ផ្នែកទី៣៖ លក្ខខណ្ឌនៃបណ្តឹងឧទ្ធរណ៍** ........ ១១

១. អ្នកមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ ........ ១២

២. អំឡុងពេលនៃការធ្វើបណ្តឹងឧទ្ធរណ៍ ........ ១៣

**ផ្នែកទី៤៖ របៀបធ្វើបណ្តឹងឧទ្ធរណ៍** ........ ១៤

**ផ្នែកទី៥៖ អានុភាពនៃពាក្យបណ្តឹងឧទ្ធរណ៍** ........ ១៥

១. អានុភាពបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រម ........ ១៦

២. អានុភាពនៃការផ្ទេរការជំនុំជម្រះក្តី ..... ១៦
៣. អានុភាពអវិភាគនៃបណ្តឹងឧទ្ធរណ៍ ..... ១៧
**ផ្នែកទី៦៖ បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ** ..... ១៨
**ផ្នែកទី៧៖ នីតិវិធីនៃបណ្តឹងឧទ្ធរណ៍** ..... ១៩
១. ការទទួលពាក្យបណ្តឹងឧទ្ធរណ៍ ..... ១៩
២. ការពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍ ..... ២០
៣. ការបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍ ..... ២០
៤. ការកំណត់កាលបរិច្ឆេទនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ..... ២១
**ផ្នែកទី៨៖ ការជំនុំជម្រះបណ្តឹងឧទ្ធរណ៍** ..... ២១
១. គោលការណ៍នៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ..... ២១
២. ការទាញហេតុផលដោយផ្ទាល់មាត់ ..... ២២
**ផ្នែកទី៩៖ ការបញ្ចប់បណ្តឹងឧទ្ធរណ៍** ..... ២៤
១. ការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ ..... ២៤
១.១. ការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយស្វ័យប្រវត្តិ ..... ២៤
១.២. ការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយសកម្មភាពភាគី ..... ២៥
២. ការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ ..... ២៨
២.១. សាលដីកាលើកចោលបណ្តឹងឧទ្ធរណ៍ ..... ២៨
២.២. សាលដីកាច្រានចោលបណ្តឹងឧទ្ធរណ៍ ..... ២៩
២.៣. សាលដីកាទទួលស្គាល់បណ្តឹងឧទ្ធរណ៍ ..... ៣០
២.៣.១. ការលុបចោល និងការវិនិច្ឆ័យដោយខ្លួនឯង ..... ៣០
២.៣.២. ការលុបចោល និងការបញ្ជូនត្រលប់ទៅតុលាការដើមវិញ ..... ៣១
២.៣.៣. ការលុបចោល និងការផ្ទេរនូវរឿងក្តីទៅតុលាការផ្សេង ..... ៣២

## ជំពូកទី៣

## បណ្តឹងសាទុក្ខ

**ផ្នែកទី១៖ និយមន័យនៃបណ្តឹងសាទុក្ខ** ..... ៣៤

**ផ្នែកទី២៖ មូលហេតុ និងកម្មវត្ថុនៃបណ្តឹងសាទុក្ខ** ........ ៣៥
១. មូលហេតុនៃបណ្តឹងសាទុក្ខ ........ ៣៥
២. កម្មវត្ថុនៃបណ្តឹងសាទុក្ខ ........ ៣៧
**ផ្នែកទី៣៖ លក្ខខណ្ឌនៃបណ្តឹងសាទុក្ខ** ........ ៣៧
១. អ្នកមានសិទ្ធិធ្វើបណ្តឹងសាទុក្ខ ........ ៣៨
២. អំឡុងពេលនៃការធ្វើបណ្តឹងសាទុក្ខ ........ ៣៨
២.១. អំឡុងពេលនៃការដាក់ពាក្យបណ្តឹងសាទុក្ខ ........ ៣៨
២.២. អំឡុងពេលនៃការដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្តឹងសាទុក្ខ ........ ៣៩
**ផ្នែកទី៤៖ របៀបធ្វើបណ្តឹងសាទុក្ខ** ........ ៤០
**ផ្នែកទី៥៖ អានុភាពនៃពាក្យបណ្តឹងសាទុក្ខ** ........ ៤០
១. អានុភាពបង្អាក់ការចូលជាស្ថាពរ ........ ៤០
២. អានុភាពនៃការផ្ទេរការជំនុំជម្រះក្តី ........ ៤១
៣. អានុភាពអវិភាគនៃបណ្តឹងសាទុក្ខ ........ ៤១
**ផ្នែកទី៦៖ បណ្តឹងសាទុក្ខឆ្លោះ** ........ ៤១
**ផ្នែកទី៧៖ បណ្តឹងសាទុក្ខបន្ទាប់បន្សំ** ........ ៤២
**ផ្នែកទី៨៖ នីតិវិធីនៃបណ្តឹងសាទុក្ខ** ........ ៤២
១. ការទទួលពាក្យបណ្តឹងសាទុក្ខ ........ ៤៣
២. ការពិនិត្យពាក្យបណ្តឹងសាទុក្ខ ........ ៤៣
៣. ការបញ្ជូនពាក្យបណ្តឹងសាទុក្ខ ........ ៤៣
៤. ការកំណត់កាលបរិច្ឆេទនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ........ ៤៣
**ផ្នែកទី៩៖ ការជំនុំជម្រះបណ្តឹងសាទុក្ខ** ........ ៤៤
១. គោលការណ៍នៃការជំនុំជម្រះបណ្តឹងសាទុក្ខ ........ ៤៤
២. ការទាញហេតុផលដោយផ្ទាល់មាត់ករណីបណ្តឹងសាទុក្ខលើកទី១ ........ ៤៤
៣. ការទាញហេតុផលដោយផ្ទាល់មាត់ករណីបណ្តឹងសាទុក្ខលើកទី២ ........ ៤៥
**ផ្នែកទី១០៖ ការបញ្ចប់បណ្តឹងសាទុក្ខ** ........ ៤៦

១. ការបញ្ចប់បណ្តឹងសាទុក្ខដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ ..... ៤៦
១.១. ការបញ្ចប់បណ្តឹងសាទុក្ខដោយស្វ័យប្រវត្តិ ..... ៤៦
១.២. ការបញ្ចប់បណ្តឹងសាទុក្ខដោយសកម្មភាពភាគី..... ៤៧
២. ការបញ្ចប់បណ្តឹងសាទុក្ខដោយឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ ..... ៥០
២.១. ការលើកចោលបណ្តឹងសាទុក្ខដោយដីកាសម្រេច..... ៥០
២.២. សាលដីកាច្រានចោលបណ្តឹងសាទុក្ខ..... ៥០
២.៣. សាលដីកាទទួលស្គាល់បណ្តឹងសាទុក្ខ..... ៥០
២.៣.១. ការបដិសេធចោល និងបញ្ជូនត្រលប់ទៅតុលាការដើមវិញ ..... ៥១
២.៣.២. ការបដិសេធចោល និងការផ្ទេររឿងក្តីទៅតុលាការផ្សេង..... ៥២
២.៣.៣. ការបដិសេធចោល និងការវិនិច្ឆ័យដោយខ្លួនឯង ..... ៥២

## ជំពូកទី៤
## បណ្តឹងជំទាស់

**ផ្នែកទី១៖ និយមន័យនៃបណ្តឹងជំទាស់** ..... ៥៣
**ផ្នែកទី២៖ មូលហេតុ និងកម្មវត្ថុនៃបណ្តឹងជំទាស់** ..... ៥៣
១. មូលហេតុនៃបណ្តឹងជំទាស់ ..... ៥៣
២. កម្មវត្ថុនៃបណ្តឹងជំទាស់..... ៥៤
**ផ្នែកទី៣៖ លក្ខខណ្ឌនៃបណ្តឹងជំទាស់** ..... ៥៦
១. ភាគីនៃបណ្តឹងជំទាស់ ..... ៥៦
២. អំឡុងពេលក្នុងការធ្វើបណ្តឹងជំទាស់..... ៥៧
**ផ្នែកទី៤៖ របៀបធ្វើបណ្តឹងជំទាស់** ..... ៥៧
**ផ្នែកទី៥៖ អានុភាពនៃពាក្យបណ្តឹងជំទាស់**..... ៥៧
**ផ្នែកទី៦៖ នីតិវិធី និងការជំនុំជម្រះលើបណ្តឹងជំទាស់**..... ៥៨
១. ការទទួលពាក្យបណ្តឹងជំទាស់..... ៥៩
២. ការពិនិត្យពាក្យបណ្តឹងជំទាស់..... ៥៩
៣. ការទាញហេតុផលដោយផ្ទាល់មាត់ ..... ៥៩

**ផ្នែកទី៧៖ វិសាលភាពនៃការជំនុំជម្រះបណ្តឹងជំទាស់**...................................................... ៦០
១. វិសាលភាពនៃការជំនុំជម្រះបណ្តឹងជំទាស់ចំពោះដីកាសម្រេចនៃសាលាឧទ្ធរណ៍.............................. ៦០
២. វិសាលភាពនៃការជំនុំជម្រះបណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់ចៅក្រម
ដែលទទួលការបញ្ជា ឬ ការប្រគល់សិទ្ធិ.................................................................................... ៦១
**សេចក្តីសន្និដ្ឋាន** ............................................................................................................ ៦២
**អនុសាសន៍** ..................................................................................................................... ៦៥
**ឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ចាប់តាំងពីពេលដែលប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងភ្លើងសង្គ្រាម អស់រយៈពេលជាច្រើនឆ្នាំកន្លងមក ប្រព័ន្ធយុត្តិធម៌ក៏ត្រូវបានបំផ្លាញយ៉ាងដំណំ។ ជាពិសេសនៅរបបកម្ពុជាប្រជាធិបតេយ្យប្រព័ន្ធយុត្តិធម៌ត្រូវបាន បំផ្លាញទាំងស្រុង។ ប្រជាពលរដ្ឋត្រូវរងនូវការកាប់សម្លាប់ និងការរំលោភបំពានសិទ្ធិសេរីភាពដោយគ្មានការ ជំនុំជម្រះរកយុត្តិធម៌នោះទេ ជាងនេះទៅទៀតក្នុងរបបនេះគេមិនអនុញ្ញាតឱ្យមាននូវកម្មសិទ្ធិឯកជនឡើយ។ លុះមក ដល់អំឡុងឆ្នាំ១៩៩៣ មកដល់ពេលបច្ចុប្បន្ននេះយើងសង្កេតឃើញថា វិស័យយុត្តិធម៌របស់ប្រទេសកម្ពុជាមាន ការរីកចម្រើនគួរឱ្យកត់សម្គាល់។ ដោយគិតចាប់តាំងពីឆ្នាំ១៩៩៣ មកជាការពិតណាស់ច្បាប់ដ៏សំខាន់មួយចំនួន ដែលព្រះរាជាណាចក្រកម្ពុជាកំពុងតែអនុវត្តនាពេលបច្ចុប្បន្ន និងមានទំនាក់ទំនងសំខាន់សម្រាប់ការរស់នៅរបស់ ប្រជាពលរដ្ឋក្នុងការប្រាស្រ័យទាក់ទងគ្នា ឬ ទំនាក់ទំនងគតិយុត្តផ្សេងៗ ពោលគឺមានដូចជាក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ផ្សេងៗទៀត។ល។ ក្រមរដ្ឋប្បវេណី គឺជាក្រមដែលបានបញ្ញត្តិនូវទំនាក់ទំនងគតិយុត្ត ផ្នែករដ្ឋប្បវេណី ដែលរាល់វិវាទផ្សេងៗកើតមានឡើងក្នុងការទំនាក់ទំនងគ្នារវាងបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត ឬ ពីគ្រួសារមួយទៅគ្រួសារមួយ ឬ ពីរដ្ឋមួយទៅរដ្ឋមួយ ឬ រវាងកម្មករនិយោជិត និងនិយោជកតែងតែមានការជួប ប្រទះនូវបញ្ហាផ្សេងៗដែលមិនអាចគេចផុតទេដូចជា វិវាទដីធ្លី វិវាទពាណិជ្ជកម្ម វិវាទប្តីប្រពន្ធមិនចុះសម្រុងនឹងគ្នា វិវាទកូនចៅដែលទាក់ទងនឹងទ្រព្យសម្បត្តិ និងវិវាទផ្សេងៗទៀត។ វិវាទរួមទាំងទំនាក់ទំនងគតិយុត្តទាំងនេះមាន ចែងនៅក្នុងក្រមរដ្ឋប្បវេណី គឺត្រូវយកក្រមនេះមកអនុវត្ត លើកលែងតែមានការកំណត់ផ្សេងនៅក្នុងច្បាប់ពិសេស ហើយចំពោះការអនុវត្តវិញ គឺត្រូវអនុលោមតាមបញ្ញត្តិដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ដែលជាលំហូរ នីតិវិធីក្នុងការជំនុំជម្រះរឿងក្តីរដ្ឋប្បវេណី និងនីតិវិធីអនុវត្តផ្សេងៗនៅតាមសាលាជម្រះក្តី។ ដូច្នេះដើម្បីធ្វើឱ្យមាន ការស្ងប់អារម្មណ៍ និងមានភាពអស់ចិត្តនូវជម្លោះ ឬ វិវាទខាងលើរបស់ភាគី ភាគីនៃជម្លោះនោះតែងតែរិះរកវិធី ដោះស្រាយ។ វិធីដោះស្រាយនេះអាចជាវិធីដោះស្រាយតាមផ្លូវតុលាការដែលជាយន្តការចាប់បង្ខំដែលត្រូវបាន ច្បាប់រៀបចំផ្តល់សិទ្ធិអំណាចដល់ស្ថាប័នចំនួនបី គឺមានដូចជាសាលាដំបូងនៅតាមបណ្តារាជធានី ឬ ខេត្ត សាលាឧទ្ធរណ៍នៅតាមតំបន់ និងតុលាការកំពូល។

នៅក្នុងរឿងក្តីរដ្ឋប្បវេណី ការដោះស្រាយវិវាទជំហានដំបូងគឺជាសមត្ថកិច្ចរបស់សាលាដំបូងដែលហៅថា តុលាការជាន់ទាប ដែលមាននៅគ្រប់ខេត្តក្រុង។ ប្រសិនបើភាគីណាដែលបានបាត់បង់ផលប្រយោជន៍នៅក្នុង រឿងក្តី ឬ ភាគីដែលឈ្នះក្តី ហើយទទួលបានផលប្រយោជន៍មិនបានដូចបំណង ឬ ក៏ភាគីនៅតែមិនអាចដោះស្រាយ វិវាទដោយស្មោះស្ម័គ្រ ឬ ភាគីបានព្រមព្រៀងគ្នាហើយ ភាគីនៅតែមិនអាចជ្រើសមធ្យោបាយណាមួយដើម្បីធ្វើ ការដោះស្រាយវិវាទទេ ភាគីអាចដាក់ពាក្យប្តឹងទៅតុលាការជាន់ខ្ពស់ដើម្បីបន្តនីតិវិធីទាមទារអ្វីដែលខ្លួនចង់បាន។ ចំពោះការដាក់ពាក្យប្តឹងទៅតុលាការជាន់ខ្ពស់នោះ គេហៅថាបណ្តឹងឧបាស្រ័យ គឺជាសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍

និងតុលាការកំពូល។ ចំពោះការធ្វើបណ្តឹងឧបាស្រ័យ ភាគីអាចប្តឹងទៅតុលាការជាន់ខ្ពស់គ្រប់សេចក្តីសម្រេចរបស់តុលាការជាន់ទាប។ មិនតែប៉ុណ្ណោះការធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន លុះត្រាតែសេចក្តីសម្រេចរបស់តុលាការជាន់ទាបមិនទាន់ចូលជាស្ថាពរ។ សេចក្តីសម្រេចរបស់តុលាការជាន់ទាបមានពីរប្រភេទ គឺប្រភេទជាដីកាសម្រេច និងប្រភេទជាសាលក្រម ឬ សាលដីកា។ ចំពោះសេចក្តីសម្រេចដែលចេញជាប្រភេទដីកាសម្រេចទាល់តែមានច្បាប់ចែងថាដីកាសម្រេចណាដែលអាចធ្វើការប្តឹងឧបាស្រ័យបានទើបភាគីអាចធ្វើបាន ពីព្រោះប្រភេទដីកាសម្រេចខ្លះភាគីមិនអាចប្តឹងឧបាស្រ័យបានទេ លុះត្រាតែច្បាប់បានចែងច្បាស់ថាដីកាសម្រេចនោះអាចប្តឹងឧបាស្រ័យបាន។ ប៉ុន្តែចំពោះសេចក្តីសម្រេចដែលចេញជាសាលក្រមវិញភាគីអាចធ្វើបណ្តឹងឧបាស្រ័យបានដោយច្បាប់មិនបានហាមឃាត់ឡើយ ប្រសិនបើភាគីចង់ប្តឹងដោយភាគីគិតថាខ្លួនបានបាត់បង់ផលប្រយោជន៍ ឬ មិនពេញចិត្តនឹងសេចក្តីសម្រេចនោះ។ ហេតុនេះមានការលើកឡើងថា តើបណ្តឹងឧបាស្រ័យជាអ្វី? តើបណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងសាទុក្ខ ឬ បណ្តឹងជំទាស់ជាអ្វី? តើបណ្តឹងនីមួយៗមាននីតិវិធីយ៉ាងដូចម្តេច? ដើម្បីឆ្លើយតបនឹងការលើកឡើងនេះ យើងនឹងធ្វើការអត្ថាធិប្បាយដោយផ្អែកលើក្រមនីតិវិធីរដ្ឋប្បវេណី និងឯកសារផ្សេងៗជាច្រើនដែលបានជ្រាវស្រាវ។ ការអត្ថាធិប្បាយប្រព្រឹត្តតាមលំដាប់លំដោយដូចជា ជំពូកទី១ គឺសញ្ញាណទូទៅនៃបណ្តឹងឧបាស្រ័យ, ជំពូកទី២ គឺបណ្តឹងឧទ្ធរណ៍, ជំពូកទី៣ គឺបណ្តឹងសាទុក្ខ, និងជំពូកទី៤ គឺបណ្តឹងជំទាស់៖

# ជំពូកទី១

# សញ្ញាណទូទៅនៃបណ្ដឹងឧបាស្រ័យ

បណ្ដឹង គឺជាសកម្មភាពទាមទារមួយដែលបានធ្វើឡើងដោយដើមចោទចំពោះចុងចម្លើយទៅតុលាការដែលមានសមត្ថកិច្ចក្នុងការជំនុំជម្រះក្ដីដោយអះអាងអំពី អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់ ហើយទាមទារឱ្យតុលាការចេញសាលក្រម ឬ សាលដីកា។[1] ដូច្នេះកាលណាតុលាការដែលមានសមត្ថកិច្ចទទួលពាក្យបណ្ដឹង តុលាការអាចចាប់ផ្ដើមនីតិវិធីបណ្ដឹងដោយធ្វើការជំនុំជម្រះទៅលើបណ្ដឹងនោះ រួចនឹងចេញសេចក្ដីសម្រេចតាមសាលក្រម ឬ សាលដីកា។ ចំពោះការធ្វើឧបាស្រ័យ សំដៅលើការមិនយល់ស្របទៅនឹងសេចក្ដីសម្រេចណាមួយដែលមានការតវ៉ាទាមទារឱ្យធ្វើការកែប្រែ ឬ លុបចោលនូវសេចក្ដីសម្រេចនោះ។ ជារួមបណ្ដឹងឧបាស្រ័យតាមនិយមន័យខាងលើ គឺជាបណ្ដឹងដែលធ្វើឡើងដើម្បីផ្លាស់ប្ដូរ ឬ លុបចោលនូវសេចក្ដីសម្រេចណាមួយដែលភាគីមិនពេញចិត្ត ដោយភាគីបានទាមទារក្នុងបណ្ដឹងឧបាស្រ័យ។

ដើម្បីឱ្យកាន់តែច្បាស់អំពីសញ្ញាណទូទៅនៃបណ្ដឹងឧបាស្រ័យ មុននឹងធ្វើការសិក្សាអំពីប្រភេទបណ្ដឹងនីមួយៗនៃបណ្ដឹងឧបាស្រ័យ គឺត្រូវស្វែងយល់ជាមុនសិននូវនិយមន័យច្បាស់លាស់ដែលអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណី និងការប្រើប្រាស់បណ្ដឹងឧបាស្រ័យ រួមទាំងគោលបំណងនៃការប្រើប្រាស់បណ្ដឹងឧបាស្រ័យ។

## ផ្នែកទី១៖ និយមន័យនៃបណ្ដឹងឧបាស្រ័យ

បណ្ដឹងឧបាស្រ័យ គឺជាប្រភេទបណ្ដឹងដែលធ្វើឡើងទៅតុលាការជាន់ខ្ពស់ ដែលទាមទារដោយភាគីដើម្បីផ្លាស់ប្ដូរ ឬ លុបចោលនូវសេចក្ដីសម្រេចដែលមិនទាន់ចូលជាស្ថាពររបស់តុលាការជាន់ទាប។[2] ឧទាហរណ៍៖ នៅពេលដែលភាគីមិនពេញចិត្តនូវសេចក្ដីសម្រេចណាមួយរបស់តុលាការជាន់ទាប ជាក់ស្ដែងដូចជាសាលាដំបូងរាជធានី-ខេត្ត ហើយសេចក្ដីសម្រេចនោះមិនទាន់ចូលជាស្ថាពរ គឺភាគីអាចប្ដឹងឧបាស្រ័យទៅសាលាឧទ្ធរណ៍បាន។

### ១. ការប្រើប្រាស់បណ្ដឹងឧបាស្រ័យ

ការធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ប្រព្រឹត្តទៅតាមល័ក្ខខ័ណ្ឌនៃប្រភេទនីមួយៗដូចខាងក្រោម៖

- ភាគីអាចធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន មុនពេលសេចក្ដីសម្រេចមិនទាន់ចូលជាស្ថាពរតែប៉ុណ្ណោះ។ ហេតុដូចនេះអាចនិយាយបានថាបើសេចក្ដីសម្រេចនោះចូលជាស្ថាពរគឺមិនអាចធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បានទេ។ ចំពោះសេចក្ដីសម្រេចដែលមិនទាន់ចូលជាស្ថាពរដែលភាគីអាចប្ដឹងឧបាស្រ័យបានមានដូចជា៖ សាលក្រម ឬ សាលដីកា ឬ ដីកាសម្រេច។ ផ្ទុយមកវិញសេចក្ដីសម្រេចដែលបាន

[1] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៧៤

[2] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៥៩

ចូលជាស្ថាពរ គឺអាចប្រើប្រាស់បណ្ដឹងផ្សេងទៀតទៅតុលាការបាន ក្រៅពីបណ្ដឹងឧបាស្រ័យ តែជាមធ្យោបាយឧបាស្រ័យដដែល គឺបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី។

➢ ចំពោះសាលក្រម ឬ សាលដីកា ភាគីអាចធ្វើបណ្ដឹងឧទ្ធរណ៍ ឬ បណ្ដឹងសាទុក្ខបាន។ ដោយបណ្ដឹងឧទ្ធរណ៍ធ្វើឡើងដើម្បីផ្លាស់ប្ដូរ ឬ លុបចោលនូវសាលក្រមដែលមិនទាន់ចូលជាស្ថាពររបស់សាលាដំបូង ឬ អាចធ្វើបណ្ដឹងសាទុក្ខក្នុងករណីគូភាគីបានព្រមព្រៀងមិនប្ដឹងឧទ្ធរណ៍ ហើយរក្សាទុកនូវសិទ្ធិប្ដឹងសាទុក្ខ ក្រោយពីតុលាការបានចេញសាលក្រមចុងក្រោយ។[3] ចំណែកបណ្ដឹងសាទុក្ខធ្វើឡើងចំពោះសាលដីកាដែលមិនទាន់ចូលជាស្ថាពររបស់សាលាឧទ្ធរណ៍។

➢ ចំណែកបណ្ដឹងជំទាស់វិញ គឺជាបណ្ដឹងឧបាស្រ័យចំពោះដីកាសម្រេចរបស់តុលាការជាន់ទាប ប៉ុន្តែបណ្ដឹងជំទាស់នេះអាចធ្វើទៅបានលុះត្រាតែមានបញ្ញត្តិក្នុងច្បាប់។[4] ឧទាហរណ៍៖ ដីកាសម្រេចដែលអាចប្ដឹងជំទាស់បាន ដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រង់មាត្រា៣០២ គឺដីកាសម្រេចរបស់ចៅក្រមដែលទទួលបញ្ហា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ ពោលភាគីអាចប្ដឹងឧបាស្រ័យបាននៅពេលដែលភាគីមិនពេញចិត្តនឹងដីកាសម្រេចនោះ។ លើសពីនេះទៅទៀតកាលណាភាគីដែលបានប្ដឹងជំទាស់ចំពោះដីកាសម្រេចដែលមានចែងក្នុងក្រមរួចហើយ មិនអាចប្ដឹងជំទាស់ទៅលើដីកាសម្រេចចំពោះបណ្ដឹងជំទាស់មុនបានឡើយ។

## ២. គោលបំណងនៃបណ្ដឹងឧបាស្រ័យ

បណ្ដឹងឧបាស្រ័យ គឺធ្វើឡើងដោយមានគោលបំណងដូចជា ការសង្គ្រោះសិទ្ធិរបស់ភាគី ការចេញសេចក្ដីសម្រេចដ៏ត្រឹមត្រូវ និងផ្ដល់យុត្តិធម៌ដល់ភាគី។ ដរាបណាការសម្រេចសេចក្ដីធ្វើឡើងដោយមនុស្ស គឺអាចវិនិច្ឆ័យ និងសម្រេចសេចក្ដីដោយខុស ឬ តែងមានការភ័ន្តច្រឡំកើតឡើងដោយជៀសផុតមិនរួច ដូចគ្នានឹងការសម្រេចសេចក្ដីរបស់តុលាការដែរ ពោលគឺពេលខ្លះមិនប្រាកដថាមានភាពត្រឹមត្រូវទាំងអស់នោះទេ ដោយសារតុលាការមិនបានពិនិត្យភស្តុតាង ឬ ឯកសារផ្សេងៗឱ្យបានគ្រប់ជ្រុងជ្រោយឡើយ ហេតុដូចនេះបើនៅតែទុកឱ្យស្ថានភាពនៅតែមានកំហុសនោះនឹងធ្វើឱ្យមានការបំពានសិទ្ធិរបស់ភាគី ថែមទាំងធ្វើឱ្យបាត់បង់ជំនឿ និងការទុកចិត្តលើប្រព័ន្ធតុលាការទៀតផង។ ដូច្នេះហើយចាំបាច់ត្រូវមាននីតិវិធីនៃការប្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដើម្បីឱ្យតុលាការជាន់ខ្ពស់អាចពិនិត្យមើលនូវសេចក្ដីសម្រេចរបស់តុលាការជាន់ទាបបាន តាមពាក្យសុំរបស់ភាគីម្ខាងដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចនោះ ហើយប្រសិនបើសេចក្ដីសម្រេចរបស់តុលាការជាន់ទាបមិនត្រឹមត្រូវ តុលាការជាន់ខ្ពស់អាចធ្វើការកែប្រែ ឬ លុបចោលនូវសេចក្ដីសម្រេចនោះបាន។ បានសេចក្ដីថាបើភាគីណាម្ខាង

[3] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៥៩ កថាខណ្ឌទី១ ចំណុច ក និង ខ

[4] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៥៩ កថាខណ្ឌទី១ ចំណុច គ និងកថាខណ្ឌទី២

មិនពេញចិត្តនឹងសេចក្តីសម្រេចរបស់តុលាការជាន់ទាបទេ ភាគីនោះមានសិទ្ធិក្នុងការធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដើម្បីទាមទារនូវអ្វីដែលខ្លួនចង់បាន ឬ អ្វីដែលមិនបាត់បង់ផលប្រយោជន៍របស់ខ្លួន។ ម៉្យាងទៀត នីតិវិធីនៃការធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ជាយន្តការមួយសម្រាប់ធ្វើការសង្គ្រោះសិទ្ធិភាគីឱ្យផុតពីការវិនិច្ឆ័យខុស ឬ កំហុសក្នុងនីតិវិធីនៃការជំនុំជម្រះ ជាងនេះទៅទៀតតុលាការបានចេញសេចក្តីសម្រេចដ៏ត្រឹមត្រូវ និងផ្តល់យុត្តិធម៌ដល់ភាគីផងដែរ។[5]

## ផ្នែកទី២៖ ភាពខុសគ្នារវាងបណ្តឹងឧបាស្រ័យ និងបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

តាមការបកស្រាយខាងលើបណ្តឹងឧបាស្រ័យ និងបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មានលក្ខខណ្ឌដូចគ្នាមួយដែលជាមធ្យោបាយសម្រាប់ឧបាស្រ័យ ប៉ុន្តែមានលក្ខខណ្ឌខុសគ្នាមួយចំនួនដូចជា៖

### ១. បណ្តឹងឧបាស្រ័យ

បណ្តឹងឧបាស្រ័យ គឺជាប្រភេទបណ្តឹងដែលធ្វើឡើងទៅតុលាការជាន់ខ្ពស់ ដែលទាមទារដោយភាគីដើម្បីផ្លាស់ប្តូរ ឬ លុបចោលនូវសេចក្តីសម្រេចដែលមិនទាន់ចូលជាស្ថាពររបស់តុលាការជាន់ទាប ដោយមូលហេតុត្រូវសង្គ្រោះសិទ្ធិរបស់ភាគីដែលភាគីត្រូវបានបំពានសិទ្ធិ និងបាត់បង់ផលប្រយោជន៍ ថែមទាំងផ្តល់នូវការចេញសេចក្តីសម្រេចដ៏ត្រឹមត្រូវ និងមានយុត្តិធម៌ដល់ភាគី។

ដូច្នេះបណ្តឹងឧបាស្រ័យធ្វើទៅបាន បើសិនបើសេចក្តីសម្រេចរបស់តុលាការជាន់ទាបដែលជាសាលក្រម ឬ សាលដីកា ឬ ដីកាសម្រេច មិនទាន់ចូលជាស្ថាពរ។

តុលាការដែលមានសមត្ថកិច្ចផ្តាច់មុខនៃការជំនុំជម្រះបណ្តឹងឧបាស្រ័យគឺ តុលាការជាន់ខ្ពស់ជាងតុលាការដែលបានចេញសេចក្តីសម្រេច រួមមានសាលក្រម ឬ សាលដីកា ឬ ដីកាសម្រេចមិនទាន់ចូលជាស្ថាពរនោះ។[6]

### ២. បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺជាប្រភេទបណ្តឹងធ្វើឡើងទៅតុលាការដដែល ដែលបានចេញសេចក្តីសម្រេចដែលចូលជាស្ថាពរ ដើម្បីធ្វើការពិនិត្យ និងលើកយកសំណុំរឿងដែលបានចូលជាស្ថាពរនោះមកធ្វើការវិនិច្ឆ័យឡើងវិញម្តងទៀត ដោយមូលហេតុការសម្រេចសេចក្តីមានចំណុចខ្វះចន្លោះក្នុងដំណើរការនីតិវិធីនៃបណ្តឹង ឬ ឯកសារដែលជាមូលដ្ឋាននៃសេចក្តីវិនិច្ឆ័យសាលក្រម ឬ សាលដីកានោះមានវិការៈធ្ងន់ធ្ងរ ឬ មានភាពខ្វះខាតមិនប្រក្រតីនោះ ដែលបានចូលជាស្ថាពររួចហើយ ជារួមមកមូលហេតុដែលអាចប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានគឺមានបញ្ញត្តិក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រង់មាត្រា៣០៧ និងមាត្រា៣០៨។

[5] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១៖ នីតិវិធីបណ្តឹង គន្លឹទី៤ ជំពូក១ ចំណុច២

[6] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៥៩

ដូចនេះចំពោះបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីអាចធ្វើទៅបាន លុះត្រាតែសេចក្តីសម្រេចនោះចូលជាស្ថាពរ ដែលជាសាលក្រម ឬ សាលដីកាចុងក្រោយ តែមិនមានដីកាសម្រេចដែលអាចប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានឡើយ។

តុលាការដែលមានសមត្ថកិច្ចផ្តាច់មុខនៃការជំនុំជម្រះចំពោះបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺតុលាការដែលបានចេញសាលក្រម ឬ សាលដីកាចុងក្រោយដែលចូលជាស្ថាពរនោះ។

សរុបមកវិញបណ្តឹងឧបាស្រ័យ និងបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មានល័ក្ខខ័ណ្ឌខុសគ្នាត្រង់ថា មូលហេតុដែលនាំឱ្យមានការធ្វើបណ្តឹងទាំងពីរ ហើយបណ្តឹងឧបាស្រ័យធ្វើឡើងចំពោះសេចក្តីសម្រេចមិនទាន់ចូលជាស្ថាពរ ប៉ុន្តែបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីធ្វើឡើងចំពោះសេចក្តីសម្រេចដែលចូលជាស្ថាពរ និងខុសគ្នាទៀតត្រង់ថាតុលាការដែលសមត្ថកិច្ចផ្តាច់មុខចំពោះបណ្តឹងនីមួយៗ។

## ផ្នែកទី៣៖ ប្រភេទនៃបណ្តឹងឧបាស្រ័យ

បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់មានបីប្រភេទគឺ បណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ និងបណ្តឹងជំទាស់។

- ចំពោះបណ្តឹងឧទ្ធរណ៍ ធ្វើឡើងចំពោះសាលក្រមដែលមិនទាន់ចូលជាស្ថាពររបស់សាលាដំបូង។[7]
- ចំណែកបណ្តឹងសាទុក្ខ ធ្វើឡើងចំពោះសាលដីកាដែលមិនទាន់ចូលជាស្ថាពររបស់សាលាឧទ្ធរណ៍ ឬ អាចធ្វើបណ្តឹងសាទុក្ខក្នុងករណីគូភាគីបានព្រមព្រៀងមិនប្តឹងឧទ្ធរណ៍ ហើយរក្សាទុកនូវសិទ្ធិប្តឹងសាទុក្ខ ក្រោយពីតុលាការបានចេញសាលក្រមចុងក្រោយ។[8]
- រីឯបណ្តឹងជំទាស់វិញ ធ្វើឡើងចំពោះដីកាសម្រេចរបស់តុលាការជាន់ទាប ប៉ុន្តែបណ្តឹងជំទាស់នេះអាចធ្វើទៅបានលុះត្រាតែមានបញ្ញត្តិនៅក្នុងច្បាប់។ ចំពោះដីកាសម្រេចលើបណ្តឹងជំទាស់មិនអាចប្តឹងជំទាស់ទៀតបានឡើយ។[9]

ហេតុនេះហើយបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់មានប្រភេទផ្សេងៗគ្នាចំនួនបី ដែលបែងចែកទៅតាមប្រភេទនៃសេចក្តីសម្រេចដើម ពោលគឺសេចក្តីសម្រេចរបស់តុលាការជាន់ទាប។ បើបុគ្គលដែលមានបំណងចង់ដាក់ពាក្យបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺត្រូវជ្រើសរើសប្រភេទនៃបណ្តឹងឧបាស្រ័យឱ្យបានត្រឹមត្រូវដោយស្របទៅតាមប្រភេទនៃសេចក្តីសម្រេចដើម។

[7] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៥៩ កថាខណ្ឌទី១ ចំណុច ក

[8] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៥៩ កថាខណ្ឌទី១ ចំណុច ខ

[9] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៥៩ កថាខណ្ឌទី១ ចំណុច គ និងកថាខណ្ឌទី២ និង៣

# ជំពូកទី២
# បណ្តឹងឧទ្ធរណ៍

នៅក្រោយពេលដែលសាលាដំបូងបានចេញសាលក្រម ភាគីដែលមិនខុសចិត្តនឹងសាលក្រមនោះអាចធ្វើបណ្តឹងឧទ្ធរណ៍ទៅតុលាការនៃបណ្តឹងឧទ្ធរណ៍បានដែលជាតុលាការនៃការជំនុំជម្រះលើកទី២។ យ៉ាងណាមិញ បណ្តឹងឧទ្ធរណ៍ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលត្រូវគោរពតាមលំហូរនៃនីតិវិធីដូចជា ការដាក់ពាក្យបណ្តឹងឧទ្ធរណ៍តាមរបៀបនៃការធ្វើបណ្តឹងឧទ្ធរណ៍ដែលមានកម្មវត្ថុ និងល័ក្ខខ័ណ្ឌឱ្យបានគ្រប់គ្រាន់ អានុភាពនៃការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ និងបន្ថែមជាមួយបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ រួមទាំងនីតិវិធី និងការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ និងចុងក្រោយការចេញសាលដីកានៃជំនុំជម្រះបណ្តឹងឧទ្ធរណ៍។ ដើម្បីឱ្យកាន់តែច្បាស់នៅខាងក្រោមនេះនឹងធ្វើការបកស្រាយអំពីលំហូរនៃនីតិវិធីទាំងអស់ដូចជា៖

## ផ្នែកទី១៖ និយមន័យនៃបណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១ របស់សាលាដំបូង ក្នុងគោលបំណងលុបចោល ឬ ផ្លាស់ប្តូរនូវសាលក្រមចុងក្រោយនោះ។ ដូច្នេះបណ្តឹងឧទ្ធរណ៍អាចធ្វើឡើងបានតែចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១ របស់សាលាដំបូងតែប៉ុណ្ណោះ។[10] ចំពោះតុលាការជាន់ខ្ពស់ គឺសម្តៅលើតុលាការដែលជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ដែលហៅថា "តុលាការនៃការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍"។ ហើយការជំនុំជម្រះដោយតុលាការនៃបណ្តឹងឧទ្ធរណ៍ ហៅថា "ការជំនុំជម្រះលើកទី២"។ ការជំនុំជម្រះលើកទី២ គឺវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការប្តឹងឧបាស្រ័យចំពោះសាលក្រមនៃការជំនុំជម្រះលើកទី១ ហើយជាមួយគ្នានោះដែរ ត្រូវពិនិត្យឡើងវិញទៅលើអង្គហេតុ និងអង្គច្បាប់ ចំពោះការទាមទារនៃការជំនុំជម្រះលើកទី១។ ដូចនេះឧទាហរណ៍បានថា នៅពេលដែលមានបណ្តឹងទៅសាលាដំបូង បើតុលាការ (សម្តៅទៅលើចៅក្រម ឬ ក្រុមប្រឹក្សាជំនុំជម្រះ ដែលទទួលបន្ទុករឿងក្តីទាក់ទងនឹងបណ្តឹងនោះ) យល់ព្រមទទួលពាក្យបណ្តឹង នោះនឹងមាននីតិវិធីនៃការជំនុំជម្រះលើកទី១ រហូតដល់ចេញសាលក្រមចុងក្រោយដែលមិនទាន់ចូលជាស្ថាពរ ភាគីណាដែលមិនពេញចិត្តនឹងសាលក្រមចុងក្រោយនោះ ភាគីអាចធ្វើបណ្តឹងឧទ្ធរណ៍ទៅតុលាការនៃបណ្តឹងឧទ្ធរណ៍បាន រួចតុលាការនៃបណ្តឹងឧទ្ធរណ៍នឹងត្រួតពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍ បើតុលាការយល់ឃើញថាត្រឹមត្រូវ នោះតុលាការនឹងបើកដំណើរការនីតិវិធីនៃការជំនុំជម្រះលើកទី២។

ដោយឡែកក្នុងករណីការជំនុំជម្រះលើកទី១ អាចអនុវត្តនៅតុលាការនៃបណ្តឹងឧទ្ធរណ៍បានដែរ ប្រសិនបើមានចែងនៅក្នុងបញ្ញត្តិពិសេស។ ឧទាហរណ៍៖ សេចក្តីសម្រេចរបស់គណៈមេធាវីជាអាទិ៍បានសម្រេចថាតុលាការ

[10] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៥៩ កថាខណ្ឌទី១ ចំណុច ក

នៃបណ្តឹងឧទ្ធរណ៍ជាតុលាការនៃការជំនុំជម្រះលើកទី១។ ដូច្នេះបណ្តឹងឧបាស្រ័យចំពោះសាលដីកាចុងក្រោយរបស់សាលាឧទ្ធរណ៍ដែលចេញក្នុងនាមជាការជំនុំជម្រះលើកទី១ អាចប្តឹងបានដល់បណ្តឹងសាទុក្ខ។ ជារួមមកតុលាការនៃបណ្តឹងឧទ្ធរណ៍ធ្វើក្នុងនាមជាការជំនុំជម្រះលើកទី១ចំពោះករណីមានចែងក្នុងបញ្ញត្តិពិសេស និងធ្វើការជំនុំជម្រះលើកទី២ ចំពោះសាលក្រមចុងក្រោយរបស់សាលាដំបូងដែលបញ្ញត្តិក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។[11]

ចំពោះសាលក្រមដែលមិនអាចធ្វើបណ្តឹងឧទ្ធរណ៍បាន គឺសាលក្រមរបៀបដោយសារតែសាលក្រមនេះពុំមានអានុភាពអ្វីផ្សេង ក្រៅពីអានុភាពដើម្បីត្រៀមចេញសាលក្រមចុងក្រោយក្នុងការជំនុំជម្រះ វាពុំមានអាជ្ញាអស់ជំនុំ ឬ អានុភាពអនុវត្តទេ។[12]

## ផ្នែកទី២៖ មូលហេតុ និងកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍

មុននឹងធ្វើឡើងនូវបណ្តឹងឧទ្ធរណ៍ គឺត្រូវតែមានមូលហេតុ និងកម្មវត្ថុត្រឹមត្រូវ។ មូលហេតុ និងកម្មវត្ថុនោះអាចបកស្រាយ និងមានបញ្ញត្តិនៅក្នុងច្បាប់ដូចខាងក្រោម៖

### ១. មូលហេតុនៃបណ្តឹងឧទ្ធរណ៍

គោលគំនិតនៃបណ្តឹងឧទ្ធរណ៍ទៅតុលាការជាន់ខ្ពស់ គឺដើម្បីកែប្រែ ផ្លាស់ប្តូរ ឬ លុបចោលសេចក្តីសម្រេចរបស់តុលាការជាន់ទាបដែលមានកំហុស និងធ្វើឱ្យមានឯកភាពគ្នាក្នុងការបកស្រាយច្បាប់ដើម្បីធានាឱ្យបាននូវស្ថិរភាពផ្នែកគតិយុត្តនៃជីវភាពរបស់ប្រជាពលរដ្ឋ។ ការសម្រេចសេចក្តីចំពោះការទាមទារតាមផ្លូវច្បាប់ បណ្តឹងត្រូវធ្វើឡើងដោយតុលាការ ដែលមានចៅក្រមជាអ្នកធ្វើសេចក្តីសម្រេច។ ចៅក្រមជាមនុស្សធម្មតាដូចយើងទាំងអស់គ្នាដែរ ដែលជៀសមិនផុតពីការបង្កើតនូវកំហុសដោយចេតនា ឬ អចេតនាហើយកំហុសនេះអាចបំពានសិទ្ធិរបស់ភាគី និងអាចធ្វើឱ្យទំនុកចិត្តជាសាធារណៈចំពោះប្រព័ន្ធតុលាការ ឬ ប៉ះពាល់ដល់យុត្តិធម៌សង្គម។ ហេតុនេះតម្រូវឱ្យមានប្រព័ន្ធមួយសម្រាប់ត្រួតពិនិត្យនូវសេចក្តីសម្រេចចុងក្រោយរបស់សាលាដំបូង (តុលាការជាន់ទាប) ឡើងវិញ ដោយតុលាការនៃបណ្តឹងឧទ្ធរណ៍ (តុលាការជាន់ខ្ពស់) ក្នុងករណីប្រសិនបើភាគីបានធ្វើបណ្តឹងឧទ្ធរណ៍។

រីឯមូលហេតុនៃបណ្តឹងឧទ្ធរណ៍ដែលកំណត់ជាក់លាក់នៅក្នុងច្បាប់ដែលមានបួនស្ថានភាពគឺ៖

- សាលក្រមនៃការជំនុំជម្រះលើកទី១ មិនត្រឹមត្រូវ គឺជាស្ថានភាពដែលសាលក្រមនោះមានកំហុស ឬ សេចក្តីសម្រេចចុងក្រោយនៃសាលក្រមដើមមានលក្ខណៈមិនត្រឹមត្រូវផ្អែកតាមសំអាងហេតុផ្សេងរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ (ភស្តុតាង និងច្បាប់សារធាតុ) ដូចជាអត្ថិភាព ឬ នត្ថិភាពនៃកាតព្វកិច្ច ការលើកឡើងអំពីមូលហេតុនៃការរំលាយ ឬ លុបចោល ឬ មោឃភាពនៃកិច្ចសន្យាជាអាទិ៍។[13] ឧទាហរណ៍៖ ភាគីដើមចោទឈ្មោះ

[11] មេរៀនស្តីពីបណ្តឹងឧទ្ធរណ៍ ឧទ្ទេសនាមដោយ លោកមេធាវី អ៊ីវ ប៉ូលី

[12] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១៖ នីតិវិធីបណ្តឹង គន្ថីទី៣ ជំពូកទី៤ ផ្នែកទី១ កថាខណ្ឌទី១ ចំណុច២

[13] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៧៩ កថាខណ្ឌទី១ ចំណុច ក

សុខ បានប្តឹងភាគីចុងចម្លើយឈ្មោះ សៅ ទៅសាលាដំបូងដើម្បីឱ្យតុលាការចេញសាលក្រមលេខ១៦៨ "ក" ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ ដែលមានខ្លឹមសារថា បង្គាប់ឱ្យចុងចម្លើយឈ្មោះ សៅ ធ្វើនីតិវិធីលុបចោលការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដីដែលមានទីតាំងនៅរាជធានីភ្នំពេញ ដោយមូលហេតុរំលាយកិច្ចសន្យាលក់ទិញចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩។ ដោយតុលាការយល់ឃើញថាមានមូលហេតុនៃការរំលាយកិច្ចសន្យា ប៉ុន្តែភាគីចុងចម្លើយឈ្មោះ សៅ យល់ថាតាមលក្ខណៈសារធាតុគ្មានមូលហេតុរំលាយកិច្ចសន្យាទេ ដោយសារខ្លួនបានបំពេញកាតព្វកិច្ចតាមការកំណត់ក្នុងកិច្ចសន្យាលក់ទិញចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ រួចរាល់អស់ហើយ។ ដូច្នេះសាលក្រមខាងលើភាគីចុងចម្លើយអាចធ្វើការប្តឹងឧទ្ធរណ៍បាន។

➢ នីតិវិធីជំនុំជម្រះលើកទី១នៅសាលាដំបូង ផ្ទុយនឹងនីតិវិធីច្បាប់ធ្ងន់ធ្ងរ ដែលជាស្ថានភាពរបស់សាលាដំបូងបានជម្រះក្តីដោយបំពានលើនីតិវិធីដែលច្បាប់បានកំណត់ ដូចជាទាក់ទងនឹងការពិនិត្យភស្តុតាង ការបញ្ជូន ការប្រកាសសាលក្រមជាអាទិ៍។[14] ឧទាហរណ៍៖ ដើមចោទជាភាគី "ក" បានដាក់ពាក្យបណ្តឹងប្តឹងភាគី "ខ" ឱ្យបង់ប្រាក់ចំនួន ២,000ដុល្លារ ដោយផ្អែកលើមូលហេតុនៃកិច្ចសន្យាលក់ទិញម៉ូតូចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០។ តុលាការបានធ្វើការសាកសួរសាក្សី "គ" ដែលជាសាក្សីរបស់ភាគី "ក" នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ ដោយផ្អែកលើចម្លើយរបស់សាក្សី "គ" ដែលបានធ្វើនៅក្នុងនីតិវិធីត្រៀមនោះ ថាខ្លួនជាបុគ្គលិកបានឃើញភាគី "ខ" ទៅហាងលក់ម៉ូតូរបស់ភាគី "ក" ហើយបានទិញម៉ូតូចំនួនពីរគ្រឿងតម្លៃ ២,000ដុល្លារ ទើបតុលាការបានសម្រេចឱ្យភាគី "ខ" បង់ប្រាក់ចំនួន ២,000ដុល្លារ ឱ្យទៅភាគី "ក"។ ភាគី "ខ" បានធ្វើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមនេះ ដោយមូលហេតុការជំនុំជម្រះលើកទី១មានកំហុសនីតិវិធីធ្ងន់ធ្ងរ ព្រោះក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមិនមានការសាកសួរសាក្សីទេ គ្រាន់តែជាដំណាក់កាលរៀបចំការអះអាងចំណុចវិវាទ និងភស្តុតាងតែប៉ុណ្ណោះ។

➢ ការលើកបណ្តឹងចោលរបស់សាលាដំបូងមានលក្ខណៈមិនត្រឹមត្រូវ និងមានភាពចាំបាច់ក្នុងការទាញហេតុផលថែមទៀត ជាស្ថានភាពដែលសាលាដំបូងបានលើកចោលពាក្យបណ្តឹងរបស់ដើមចោទដោយសាលក្រមមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ដោយមូលហេតុពាក្យបណ្តឹងរបស់ដើមចោទផ្ទុយនឹងច្បាប់មិនអាចកែតម្រូវបាន។[15] ដូចជាតុលាការយល់ថាខ្វះល័ក្ខខ័ណ្ឌនៃបណ្តឹង ប៉ុន្តែភាគីយល់ថាតុលាការវិនិច្ឆ័យទៅលើអង្គហេតុពុំទាន់គ្រប់គ្រាន់នោះទេ ភាគីអាចធ្វើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមនេះបាន។

➢ ការជំនុំជម្រះលើកទី១ មានកំហុសចំពោះសមត្ថកិច្ចផ្តាច់មុខ ជាស្ថានភាពដែលសាលាដំបូងបានចេញសាលក្រមចំពោះការទាមទារដែលមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ដោយសារច្បាប់កំណត់អំពី

[14] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៧៩ កថាខណ្ឌទី១ ចំណុច ខ

[15] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៨០ កថាខណ្ឌទី១

សមត្ថកិច្ចផ្តាច់មុខចំពោះករណីណាមួយ ដូចជាបណ្តឹងលែងលះ បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាព នៃបុត្តភាពជាអាទិ៍។ ឧទាហរណ៍៖ ដើមចោទជាភាគី "ក" បានដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់កូន ដោយយកភាគី "ខ" ជាចុងចម្លើយ។ ភាគី "ក" មានលំនៅឋាននៅខេត្តកំពង់ចាម ភាគី "ខ" មានវត្តមានចុងក្រោយ នៅប្រទេសកម្ពុជានៅក្នុងខេត្តសៀមរាប ប៉ុន្តែបានចាកចេញទៅបរទេសជាង១០ឆ្នាំមកហើយ។ សាលាដំបូង ខេត្តសៀមរាបបានចាត់ការពាក្យបណ្តឹងនេះ ហើយសម្រេចឱ្យទទួលស្គាល់ភាគី "ខ" ជាកូនរបស់ភាគី "ក"។ ភាគី "ខ" បានប្តឹងឧទ្ធរណ៍ចំពោះសាលក្រមនេះ ដោយមូលហេតុថាតុលាការខេត្តសៀមរាបមិនមានសមត្ថកិច្ច ក្នុងការចាត់ការបណ្តឹងនេះទេ។ ដោយចុងចម្លើយមិនមានលំនៅឋាន ឬ ទីសំណាក់នៅប្រទេសកម្ពុជាទេ ដូច្នេះត្រូវ ជាសមត្ថកិច្ចរបស់សាលាដំបូងរាជធានីភ្នំពេញ។[16]

## ២. កម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះ លើកទី១ របស់សាលាដំបូង។ ដូច្នេះកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ គឺសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១ ដែលមិនទាន់ចូលជាស្ថាពរ របស់សាលាដំបូងទាំងអស់ ប៉ុន្តែលើកលែងក្នុងករណីមួយចំនួន។[17]

សេចក្តីសម្រេចដែលមិនអាចប្តឹងឧទ្ធរណ៍បាន ពោលគឺមិនមែនជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍មានដូចជា៖

- ករណីគូភាគីបានព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍ ដោយរក្សាទុកនូវសិទ្ធិប្តឹងសាទុក្ខក្រោយពេល តុលាការបានចេញសាលក្រមចុងក្រោយដែលមិនទាន់ចូលជាស្ថាពររបស់សាលាដំបូង។ ការព្រមព្រៀងបែបនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ គ្រាន់តែព្រមព្រៀងផ្ទាល់មាត់មិនប្តឹងឧទ្ធរណ៍នោះ ក៏មិនអាចប្តឹងឧទ្ធរណ៍បានដែរ ដោយសារភាគីគិតថាចង់លះបង់ការវិនិច្ឆ័យទៅលើអង្គសេចក្តីលើកទី២ ដែលតុលាការនៃបណ្តឹងឧទ្ធរណ៍ជា តុលាការវិនិច្ឆ័យទៅលើអង្គសេចក្តីនោះផងដែរ។[18] ឧទាហរណ៍៖ ភាគី "ក" និងភាគី "ខ" បានព្រមព្រៀងគ្នា ប្តឹងសាទុក្ខឆ្លោះទៅតុលាការកំពូល ដោយធ្វើជាលាយលក្ខណ៍អក្សរ ក្នុងគោលបំណងលះបង់នូវការវិនិច្ឆ័យទៅ លើការជំនុំជម្រះលើកទី២ដោយតុលាការនៃបណ្តឹងឧទ្ធរណ៍ តែទាមទារការវិនិច្ឆ័យលើអង្គច្បាប់ដោយតុលាការ នៃបណ្តឹងសាទុក្ខ។
- ករណីសាលក្រមចុងក្រោយដែលវិនិច្ឆ័យទៅលើរឿងក្តីរដ្ឋប្បវេណី ឬ ពាណិជ្ជកម្ម ដែលមានតម្លៃ កម្មវត្ថុនៃបណ្តឹងមិនលើសពី ៥,000,000 (ប្រាំលាន) រៀល។ ឧទាហរណ៍៖ ភាគី "ក" បង្គាប់ឱ្យចុងចម្លើយ បង់ប្រាក់

---

[16] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៨១ និងមាត្រា១០

[17] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៦០ កថាខណ្ឌទី១

[18] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៦០ កថាខណ្ឌទី១ ចំណុច ក

ចំនួន ១,០០០ដុល្លារ ដែលជារឿងក្តីចេញសាលក្រមចុងក្រោយមកមានតម្លៃនៃកម្មវត្ថុតិចជាង៥លានរៀល ដូច្នេះសាលក្រមនេះមិនអាចប្តឹងឧទ្ធរណ៍បានទេ។

➢ សាលក្រមរបៀប ក៏មិនមែនជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ដែរ ព្រោះសាលក្រមរបៀបមិនមែនជាសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១ទេ។ ដូចការលើកឡើងខាងលើសាលក្រមរបៀបបពុំមានអានុភាពអ្វីផ្សេង ក្រៅពីអានុភាពដើម្បីត្រៀមចេញសាលក្រមចុងក្រោយក្នុងការជំនុំជម្រះ ហើយពុំមានអាជ្ញាអស់ជំនុំ ឬអានុភាពអនុវត្តទេ។[19]

➢ សេចក្តីសម្រេចរបស់សាលាដំបូងដែលមិនអាចធ្វើការឧបាស្រ័យតែម្តង គឺមិនមែនជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ទេ ដូចជាដីកាសម្រេចអំពីការតវ៉ាចំពោះការដឹកនាំនីតិវិធី ឬ ដីកាសម្រេចបង្គង់នីតិវិធីនៃបណ្តឹងជាអាទិ៍។

➢ សេចក្តីសម្រេចដែលអាចធ្វើឧបាស្រ័យដោយបណ្តឹងជំទាស់ គឺមិនអាចប្តឹងឧទ្ធរណ៍បានទេ ពោលមិនមែនជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ឬ ដីកាសម្រេចរបស់សាលាដំបូងមិនអាចធ្វើបណ្តឹងឧទ្ធរណ៍បានទេ។ ឧទាហរណ៍៖ ដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ឬ ដីកាសម្រេចលើកចោលពាក្យសុំឱ្យថែរក្សាការពារភស្តុតាងជាអាទិ៍។

➢ ចំពោះសេចក្តីសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្តី ដែលជាប់ជាមួយនឹងសាលក្រមចុងក្រោយ មិនអាចប្តឹងឧទ្ធរណ៍ដោយឯករាជ្យបានឡើយ។[20]

➢ ម៉្យាងទៀតក្នុងករណីដែលតុលាការនៃការជំនុំជម្រះលើកទី១ ចេញសាលក្រមកំបាំងមុខ បើភាគីបន្តការវិនិច្ឆ័យនៅតុលាការនៃការជំនុំជម្រះលើកទី១ ហើយភាគីមានល័ក្ខខ័ណ្ឌគ្រប់គ្រាន់ដើម្បីប្តឹងទាស់ដែលបានកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា២០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនអាចធ្វើបណ្តឹងឧទ្ធរណ៍បានទេ។ ប៉ុន្តែបើភាគីនោះលះបង់នូវផលប្រយោជន៍ដែលបន្តការវិនិច្ឆ័យនៅតុលាការនៃការជំនុំជម្រះលើកទី១ គឺអាចប្តឹងឧទ្ធរណ៍បាន ចំណែកឯភាគីដែលខ្វះល័ក្ខខ័ណ្ឌគ្រប់គ្រាន់ដើម្បីប្តឹងទាស់ ក៏អាចប្តឹងឧទ្ធរណ៍បានដែរ។ ចំពោះការប្តឹងទាស់លើសាលក្រមកំបាំងមុខបានចេញសាលក្រមចុងក្រោយរួចហើយ ក៏អាចប្តឹងឧទ្ធរណ៍បានដែរ។

## ផ្នែកទី៣៖ ល័ក្ខខ័ណ្ឌនៃបណ្តឹងឧទ្ធរណ៍

ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ចាំបាច់ត្រូវមានល័ក្ខខ័ណ្ឌជាក់លាក់ចំនួនពីរ គឺត្រូវដឹងថាអ្នកណាអាចមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍បាន បើភាគីដឹងថាខ្លួនមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ហើយ ត្រូវសិក្សាពីអំឡុងពេលក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ ដើម្បីឱ្យការប្តឹងឧទ្ធរណ៍ប្រព្រឹត្តទៅបានត្រឹមត្រូវ និងមានប្រសិទ្ធិភាពតាមដំណើរការនៃនីតិវិធី។

[19] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១៖ នីតិវិធីបណ្តឹង

[20] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៦១

## ១. អ្នកមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍

ជាទូទៅអ្នកដែលមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ គឺជាភាគីដែលមិនពេញចិត្តនឹងសាលក្រមចុងក្រោយដែលមិនទាន់ចូលជាស្ថាពររបស់សាលាដំបូង។ មានន័យថាបណ្តឹងឧទ្ធរណ៍អាចធ្វើឡើងដោយដើមចោទ ឬ ចុងចម្លើយដែលមិនពេញចិត្ត និងបាត់បង់នូវផលប្រយោជន៍ដោយសារសាលក្រមនៃការជំនុំជម្រះលើកទី១របស់សាលាដំបូង។ ជាគោលការណ៍ផលប្រយោជន៍ក្នុងការប្តឹងឧបាស្រ័យដែលត្រូវបានទទួលស្គាល់ នៅពេលដែលការទាមទាររបស់ដើមចោទ ឬ ចុងចម្លើយដែលចង់ប្តឹងឧបាស្រ័យមានទំហំធំជាងការទាមទាររបស់ភាគីនៅក្នុងសាលក្រមនៃការជំនុំជម្រះលើកទី១។ ម៉្យាងទៀតភាគីដែលបាត់បង់ផលប្រយោជន៍ គឺជាភាគីដែលចាញ់ក្តីទាំងស្រុង ឬ មួយផ្នែក ភាគីនោះមានសិទ្ធិក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ ហេតុនេះភាគីដែលឈ្នះក្តីទាំងស្រុងគ្មានផលប្រយោជន៍ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ទេ ពោលគឺគ្មានសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍។ ក្នុងករណីភាគីដែលឈ្នះក្តីទាំងស្រុងធ្វើបណ្តឹងឧទ្ធរណ៍ បណ្តឹងឧទ្ធរណ៍នោះនឹងត្រូវបានតុលាការលើកចោលដោយមូលហេតុផ្ទុយនឹងច្បាប់។[21]

ឧទាហរណ៍ទី១៖ ក្នុងពាក្យបណ្តឹងភាគី "ក" ប្តឹងភាគី "ខ" ឱ្យបង់ប្រាក់ចំនួន ១២,០០០ដុល្លារ។ សាលាដំបូងចេញសាលក្រម បង្គាប់ឱ្យចុងចម្លើយភាគី "ខ" បង់ប្រាក់ចំនួន ១២,០០០ដុល្លារ មកឱ្យដើមចោទភាគី "ក"។ ជាក់ស្តែងភាគី "ខ" ជាអ្នកបាត់បង់ផលប្រយោជន៍ដោយសាលក្រមរបស់សាលាដំបូង ហេតុនេះភាគី "ខ" មានផលប្រយោជន៍ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍។

ឧទាហរណ៍ទី២៖ ក្នុងពាក្យបណ្តឹងដដែលខាងលើ សាលាដំបូងចេញសាលក្រមដោយច្រានចោលការទាមទាររបស់ភាគី "ក"។ ដូច្នេះភាគី "ក" ជាអ្នកបាត់បង់ផលប្រយោជន៍ដោយសាលក្រមរបស់សាលាដំបូង ហេតុនេះភាគី "ក" មានផលប្រយោជន៍ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍។

ឧទាហរណ៍ទី៣៖ ក្នុងពាក្យបណ្តឹងដដែលខាងលើ សាលាដំបូងចេញសាលក្រម បង្គាប់ឱ្យចុងចម្លើយភាគី "ខ" បង់ប្រាក់ចំនួន ៨០០០ដុល្លារ មកឱ្យដើមចោទភាគី "ក"។ ក្នុងករណីនេះទាំងចុងចម្លើយ និងដើមចោទសុទ្ធតែជាភាគីដែលបាត់បង់ផលប្រយោជន៍ ហេតុនេះទាំងដើមចោទ និងចុងចម្លើយមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍។ ករណីនេះចុងចម្លើយធ្វើបណ្តឹងឧទ្ធរណ៍ ដើមចោទក៏ធ្វើបណ្តឹងឧទ្ធរណ៍បានដែរ ប៉ុន្តែបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងដោយដើមចោទហៅថា បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ។

សិទ្ធិប្តឹងឧទ្ធរណ៍មិនអាចកើតឡើង ក្នុងករណីដែលមានការព្រមព្រៀងរវាងភាគីទាំងសងខាងជាមុនថាមិនប្តឹងឧទ្ធរណ៍នោះទេ។ ការព្រមព្រៀងមិនប្តឹងឧទ្ធរណ៍នេះមានលក្ខណៈខុសពីការព្រមព្រៀងផ្លោះទៅតុលាការនៃបណ្តឹងសាទុក្ខ ត្រង់ថាសិទ្ធិធ្វើបណ្តឹងសាទុក្ខក៏មិនអាចប្តឹងបានដែរ។ ហេតុដូច្នេះប្រសិនបើការព្រមព្រៀងមិនប្តឹង

[21] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៦៨

ឧទ្ធរណ៍ត្រូវបានបង្កើតឡើងដោយមានសុពលភាព សាលក្រមនៃការជំនុំជម្រះលើកទី១នៅសាលាដំបូងនឹងត្រូវចូលជាស្ថាពរ នៅពេលដែលប្រកាសសាលក្រមនោះ។

សិទ្ធិប្ដឹងឧទ្ធរណ៍នឹងកើតឡើងដោយភាគីដែលមានផលប្រយោជន៍ តាមការប្រកាសសាលក្រមនៃការជំនុំជម្រះលើកទី១។ ប៉ុន្តែក្រោយពេលសិទ្ធិប្ដឹងឧទ្ធរណ៍កើតឡើង ភាគីដែលមានសិទ្ធិប្ដឹងឧទ្ធរណ៍ អាចលះបង់នូវសិទ្ធិនេះបានផងដែរ។ ការលះបង់សិទ្ធិប្ដឹងឧទ្ធរណ៍ត្រូវធ្វើឡើងតាមសេចក្ដីថ្លែងការណ៍។ ប្រសិនបើភាគីលះបង់សិទ្ធិប្ដឹងឧទ្ធរណ៍ក្រោយពេលដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ សេចក្ដីថ្លែងការណ៍អំពីការលះបង់សិទ្ធិប្ដឹងឧទ្ធរណ៍នោះ ត្រូវធ្វើឡើងជាមួយគ្នានឹងការដកពាក្យបណ្ដឹងឧទ្ធរណ៍។[22]

**២. អំឡុងពេលនៃការធ្វើបណ្ដឹងឧទ្ធរណ៍**

បណ្ដឹងឧទ្ធរណ៍ ត្រូវធ្វើឡើងក្នុងអំឡុងពេល ០១ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនៃការជំនុំជម្រះលើកទី១។ ឧទាហរណ៍៖ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ ភាគីដែលមានផលប្រយោជន៍ក្នុងការប្ដឹងឧទ្ធរណ៍បានទទួលលិខិតសាលក្រម។ ដូច្នេះថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ ជាអំឡុងពេលប្ដឹងឧទ្ធរណ៍ រីឯថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ ទៅជាថ្ងៃដែលផុតអំឡុងពេលប្ដឹងឧទ្ធរណ៍ហើយ។

ក្នុងករណីតុលាការលើកចោល ឬ ច្រានចោលបណ្ដឹងទាស់ បណ្ដឹងឧទ្ធរណ៍អាចធ្វើទៅបានដែលភាគីមានប្រយោជន៍ក្នុងការប្ដឹងឧទ្ធរណ៍ត្រូវធ្វើឡើងក្នុងអំឡុងពេល ០១ខែ គិតចាប់ពីថ្ងៃបានទទួលដំណឹងអំពីដីកាសម្រេចច្រានចោល ឬ លើកចោលនូវបណ្ដឹងទាស់នោះ។[23] ឧទាហរណ៍៖ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២១ ភាគីទទួលសាលក្រមកំបាំងមុខ ក្នុងរយៈពេល១៤ថ្ងៃបានដាក់ពាក្យបណ្ដឹងទាស់ នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២១។ បន្ទាប់មកភាគីខាងលើបានទទួលដំណឹងអំពីដីកាសម្រេចច្រានចោលបណ្ដឹងទាស់ ដូចនេះចាប់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១ ជាអំឡុងពេលប្ដឹងឧទ្ធរណ៍ រីឯថ្ងៃទី០២ ខែមេសា ឆ្នាំ២០២១ ទៅជាថ្ងៃដែលផុតអំឡុងពេលប្ដឹងឧទ្ធរណ៍ហើយ។

ប្រសិនបើករណីតុលាការចេញសាលក្រមកំបាំងមុខ ហើយភាគីមិនប្ដឹងទាស់ បណ្ដឹងឧទ្ធរណ៍ត្រូវធ្វើឡើងក្នុងអំឡុង០១ខែ គិតចាប់ពីថ្ងៃផុតសិទ្ធិប្ដឹងទាស់។

ជាគោលការណ៍អំឡុងពេលធ្វើបណ្ដឹងឧទ្ធរណ៍មិនអាចពន្យារពេលបានឡើយ ប៉ុន្តែក្នុងករណីភាគីដែលមានសិទ្ធិប្ដឹងឧទ្ធរណ៍មិនអាចប្ដឹងឧទ្ធរណ៍បានដោយមូលហេតុមិនមែនជាកំហុសរបស់ខ្លួន ភាគីនោះអាចបំពេញនូវសកម្មភាពបណ្ដឹងពេលក្រោយបានក្នុងអំឡុង ០១សប្ដាហ៍ បន្ទាប់ពីមូលហេតុនោះបានរលត់ ប្រសិនបើភាគី

[22] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៦៣

[23] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៦៤ កថាខណ្ឌទី១

នៅបរទេស អំឡុងពេលនោះមានចំនួន០២ខែ។ ឧទាហរណ៍៖ ចុងចម្លើយភាគី "ខ" ទទួលសាលក្រមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ ដោយមានសិទ្ធិប្តឹងឧទ្ធរណ៍រយៈពេល ០១ខែ គិតចាប់ពីថ្ងៃទទួលបានសាលក្រម។ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ ជាថ្ងៃចុងក្រោយនៃសិទ្ធិប្តឹងឧទ្ធរណ៍ ភាគ "ខ" បានដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ប៉ុន្តែនៅថ្ងៃនោះ មានបាតុកម្ម ហើយបិទតុលាការនាំឱ្យមិនអាចទទួលពាក្យបណ្តឹងបាន ក្នុងករណីនេះអំឡុងពេលប្តឹងឧទ្ធរណ៍មាន មួយសប្តាហ៍គិតពីថ្ងៃដែលកើតហេតុដែលនាំឱ្យឧកខាននោះបានរលត់ និងភាគីត្រូវធ្វើការអះអាង និងបញ្ជាក់ ដោយភស្តុតាងថាការមិនអាចធ្វើបណ្តឹងឧទ្ធរណ៍ក្នុងអំឡុងពេលកំណត់នោះបាន មិនមែនដោយសារកំហុសរបស់ ខ្លួនទេជាការគ្រប់គ្រាន់។[24]

ប្រសិនបើអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍កន្លងហួស ភាគីដែលមានសិទ្ធិប្តឹងឧទ្ធរណ៍ នឹងត្រូវបានបាត់បង់ សិទ្ធិនោះ។ ហេតុដូច្នេះបើពាក្យបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ក្រោយអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍កន្លងហួស បណ្តឹងឧទ្ធរណ៍នោះនឹងត្រូវបានលើកចោលដោយសាលដីកា ដោយសារបណ្តឹងឧទ្ធរណ៍នោះមានលក្ខណៈផ្ទុយ នឹងច្បាប់។[25] ម្យ៉ាងទៀតក្រោយពេលសាលក្រមនៃការជំនុំជម្រះលើកទី១ត្រូវបានប្រកាស ទោះបីជាមិនទាន់ ទទួលការបញ្ជូនសាលក្រមក៏ដោយ ក៏ភាគីអាចប្តឹងឧទ្ធរណ៍ដោយស្របច្បាប់បានដែរ។ បានសេចក្តីថាទោះបីជា សិទ្ធិប្តឹងឧទ្ធរណ៍ត្រូវបានរលត់ក៏ដោយក៏នៅតែអាចប្តឹងឧទ្ធរណ៍បានដែរ បណ្តឹងនេះហៅថា បណ្តឹងឧទ្ធរណ៍ បន្ទាប់បន្សំ ដែលជាបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំធ្វើឡើងដោយឯករាជ្យ។[26]

**ផ្នែកទី៤៖ របៀបធ្វើបណ្តឹងឧទ្ធរណ៍**

ពាក្យបណ្តឹងឧទ្ធរណ៍ត្រូវសរសេរជាលាយលក្ខណ៍អក្សរ ដោយត្រូវបញ្ជាក់អំពី៖

- អត្តសញ្ញាណរបស់ភាគី
- សញ្ញាណនៃសាលក្រមនៃការជំនុំជម្រះលើកទី១
- សេចក្តីដែលប្តឹងចំពោះសាលក្រមនោះ
- មូលហេតុនៃការទាមទារឱ្យលុបចោល ឬ ផ្លាស់ប្តូរនូវសាលក្រម។

នៅក្នុងពាក្យបណ្តឹងឧទ្ធរណ៍ ត្រូវសរសេរអំពីឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ភាគី និងអ្នក តំណាងដែលច្បាប់បានកំណត់ ឧទាហរណ៍៖ ខ្ញុំបាទឈ្មោះ "ខ" មានអាសយដ្ឋាននៅផ្ទះលេខ០១ ផ្លូវ000 រាជធានីភ្នំពេញ មានមេធាវីតំណាងដោយអាណត្តិឈ្មោះ "គ" អត្តលេខ៖000 ជាមេធាវីនៃក្រុមមេធាវី L.A.W

[24] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៦៤ កថាខណ្ឌទី២

[25] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៦៨

[26] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៧០

មានការិយាល័យទីតាំងនៅភ្នំពេញ។ បន្ទាប់មកភាគីត្រូវសរសេរនូវសញ្ញាណសាលក្រមនៃការជំនុំជម្រះលើកទី១ ឧទាហរណ៍៖ សាលក្រមរដ្ឋប្បវេណីលេខ១៦៨ "ក" ស.ដ.រ.វ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។ ចំណុចសំខាន់ដែលត្រូវសរសេរមួយទៀត គឺសេចក្តីដែលប្តឹងឧបាស្រ័យចំពោះសាលក្រម ឧទាហរណ៍៖ សាលក្រមខាងលើបង្គាប់ឱ្យដើមចោទ "ក" លែងលះចុងចម្លើយ "ខ" និងបង្គាប់ឱ្យចុងចម្លើយ "ខ" ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដី L មួយផ្នែកឱ្យដើមចោទ "ក" ដោយមូលហេតុបែងចែកទ្រព្យរួម។ ដូច្នេះសេចក្តីប្តឹងឧទ្ធរណ៍ គឺប្តឹងឧទ្ធរណ៍នឹងសេចក្តីសម្រេចបញ្ចប់ត្រង់ចំណុចទី២ ពោលគឺចំណុចបង្គាប់ឱ្យធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដី L មួយផ្នែកឱ្យដើមចោទ "ក" នៃសាលក្រមដើម។ ម្យ៉ាងទៀតជាការល្អ នៅក្នុងពាក្យបណ្តឹងឧទ្ធរណ៍ បើសរសេរអំពីមូលហេតុដែលទាមទារឱ្យលុបចោល ឬ ឱ្យផ្លាស់ប្តូរនូវសាលក្រមនៃការជំនុំជម្រះលើកទី១ ឧទាហរណ៍៖ សាលក្រមនៃការជំនុំជម្រះលើកទី១ មានកំហុសនីតិវិធីធ្ងន់ធ្ងរ ឬ សាលក្រមនៃការជំនុំជម្រះលើកទី១មិនត្រឹមត្រូវ។[27] ប្រសិនបើមិនបានសរសេរអំពីមូលហេតុនៃការទាមទារនោះទេ អ្នកធ្វើបណ្តឹងឧទ្ធរណ៍ត្រូវដាក់លិខិតជាលាយលក្ខណ៍អក្សរដែលសរសេរអំពីមូលហេតុនោះ ក្នុងអំឡុងពេល៣០ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍នេះ។[28] ដោយឡែកទោះបីអ្នកធ្វើបណ្តឹងឧទ្ធរណ៍មិនដាក់លិខិតនោះក៏ដោយ បណ្តឹងឧទ្ធរណ៍នោះមិនចាត់ទុកថាផ្ទុយនឹងច្បាប់ឡើយ ហើយក៏មិនត្រូវបានលើកបណ្តឹងចោលនោះទេ ព្រោះមូលហេតុនៃបណ្តឹងមិនមែនជាចំណុចចាំបាច់ ដែលត្រូវសរសេរក្នុងពាក្យបណ្តឹងឧទ្ធរណ៍នោះឡើយ ព្រោះតុលាការនៃបណ្តឹងឧទ្ធរណ៍វិនិច្ឆ័យលើអង្គហេតុ និងអង្គច្បាប់ដែលខុសនីតិវិធីប៉ុណ្ណោះ។ ដូច្នេះពាក្យបណ្តឹងឧទ្ធរណ៍នេះត្រូវដាក់ទៅតុលាការដើម ដែលជាតុលាការនៃការជំនុំជម្រះលើកទី១ ឬ សាលាដំបូង។ ពេលដែលបានទទួលពាក្យបណ្តឹងឧទ្ធរណ៍នេះ តុលាការនៃការជំនុំជម្រះលើកទី១ ត្រូវផ្ញើពាក្យបណ្តឹងឧទ្ធរណ៍ និងសំណុំរឿងទៅតុលាការនៃបណ្តឹងឧទ្ធរណ៍ឱ្យបានឆាប់រហ័ស។[29]

**ផ្នែកទី៥៖ អានុភាពនៃពាក្យបណ្តឹងឧទ្ធរណ៍**

ការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ឱ្យបានទាន់ពេលវេលា គឺមានអានុភាពទៅលើសាលក្រមដើមដែលអាចបង្អាក់នូវការចូលជាស្ថាពរនៃសាក្រមនោះបាន។ ហើយដំណើរការនៃការជម្រះក្តីនៅតុលាការដើមត្រូវបានផ្ទេរមកឱ្យតុលាការនៃបណ្តឹងឧទ្ធរណ៍ ដែលគេឱ្យឈ្មោះថា អានុភាពនៃការផ្ទេរការជំនុំជម្រះក្តីដោយបណ្តឹងឧទ្ធរណ៍ ដែលតុលាការនៃបណ្តឹងឧទ្ធរណ៍មានសិទ្ធិពេញលេញក្នុងការវិនិច្ឆ័យនៃការទាមទារនោះ។ ជួនកាលភាគីដែលធ្វើ

[27] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៦៥ កថាខណ្ឌទី២

[28] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៦៥ កថាខណ្ឌទី៣

[29] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៦៥ កថាខណ្ឌទី១

បណ្តឹងឧទ្ធរណ៍មិនសុខចិត្តលើសាលក្រមតែផ្នែកណាមួយនៃសាលក្រមប៉ុណ្ណោះ ប៉ុន្តែអានុភាពបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រមទាំងមូលតែម្តង ដែលមិនមានអានុភាពក្នុងការអនុវត្តសាលក្រមឡើយ នេះហៅថាអានុភាពអវិភាគនៃបណ្តឹងឧទ្ធរណ៍។

**១. អានុភាពបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រម**

ពេលដែលបណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើក្នុងអំឡុងពេលដែលបានកំណត់ ទោះជាអំឡុងពេលដែលកំណត់នោះបានកន្លងផុតទៅហើយក៏ដោយ ក៏សាលក្រមដើមនៃការជំនុំជម្រះលើកទី១មិនទាន់ចូលជាស្ថាពរដែរ នេះគេហៅថាអានុភាពបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រម។[30] ដូច្នេះអានុភាពបង្អាក់ការចូលជាស្ថាពរនៃសាលក្រមជាស្ថានភាពដែលរារាំងការចូលជាស្ថាពរនៃសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១ ដោយសារអានុភាពនៃការដាក់ពាក្យបណ្តឹងឧទ្ធរណ៍តាមការកំណត់របស់ច្បាប់។ ឧទាហរណ៍៖ ភាគីបានទទួលសាលក្រមនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ ហើយភាគីនោះដាក់ពាក្យបណ្តឹងឧទ្ធរណ៍បានហើយនៅក្នុងអំឡុងពេលប្តឹងឧទ្ធរណ៍ ចាប់ពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃផុតកំណត់ប្តឹងឧទ្ធរណ៍ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០ ពេលនោះនៅថ្ងៃផុតកំណត់ប្តឹងឧទ្ធរណ៍នឹងមានការបង្អាក់ការចូលជាស្ថាពរនៃសាលក្រមនៃការជំនុំជម្រះលើកទី១ របស់សាលដំបូង។

ប៉ុន្តែក្នុងករណីសាលក្រមដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន សាលក្រមនោះមានអានុភាពអនុវត្ត ទោះបីជាមានបណ្តឹងឧទ្ធរណ៍ក៏ដោយ។ បានសេចក្តីថាមានអានុភាពអនុវត្តដោយមិនរង់ចាំការចូលជាស្ថាពរនៃសាលក្រមឡើយ។[31]

**២. អានុភាពនៃការផ្ទេរការជំនុំជម្រះក្តី**

បណ្តឹងឧទ្ធរណ៍ ដែលបានធ្វើឡើងក្នុងអំឡុងពេលបានកំណត់មានអានុភាពផ្ទេរការទាមទារពីសាលាដំបូងទៅសាលាឧទ្ធរណ៍ មានន័យថា វិវាទរវាងដើមចោទ និងចុងចម្លើយនៅតុលាការនៃការជំនុំជម្រះក្តីលើកទី១ មិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការនៃការជំនុំជម្រះលើកទី១ទៀតទេ ពោលគឺស្ថិតក្រោមសមត្ថកិច្ចរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍។ ដូច្នេះដោយសារអានុភាពនេះ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវវិនិច្ឆ័យអំពីការទាមទារនោះ។ ឧទាហរណ៍៖ ដើមចោទ "ក" បានប្តឹង "ខ" ឱ្យបង់ប្រាក់ចំនួន ១០,០០០ដុល្លារ មកឱ្យខ្លួន សាលាដំបូងសម្រេចទទួលស្គាល់ការទាមទាររបស់ដើមចោទ។ ចុងចម្លើយ "ខ" បានប្តឹងឧទ្ធរណ៍ចំពោះសាលក្រមរបស់សាលាដំបូងដោយយល់ឃើញថាសាលក្រមនេះមិនត្រឹមត្រូវ។ ក្នុងករណីនេះការសម្រេចអំពីវិវាទនៃសិទ្ធិទាមទារប្រាក់ចំនួន ១០,០០០ដុល្លារ ត្រូវផ្ទេរពីសមត្ថកិច្ចរបស់តុលាការជាន់ទាបទៅតុលាការជាន់ខ្ពស់ ពោលគឺពីសាលាដំបូងទៅតុលាការនៃបណ្តឹងឧទ្ធរណ៍។

---

[30] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៩៣ កថាខណ្ឌទី២

[31] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៩៦

### ៣. អានុភាពអវិភាគនៃបណ្ដឹងឧទ្ធរណ៍

បណ្ដឹងឧទ្ធរណ៍ ដែលបានធ្វើឡើងក្នុងអំឡុងពេលដែលច្បាប់បានកំណត់ មានអានុភាពបង្អាក់ការចូលជាស្ថាពរនៃសាលក្រមចុងក្រោយរបស់សាលាដំបូងទាំងមូល ទោះបីជាបណ្ដឹងឧទ្ធរណ៍ធ្វើឡើងចំពោះតែផ្នែកណាមួយនៃសាលក្រមចុងក្រោយរបស់សាលាដំបូងក៏ដោយ។

ឧទាហរណ៍៖ សាលក្រមរបស់សាលាដំបូងលេខ០១ "ក" ស.ព.រ.វ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារ៖

១. ដើមចោទ "ក" និងចុងចម្លើយ "ខ" លែងលះគ្នា។

២. បង្គាប់ឱ្យចុងចម្លើយ "ខ" ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដី L មួយផ្នែកមកឱ្យដើមចោទ "ក" ដោយមូលហេតុបែងចែកទ្រព្យសម្បត្តិរួម។

៣. ដើមចោទ "ក" ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ "គ"។

៤. បង្គាប់ឱ្យចុងចម្លើយ "ខ" ប្រគល់កូន "គ" មកឱ្យដើមចោទ "ក"។

ចុងចម្លើយ "ខ" ប្ដឹងឧទ្ធរណ៍ចំណុចទី២ ទី៣ និងទី៤ ប៉ុន្តែផ្នែកដែលមិនប្ដឹងឧទ្ធរណ៍ និងផ្នែកដែលប្ដឹងឧទ្ធរណ៍គឺត្រូវបង្អាក់ការចូលជាស្ថាពរទាំងមូលតែម្តង។ ដូច្នេះចុងចម្លើយ "ខ" ប្ដឹងឧទ្ធរណ៍ត្រង់ចំណុចទី២ ទី៣ និងទី៤ នាំឱ្យសាលក្រមទាំងមូលមិនចូលជាស្ថាពរ ហេតុនេះទោះបីចំណុចទី១ ចុងចម្លើយ "ខ" មិនបានប្ដឹងក៏ដោយ ក៏មិនចូលជាស្ថាពរដែរ នោះដើមចោទក៏មិនអាចធ្វើការអនុវត្តដោយបង្ខំដោយផ្អែកលើសាលក្រមដើម ឬប្រកាសឱ្យធ្វើការអនុវត្តជាបណ្ដោះអាសន្នទៅលើផ្នែកដែលខ្លួនឈ្នះបានឡើយ។

សរុបមកមានន័យថា ថ្វីបើដើមបណ្ដឹងឧទ្ធរណ៍ប្ដឹងឧបាស្រ័យតែផ្នែកណាមួយនៃសាលក្រមដើមក៏ដោយ ក៏មានអានុភាពនៃការបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រម និងមានអានុភាពនៃការផ្ទេរការជម្រះក្តីកើតមានឡើងដែរ ចំពោះការទាមទារទាំងអស់នៅក្នុងសាលក្រមដើម នេះហៅថា អានុភាពអវិភាគភាពនៃបណ្ដឹងឧទ្ធរណ៍។

ផ្ទុយមកវិញក្នុងករណីតុលាការបានចេញសាលក្រម ហើយភាគីបានព្រមព្រៀងគ្នាមិនប្ដឹងឧទ្ធរណ៍ចំពោះផ្នែកណាមួយនៃការទាមទារ ឬ ភាគីទាំងសងខាងលះបង់សិទ្ធិប្ដឹងឧទ្ធរណ៍ និងសិទ្ធិប្ដឹងឧទ្ធរណ៍បន្ទាប់បន្សំចំពោះផ្នែកណាមួយនៃការទាមទារ នាំឱ្យផ្នែកនោះនៃសាលក្រមចុងក្រោយត្រូវចូលជាស្ថាពរ។

ឧទាហរណ៍៖ ដើមចោទ "ក" ប្ដឹងចុងចម្លើយ "ខ" ទៅសាលាដំបូង ដែលមានខ្លឹមសារ៖

១. បង្គាប់ឱ្យចុងចម្លើយ "ខ" បង់ប្រាក់ ១០,០០០ដុល្លារ ឱ្យដើមចោទ "ក"។

២. បង្គាប់ឱ្យចុងចម្លើយ "ខ" បង់ប្រាក់ក្នុងអត្រា១០%ក្នុងមួយឆ្នាំនៃទឹកប្រាក់ ១០,០០០ដុល្លារ គិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ រហូតសងរួច។

៣. បង្គាប់ឱ្យចុងចម្លើយ "ខ" បង់ប្រាក់ ៥,០០០ដុល្លារ មកឱ្យដើមចោទ "ក"។

តុលាការចេញសេចក្តីសម្រេចបញ្ចប់៖

១. បង្គាប់ឱ្យចុងចម្លើយ "ខ" បង់ប្រាក់ ៨,០០០ដុល្លារ ឱ្យដើមចោទ "ក"។

២. បង្គាប់ឱ្យចុងចម្លើយ "ខ" បង់ប្រាក់ក្នុងអត្រា១០%ក្នុងមួយឆ្នាំនៃទឹកប្រាក់ ៨,០០០ដុល្លារ គិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ រហូតសងរួច។

៣. បង្គាប់ឱ្យចុងចម្លើយ "ខ" បង់ប្រាក់ ៥,០០០ដុល្លារ មកឱ្យដើមចោទ "ក"។

ដើមចោទ និងចុងចម្លើយបានព្រមព្រៀងមិនធ្វើបណ្តឹងឧទ្ធរណ៍ និងបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំចំពោះចំណុចទី១ និងទី២ នៃសេចក្តីសម្រេចបញ្ចប់របស់សាលក្រមនៃការជំនុំជម្រះលើកទី១ទេ និងត្រូវចូលជាស្ថាពរដោយមិនរង់ចាំផុតអំឡុងពេលនៃការប្តឹងឧទ្ធរណ៍ទេ។ ដូច្នេះដើមចោទអាចដាក់ពាក្យសុំទៅតុលាការនៃបណ្តឹងឧទ្ធរណ៍ ឱ្យប្រកាសការអនុវត្តជាបណ្តោះអាសន្នតែចំណុចទី១ និងទី២ នៃសេចក្តីសម្រេចបញ្ចប់របស់សាលក្រមនៃការជំនុំជម្រះលើកទី១។ ហើយចំពោះចំណុចទី៣វិញ ចុងចម្លើយអាចប្តឹងឧទ្ធរណ៍បាន។

ហេតុនេះការព្រមព្រៀងមិនប្តឹងឧទ្ធរណ៍ និងប្តឹងឧទ្ធរណ៍បន្ទាប់បន្សំនូវចំណុចណាមួយ ចំណុចដែលបានព្រមព្រៀងនោះនឹងចូលជាស្ថាពរ ទោះបីជាចំណុចផ្សេងទៀត ភាគីបានប្តឹងឧទ្ធរណ៍ក៏ដោយ។

## ផ្នែកទី៦៖ បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ

បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ គឺជាការធ្វើឧបាស្រ័យដោយភ្ជាប់ជាមួយនឹងបណ្តឹងឧទ្ធរណ៍របស់ភាគីម្ខាងទៀតចំពោះចំណុចដែលចុងបណ្តឹងឧទ្ធរណ៍បាត់បង់ផលប្រយោជន៍។ ឧទាហរណ៍៖ ដើមចោទ "ក" ទាមទារទៅសាលាដំបូងឱ្យចុងចម្លើយ "ខ" បង់ប្រាក់ ១០,០០០ដុល្លារ ហើយតុលាការបានសម្រេចឱ្យ ៩,០០០ដុល្លារ ក្នុងករណីនេះដើមចោទ "ក" អាចប្តឹងឧទ្ធរណ៍បានចំពោះសាលក្រមនេះ ប៉ុន្តែដើមចោទ "ក" មិនបានធ្វើបណ្តឹងឧទ្ធរណ៍ទេ។ បន្ទាប់មកបើចុងចម្លើយ "ខ" ធ្វើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមនេះ ពេលនោះដើមចោទក៏បានធ្វើបណ្តឹងឧទ្ធរណ៍ដែរ ដែលបណ្តឹងឧទ្ធរណ៍របស់ដើមចោទហៅថា បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ។ បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ អាចធ្វើបាននៅគ្រប់ដំណាក់កាលនៃនីតិវិធីបណ្តឹងឧទ្ធរណ៍ ប៉ុន្តែត្រូវធ្វើនៅមុនពេលការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍បានបញ្ចប់។[32] មានន័យថាទោះបីជាសិទ្ធិប្តឹងឧទ្ធរណ៍ត្រូវបានរលត់ក៏ដោយ (ហួសអំឡុងពេលប្តឹងឧទ្ធរណ៍) ក៏ចុងបណ្តឹងឧទ្ធរណ៍អាចធ្វើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំបានដែរ។

អំឡុងពេលធ្វើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ដូចគ្នានឹងបណ្តឹងឧទ្ធរណ៍ដែរពោលគឺ ០១ខែ គិតចាប់ពីថ្ងៃទទួលបានលិខិតសាលក្រម ឬ ថ្ងៃដែលបានជូនដំណឹងអំពីដីកាសម្រេចច្រានចោល ឬ លើកចោលនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ចំពោះអំឡុងពេល ០១ខែ មិនអាចពន្យារពេលបានទេ។ ក្នុងករណីបណ្តឹងឧទ្ធរណ៍

[32] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៧០ កថាខណ្ឌទី១

ត្រូវបាត់បង់អានុភាព នៅពេលដែលតុលាការនៃបណ្តឹងឧទ្ធរណ៍លើកចោលបណ្តឹងឧទ្ធរណ៍ ឬ ដើមបណ្តឹងឧទ្ធរណ៍បានដកពាក្យបណ្តឹង បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនឹងបាត់បង់អានុភាព ប្រសិនបើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះធ្វើឡើងហួសអំឡុងពេលប្តឹងឧទ្ធរណ៍។ ហេតុនេះបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំត្រូវបានលើកចោលដោយសារផ្ទុយនឹងច្បាប់។

ប៉ុន្តែក្នុងករណីបើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះធ្វើឡើងមិនហួសអំឡុងពេលប្តឹងឧទ្ធរណ៍ និងមានល័ក្ខខ័ណ្ឌនៃបណ្តឹងឧទ្ធរណ៍គ្រប់គ្រាន់ ករណីនេះហៅថាបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំបានធ្វើឡើងដោយឯករាជ្យ ហើយទោះបីជាតុលាការលើកចោល ឬ ដើមបណ្តឹងឧទ្ធរណ៍ដកពាក្យបណ្តឹងឧទ្ធរណ៍ក៏ដោយ ក៏មិនប៉ះពាល់ ឬបាត់បង់អានុភាពដល់បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំដែរ ក្នុងករណីនេះបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនឹងក្លាយជាបណ្តឹងឧទ្ធរណ៍ឯករាជ្យ ហើយតុលាការនៃណ្តឹងឧទ្ធរណ៍នឹងបន្តចាត់ការលើបណ្តឹងឧទ្ធរណ៍នោះ។[33]

ចំពោះរបៀបធ្វើពាក្យបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ និងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ រមែងត្រូវអនុលោមទៅតាមបញ្ញត្តិនៃបណ្តឹងឧទ្ធរណ៍ ពោលគឺត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ។[34] ហេតុនេះដើមបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ (ចុងបណ្តឹងឧទ្ធរណ៍) ត្រូវដាក់លិខិតពាក្យបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំទៅតុលាការដើម បន្ទាប់មកបញ្ជូនទៅតុលាការនៃបណ្តឹងឧទ្ធរណ៍ដើម្បីពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះ ហើយត្រូវបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះទៅចុងបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ។

## ផ្នែកទី៧៖ នីតិវិធីនៃបណ្តឹងឧទ្ធរណ៍

យើងបានសិក្សារួចមកហើយអំពីសញ្ញាណទូទៅ ប្រភេទនៃបណ្តឹងឧទ្ធរណ៍ដែលមានកម្មវត្ថុ ល័ក្ខខ័ណ្ឌ និងរបៀបធ្វើបណ្តឹងឧទ្ធរណ៍ ព្រមទាំងអានុភាពនៃពាក្យបណ្តឹងឧទ្ធរណ៍ និងបន្ថែមនូវបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ។ ហើយក្នុងផ្នែកនេះនឹងមានការបកស្រាយអំពីដំណើរនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ដែលមានដូចជា ការទទួលពាក្យបណ្តឹងឧទ្ធរណ៍ រួចមកមានការពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍ ការបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍ និងការកំណត់កាលបរិច្ឆេទនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់មុននឹងធ្វើការជំនុំជម្រះ។

### ១. ការទទួលពាក្យបណ្តឹងឧទ្ធរណ៍

ភាគីដែលខូចប្រយោជន៍អំពីសេចក្តីសម្រេចរបស់តុលាការនៃការជំនុំជម្រះលើកទី១ គឺតម្រូវឱ្យដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅតុលាការដើមដែលជាសាលាដំបូង។ តុលាការដើមមានតួនាទីទទួលពាក្យបណ្តឹងឧទ្ធរណ៍ និងបញ្ជូនសំណុំរឿង និងឯកសារដែលពាក់ព័ន្ធទាំងនេះទៅតុលាការនៃបណ្តឹងឧទ្ធរណ៍។ យ៉ាងណាមិញតុលាការ

[33] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៧០ កថាខណ្ឌទី២

[34] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៧០ កថាខណ្ឌទី៣

ដើមពុំមានសមត្ថកិច្ចពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍ទេ គ្រាន់តែជាតុលាការដែលទទួលយកពាក្យបណ្តឹងឧទ្ធរណ៍របស់ភាគីប៉ុណ្ណោះ ប៉ុន្តែអាចពិនិត្យត្រឹមតែលើល័ក្ខខ័ណ្ឌនៃបណ្តឹងឧទ្ធរណ៍ អំឡុងពេលនៃការធ្វើបណ្តឹងឧទ្ធរណ៍ ការបង់ពន្ធដាក់ពាក្យសុំជាអាទិ៍នោះ មុនធ្វើការបញ្ជូនពាក្យបណ្តឹងនោះជាមួយនឹងសំណុំរឿងក្តីដែលពាក់ព័ន្ធទៅតុលាការនៃបណ្តឹងឧទ្ធរណ៍តែប៉ុណ្ណោះ។

### ២. ការពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍

នៅពេលតុលាការនៃបណ្តឹងឧទ្ធរណ៍បានទទួលពាក្យបណ្តឹងហើយ គឺត្រូវពិនិត្យទៅលើពាក្យបណ្តឹងឧទ្ធរណ៍នោះនូវចំណុចជាលក្ខណៈទម្រង់ចំនួនបួន ដូចដែលបានរៀបរាប់ក្នុងចំណុចនៃរបៀបធ្វើបណ្តឹងឧទ្ធរណ៍ ប៉ុន្តែមានល័ក្ខខ័ណ្ឌមួយទៀតគឺការបង់ប្រាក់ប្រដាប់ក្តីដែលបង់នៅពេលដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅតុលាការ។ ដូច្នេះតុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវពិនិត្យចំណុចជាលក្ខណៈទម្រង់ចំនួនបួន មានដូចជា៖

- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ភាគី និងអ្នកតំណាងដែលច្បាប់បានកំណត់
- សញ្ញាណសាលក្រមនៃការជំនុំជម្រះលើកទី១
- សេចក្តីដែលប្តឹងឧទ្ធរណ៍ចំពោះសាលក្រមនោះ និងមូលហេតុនៃការទាមទារ
- ការបង់ប្រាក់ប្រដាប់ក្តី។[35]

ក្នុងករណីតុលាការនៃបណ្តឹងឧទ្ធរណ៍ពិនិត្យទៅឃើញថាមានចំណុចខ្វះខាត តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវបង្គាប់ឱ្យភាគីធ្វើការកែតម្រូវនូវចំណុចខ្វះខាតទាំងនោះ ក្នុងកំឡុងពេលសមរម្យមួយ។ បើទោះជាមានការបង្គាប់ឱ្យកែតម្រូវក៏ដោយ តែដើមបណ្តឹងឧទ្ធរណ៍មិនព្រមកែតម្រូវទៅតុលាការនៃបណ្តឹងឧទ្ធរណ៍ទេ ពោលគឺត្រូវលើកចោលពាក្យបណ្តឹងឧទ្ធរណ៍នោះដោយដីកាសម្រេច (ដីកាសម្រេចនេះអាចប្តឹងជំទាស់បាន ដែលមានបញ្ញត្តិក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៦៦ កថាខណ្ឌទី៣)។ ចំណុចនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលដើមបណ្តឹងឧទ្ធរណ៍មិនបានបង់ពន្ធសម្រាប់ដាក់ពាក្យបណ្តឹងឧទ្ធរណ៍នោះផងដែរ។[36] ចំពោះការបង់ពន្ធដាក់ពាក្យបណ្តឹងឧទ្ធរណ៍ និងបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំពន្ធដាក់ពាក្យសុំត្រូវគណនាទៅតាមតម្លៃកម្មវត្ថុនៃបណ្តឹងដែលមានចំនួន ១,៥ ដង នៃពន្ធដាក់ពាក្យសុំនៅតុលាការជាន់ទាប។

### ៣. ការបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍

ប្រសិនបើពាក្យបណ្តឹងឧទ្ធរណ៍ត្រឹមត្រូវតាមទម្រង់ច្បាប់ ក្រឡាបញ្ជីត្រូវបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍នោះទៅឱ្យចុងបណ្តឹងឧទ្ធរណ៍ ដើម្បីឱ្យចុងបណ្តឹងឧទ្ធរណ៍បានដឹង និងត្រៀមខ្លួនក្នុងការឆ្លើយតបជាមួយនឹងបណ្តឹង

---

[35] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ គន្ថីទី១ ជំពូកទី៤

[36] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៦១ កថាខណ្ឌទី៤

ឧទ្ធរណ៍របស់ដើមបណ្ដឹងឧទ្ធរណ៍។ ក្នុងករណីដែលមិនអាចបញ្ជូនពាក្យបណ្ដឹងឧទ្ធរណ៍ (រាប់បញ្ចូលនូវករណីដែលភាគីមិនបានបង់ប្រាក់ប្រដាប់ក្ដីដែលចាំបាច់ដើម្បីបញ្ជូនពាក្យបណ្ដឹងឧទ្ធរណ៍) ត្រូវអនុលោមទៅតាមករណីដែលពាក្យបណ្ដឹងឧទ្ធរណ៍មិនត្រឹមត្រូវតាមទម្រង់ច្បាប់ ត្រង់មាត្រា២៦៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**៤. ការកំណត់កាលបរិច្ឆេទនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់**

បន្ទាប់ពីទទួលពាក្យបណ្ដឹងឧទ្ធរណ៍ និងពិនិត្យឃើញថាបណ្ដឹងនោះធ្វើឡើងត្រឹមត្រូវហើយ តុលាការនៃបណ្ដឹងឧទ្ធរណ៍ ត្រូវធ្វើការកំណត់នូវកាលបរិច្ឆេទសម្រាប់ធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានឆាប់រហ័ស និងធ្វើការកោះហៅគូភាគីឱ្យចូលរួម។ គួរបញ្ជាក់ផងដែរថាបណ្ដឹងឧទ្ធរណ៍ធ្វើឡើងដោយផ្អែកលើសាលក្រមនៃការជំនុំជម្រះលើកទី១ មិនត្រឹមត្រូវ ឬ ផ្ទុយនីតិវិធីច្បាប់ធ្ងន់ធ្ងរ ឬ ការលើកបណ្ដឹងចោលរបស់សាលាដំបូងមានលក្ខណៈមិនត្រឹមត្រូវ និងមានភាពចាំបាច់ក្នុងការទាញហេតុផល ឬ កំហុសចំពោះសមត្ថកិច្ចផ្ដាច់មុខ ដូច្នេះតុលាការធ្វើការវិនិច្ឆ័យទៅលើអង្គហេតុ និងអង្គច្បាប់ ប៉ុន្តែតុលាការមិនចាំបាច់ធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដើម្បីរៀបចំនូវសេចក្ដីអះអាងរបស់ភាគី កំណត់ចំណុចវិវាទ និងរៀបចំភស្តុតាងដែលត្រូវបានធ្វើនៅក្នុងនីតិវិធីជំនុំជម្រះលើកទី១រួចហើយ ហេតុនេះតុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់តែម្ដង។ នៅក្រោយពេលដែលបានកំណត់កាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់រួចរាល់ តុលាការត្រូវធ្វើការបញ្ជូនដីកាកោះទៅភាគី ដើម្បីឱ្យភាគីចូលរួមក្នុងនីតិវិធី។ ការបញ្ជូនដីកាកោះអាចធ្វើការបញ្ជូនទៅភាគីជាមួយគ្នានឹងលិខិតទទួលពាក្យបណ្ដឹង លើកលែងតែករណីដែលតុលាការលើកចោលពាក្យបណ្ដឹងឧទ្ធរណ៍នោះ ឬ មួយតុលាការចេញដីកាបង្គាប់ឱ្យកែតម្រូវជាដើម។

**ផ្នែកទី៨៖ ការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍**

នៅដំណាក់កាលជំនុំជម្រះលើកទី២ ត្រូវគោរពតាមគោលការណ៍នៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ និងមានការទាញហេតុផលដោយផ្ទាល់មាត់ ដោយមិនចាំបាច់ធ្វើនីតិវិធីត្រៀមទាញហេតុផល។

**១. គោលការណ៍នៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍**

ចំពោះការប្រព្រឹត្តទៅក្នុងការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ គឺមានគោលការណ៍មួយចំនួនដូចជា៖

តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវ ឬ មូលហេតុដែលនាំឱ្យមានការប្ដឹងឧទ្ធរណ៍ដែលបានសិក្សាខាងលើ ដើម្បីឧបាស្រ័យចំពោះសាលក្រមដើមនៃការជំនុំជម្រះលើកទី១។ តុលាការនៃបណ្ដឹងឧទ្ធរណ៍អាចលុបចោល ឬ ផ្លាស់ប្ដូរសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១ ត្រឹមកម្រិតនៃការទាមទារក្នុងបណ្ដឹងឧទ្ធរណ៍ ឬ បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ (គោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី) តែប៉ុណ្ណោះ។[37] ហេតុនេះចំណុចណាមួយនៃសាលក្រមនៃការជំនុំជម្រះលើកទី១ ដែលមិនត្រូវបានប្ដឹងឧទ្ធរណ៍

[37] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៧៨

តុលាការនៃបណ្តឹងឧទ្ធរណ៍មិនអាចសម្រេចបាននោះទេ។ ម្យ៉ាងវិញទៀតដើមបណ្តឹងឧទ្ធរណ៍មិនអាចទទួលនូវសាលដីកា ដែលខូចប្រយោជន៍ច្រើនជាងអ្វីដែលមានសម្រេចនៅក្នុងសាលក្រមនៃការជំនុំជម្រះលើកទី១នោះទេ (គោលការណ៍នៃការហាមឃាត់ការផ្លាស់ប្តូរដោយខូចផលប្រយោជន៍) លើកលែងតែមានបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ។ ឧទាហរណ៍៖ ដើមបណ្តឹងឧទ្ធរណ៍ "ខ" ប្តឹងឧទ្ធរណ៍ចំពោះចុងបណ្តឹងឧទ្ធរណ៍ "ក" គោលបំណងរបស់ដើមបណ្តឹងឧទ្ធរណ៍ចង់ឱ្យតុលាការលុបចោលការសម្រេចឱ្យបង់ប្រាក់ ៨,០០០ដុល្លារ។ តុលាការនៃបណ្តឹងឧទ្ធរណ៍អាចសម្រេចលុបចោល ឬ ផ្លាស់ប្តូរសាលក្រមដើមដែលមានទំហំមិនឱ្យខូចប្រយោជន៍របស់ដើមបណ្តឹងឧទ្ធរណ៍លើសពី ៨,០០០ដុល្លារ នោះទេ។ ប៉ុន្តែក្នុងករណីចុងបណ្តឹងឧទ្ធរណ៍បានធ្វើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ តុលាការនៃបណ្តឹងឧទ្ធរណ៍អាចសម្រេចឱ្យដើមបណ្តឹងឧទ្ធរណ៍ខូចផលប្រយោជន៍លើសពី ៨,០០០ដុល្លារ មានន័យថាដោយសារតែមានបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំចំពោះចំនួនទឹកប្រាក់ ២,០០០ដុល្លារ ហេតុនេះដើមបណ្តឹងឧទ្ធរណ៍អាចខូចខាតផលប្រយោជន៍ចំនួន ១០,០០០ដុល្លារ ប្រសិនបើតុលាការនៃបណ្តឹងឧទ្ធរណ៍ទទួលស្គាល់បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំរបស់ចុងបណ្តឹងឧទ្ធរណ៍។

**២. ការទាញហេតុផលដោយផ្ទាល់មាត់**

នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ សាលាឧទ្ធរណ៍មានសមាសភាពក្នុងការធ្វើជំនុំជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះដែលមានចៅក្រម០៣រូប ក្នុងចំណោមនោះមានប្រធាន០១រូប និងមានការចូលរួមដោយក្រឡាបញ្ជីជាអ្នកកត់ត្រា ចូលរួមដោយតំណាងមហាអយ្យការ និងមេធាវីតំណាង ឬ ការពារសិទ្ធិឱ្យភាគី ដោយអនុលោមតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី។ ដោយឡែកសម្រាប់រឿងក្តីដែលត្រូវបានតុលាការកំពូលសម្រេចបង្វិលមកវិញ នោះសាលាឧទ្ធរណ៍ត្រូវធ្វើការជំនុំជម្រះម្តងទៀត ដោយមានក្រុមប្រឹក្សាជំនុំជម្រះជាចៅក្រមចំនួន០៥រូប ក្នុងនោះមានប្រធាន០១រូប និងចៅក្រមចំនួន០៤រូបទៀត សុទ្ធតែជាចៅក្រមដែលមិនបានចូលរួមជំនុំជម្រះកាលពីលើកមុន។

ចំពោះសកម្មភាពនៃការជំនុំជម្រះលើកទី២របស់តុលាការនៃបណ្តឹងឧទ្ធរណ៍ ចំពោះសាលក្រមដើមដោយចេញសាលដីកា ហេតុនេះដើម្បីអាចវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវបានតុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ប៉ុន្តែមិនមានការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ ពីព្រោះសកម្មភាពនៃការជំនុំជម្រះលើកទី១ (សកម្មភាពបណ្តឹងដែលបានធ្វើឡើងនៅក្នុងការជំនុំជម្រះលើកទី១ ដោយរាប់បញ្ចូលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) មានអានុភាពចំពោះការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍។ ដូចបានលើកឡើងថាជាគោលការណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍មិនធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ លើកលែងតែការកំណត់ចំណុចវិវាទរបស់តុលាការជាន់ទាបមានលក្ខណៈមិនត្រឹមត្រូវ ហើយមានភាពចាំបាច់ពិសេសត្រូវកំណត់ចំណុចវិវាទជាថ្មី។ ឧទាហរណ៍៖ នៅក្នុងការជំនុំជម្រះលើកទី១ ដើមចោទអះអាងអំពីសិទ្ធិលើ

បំណុលចំនួន ១២,០០០ដុល្លារ ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ចុងចម្លើយបានអះអាងអំពីការរលត់សិទ្ធិលើបំណុលដោយអាជ្ញាយុកាល ហើយតុលាការបានកំណត់ចំណុចវិវាទថា "តើមានអត្ថិភាពនៃសិទ្ធិលើបំណុលឬទេ?" ការកំណត់ចំណុចវិវាទនេះមិនត្រឹមត្រូវទេ ចំណុចវិវាទដែលត្រឹមត្រូវគឺ "តើសិទ្ធិលើបំណុលនេះត្រូវរលត់ដោយអាជ្ញាយុកាលឬទេ?"។ ដូច្នេះសាលាដំបូងបានកំណត់ចំណុចវិវាទដែលមិនត្រឹមត្រូវថា "តើមានអត្ថិភាពនៃសិទ្ធិលើបំណុលឬទេ?" និងចេញសេចក្ដីសម្រេចបញ្ចប់ បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ ១២,០០០ដុល្លារ មកឱ្យដើមចោទ។ មកដល់តុលាការនៃបណ្ដឹងឧទ្ធរណ៍ឃើញថាមានចំណុចវិវាទមិនត្រឹមត្រូវ ទើបកំណត់ចំណុចវិវាទជាថ្មីថា "តើសិទ្ធិលើបំណុលនេះត្រូវរលត់ដោយអាជ្ញាយុកាលឬទេ?"។ ដូចនេះតុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវធ្វើការជំនុំជម្រះលើកទី២ ដោយត្រូវធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក្នុងករណីត្រូវកំណត់ចំណុចវិវាទជាថ្មី។

ចំពោះការទាញហេតុផលដោយផ្ទាល់មាត់វិញ ត្រូវធ្វើត្រឹមទំហំដែលភាគីបានទាមទារឱ្យផ្លាស់ប្ដូរសាលក្រមនៃការជំនុំជម្រះលើកទី១តែប៉ុណ្ណោះ។ សាលាឧទ្ធរណ៍ធ្វើការសម្រេចសេចក្ដីដោយពិនិត្យមើលទាំងអង្គហេតុ និងអង្គច្បាប់។ ការទាញហេតុផលដោយផ្ទាល់មាត់នៅតុលាការនៃបណ្ដឹងឧទ្ធរណ៍តម្រូវឱ្យភាគីធ្វើសេចក្ដីថ្លែងការណ៍អំពីលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់នៅតុលាការនៃការជំនុំជម្រះលើកទី១ ដោយសារនៅក្នុងការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ចៅក្រមត្រូវបានផ្លាស់ប្ដូរពីចៅក្រមនៃការជំនុំជម្រះលើកទី១។[38] ហេតុនេះសេចក្ដីថ្លែងការណ៍គ្រាន់តែជាសកម្មភាពរាយការណ៍ដែលមានលក្ខណៈជាទម្រង់ ដើម្បីបំពេញគោលការណ៍វិនិច្ឆ័យដោយផ្ទាល់។[39] បន្ទាប់មកនឹងមានការបន្តការវិនិច្ឆ័យ ដោយបើកឡើងវិញនូវការទាញហេតុផលដោយផ្ទាល់មាត់ជាថ្មីដែលត្រូវបានបញ្ចប់ម្ដងរួចហើយនៅក្នុងការជំនុំជម្រះលើកទី១ នេះហៅថាការទាញហេតុផលដោយផ្ទាល់មាត់នៅតុលាការនៃបណ្ដឹងឧទ្ធរណ៍។ ដូចនេះសកម្មភាពបណ្ដឹង (ការអះអាងអង្គហេតុ ការស្នើសុំឱ្យពិនិត្យភស្តុតាង ការសារភាពជាអាទិ៍) ដែលបានធ្វើនៅក្នុងការជំនុំជម្រះលើកទី១ មានអានុភាពនៅក្នុងការជំនុំជម្រះនៃបណ្ដឹងឧទ្ធរណ៍។ ឧទាហរណ៍៖ បញ្ចប់ការជំនុំជម្រះលើកទី១នៅសាលាដំបូងដែលការវិនិច្ឆ័យ ដោយមានការសួរសាក្សី "គ" មកបន្តការជំនុំជម្រះលើកទី២មានការវិនិច្ឆ័យជាថ្មីគឺនៅតែបន្តប្រើលទ្ធផលនៃការសួរសាក្សីនោះ។ ហេតុនេះនៅក្នុងការជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ តុលាការនៃបណ្ដឹងឧទ្ធរណ៍មិនអនុញ្ញាតឱ្យដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន (ភស្តុតាង) បន្ថែម ឬ ថ្មីនោះទេ។ ឧទាហរណ៍៖ ការជំនុំជម្រះលើកទី១ ភស្តុតាង X មិនត្រូវបានដាក់នោះទេ មកដល់ការជំនុំជម្រះលើកទី២ បានស្នើសុំដាក់ភស្តុតាង X ពេលនោះភស្តុតាង X មិនត្រូវបានអនុញ្ញាតឱ្យដាក់នោះទេ។ ប៉ុន្តែភាគីអាចត្រូវបានផ្ដល់ឱកាសឱ្យដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនដែលមិនបានដាក់នៅក្នុង

[38] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៧២

[39] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៨៥ កថាខណ្ឌទី២

ការជំនុំជម្រះលើកទី១ ប្រសិនបើមធ្យោបាយតទល់ ឬ ការពារខ្លួន (ភស្តុតាង) នោះ មិនផ្ទុយនឹងបញ្ញត្តិនៃមាត្រា១០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីដែលចែងថា ចំពោះករណីមធ្យោបាយនោះទាក់ទងនឹងចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួន ឬ ករណីដែលមធ្យោបាយថ្មីនោះមិនធ្វើឱ្យមានការយឺតយ៉ាវដល់នីតិវិធីនៃបណ្តឹង ឬ ករណីដែលភាគីបានធ្វើសេចក្តីសម្រេចដំបូងថា ខ្លួនមិនអាចដាក់មធ្យោបាយនោះបានមុនពេលបញ្ចប់នីតិវិធីត្រៀមការទាញហេតុផលដោយគ្មានកំហុសធ្ងន់ធ្ងរឡើយនៅក្នុងការជំនុំជម្រះលើកទី១។ ឧទាហរណ៍៖ ការជំនុំជម្រះលើកទី១ មិនបានសាកសួរសាក្សី "គ" ការជំនុំជម្រះលើកទី២ អនុញ្ញាតឱ្យសួរសាក្សី "គ" ការដាក់ភស្តុតាងថ្មី ដែលមិនផ្ទុយនឹងបញ្ញត្តិនៃមាត្រា១០៨ នៃក្រមនីតិវិធីប្បវេណី ត្រូវបានអនុញ្ញាតនៅក្នុងការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ដែលនៅក្នុងការជំនុំជម្រះលើកទី១ ដើមចោទបានដាក់ពាក្យសុំឱ្យសាកសួរសាក្សី "គ" ប៉ុន្តែដោយសារសាក្សី "គ" មានជំងឺធ្ងន់ធ្ងរត្រូវទៅព្យាបាលនៅបរទេស ដោយមិនដឹងពេលណាអាចត្រលប់មកវិញបាន ហេតុនេះសាក្សី "គ" មិនត្រូវបានសួរនៅក្នុងការជំនុំជម្រះលើកទី១ទេ ប៉ុន្តែនៅក្នុងការជំនុំម្រះលើបណ្តឹងឧទ្ធរណ៍ សាក្សី "គ" បានជាសះស្បើយពីជំងឺ និងត្រលប់មកកម្ពុជាវិញ។[40]

នៅពេលការទាញហេតុផលដោយផ្ទាល់មាត់បានបញ្ចប់ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវចេញសាលដីកាចុងក្រោយចំពោះបណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ដោយសាលដីកាចុងក្រោយនៃបណ្តឹងឧទ្ធរណ៍មានបីប្រភេទខុសៗគ្នា។ ក្នុងករណីនេះតុលាការនៃបណ្តឹងឧទ្ធរណ៍ធ្វើការទាញហេតុផលដោយផ្ទាល់មាត់រួចហើយ ភាគីដែលមិនពេញចិត្តនឹងសេចក្តីសម្រេចដែលមានក្នុងសាលដីការបស់សាលាឧទ្ធរណ៍ អាចប្តឹងសាទុក្ខទៅតុលាការកំពូលតាមកំណត់របស់ច្បាប់។

## ផ្នែកទី៩៖ ការបញ្ចប់បណ្តឹងឧទ្ធរណ៍

ក្រោយពីតុលាការនៃបណ្តឹងឧទ្ធរណ៍ធ្វើការទាញហេតុដោយផ្ទាល់មាត់រួច គឺត្រូវតែបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយវិធីពីរយ៉ាង ដូចជាការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ ឬ ការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ។

### ១. ការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ

ការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ គឺអាចជាការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយស្វ័យប្រវត្តិ ឬ ការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយសកម្មភាពភាគី។

#### ១.១. ការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយស្វ័យប្រវត្តិ

នៅពេលដែលនីតិវិធីបណ្តឹងឧទ្ធរណ៍កំពុងដំណើរការ ក្នុងករណីដែលមានភាគីណាមួយបានទទួលមរណភាព ហើយគ្មានអ្នកណាទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងនាំឱ្យបណ្តឹងនោះត្រូវបានបញ្ចប់។

[40] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៧៤

តាមធម្មតាបើទោះបីជាមានភាគីណាម្ខាងបានទទួលមរណភាពក៏ដោយ ក៏សន្តតិជនរបស់ភាគីនោះនឹងត្រូវទទួលបន្តនូវនីតិវិធីនៃបណ្តឹងដែលបានធ្វើពីមុនមក ហើយនីតិវិធីបណ្តឹងឧទ្ធរណ៍នោះមិនត្រូវបានបញ្ចប់ទេ ប៉ុន្តែបើមានករណីដែលភាគីបានទទួលមរណភាពនោះ ពុំមានអ្នកដែលត្រូវទទួលបន្តនូវនីតិវិធីនៃបណ្តឹងដោយសារសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹង តុលាការនៃបណ្តឹងឧទ្ធរណ៍នឹងចេញសាលដីកាបញ្ចប់បណ្តឹងនោះដោយស្វ័យប្រវត្តិ ដោយមានខ្លឹមសារថាបណ្តឹងឧទ្ធរណ៍ត្រូវបានបញ្ចប់ដោយសារមរណភាពរបស់ភាគី។

ក្នុងករណីដែលសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងបានរលត់ដោយសារការរួមបញ្ចូលគ្នានៃនីតិបុគ្គលនាំឱ្យសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងត្រូវធ្លាក់លើបុគ្គលតែម្នាក់ ហើយដើមបណ្តឹងឧទ្ធរណ៍និងចុងបណ្តឹងឧទ្ធរណ៍បានក្លាយទៅជាបុគ្គលតែមួយ ដោយសារតែភាគីណាម្ខាងបានទទួលបន្តនូវឋានៈតាមផ្លូវបណ្តឹងរបស់ភាគីម្ខាងទៀត ដោយសារការរួមបញ្ចូលគ្នានៃនីតិបុគ្គល ឬ ដោយសន្តតិកម្ម។ ករណីនេះតុលាការនឹងចេញសាលដីកាបញ្ចប់បណ្តឹងដោយស្វ័យប្រវត្តិ ដោយសារតែមានភាគីជាបុគ្គលតែមួយ។

### **១.២. ការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយសកម្មភាពភាគី**

ការបញ្ចប់បណ្តឹងដោយសកម្មភាពរបស់ភាគី ក្នុងនោះអាចជាសកម្មភាពនៃការដកពាក្យបណ្តឹង ការលះបង់ ឬ ការទទួលស្គាល់ការទាមទារ និងការសះជាតាមផ្លូវបណ្តឹងរបស់ភាគីនឹងធ្វើឱ្យសកម្មភាពនៃបណ្តឹងត្រូវបញ្ចប់ផងដែរ៖

- ទោះបីជាបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់រួចហើយក៏ដោយ ភាគីនៅតែមានសិទ្ធិនៅក្នុងការដកពាក្យបណ្តឹងវិញ នៅពេលណាក៏បានរហូតដល់ពេលដែលសាលដីកាចុងក្រោយរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវបានប្រកាស ដោយមិនចាំបាច់ទទួលការយល់ព្រមពីចុងបណ្តឹងឧទ្ធរណ៍។[41] ជាក់ស្តែងអំឡុងពេលនៃការដកពាក្យបណ្តឹងឧទ្ធរណ៍ គឺចាប់ពីការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ រហូតដល់ការប្រកាសសាលដីកានៃការជំនុំជម្រះលើកទី២ ឬ ក្នុងនាមការជំនុំជម្រះលើកទី១ នៅពេលដែលប្រកាសសាលដីការួច សិទ្ធិក្នុងការដកពាក្យបណ្តឹងឧទ្ធរណ៍ត្រូវបានរលត់។ ការដកពាក្យបណ្តឹងឧទ្ធរណ៍ គឺជាការដកចេញនូវការធ្វើឧបាស្រ័យចំពោះសាលក្រមនៃការជំនុំជម្រះលើកទី១ ហេតុនេះអានុភាពនៃការដកបណ្តឹងឧទ្ធរណ៍នាំឱ្យនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ត្រូវបានបញ្ចប់ និងត្រូវបានចាត់ទុកថាគ្មានបណ្តឹងឧទ្ធរណ៍តាំងពីដើម ហើយសាលក្រមនៃការជំនុំជម្រះលើកទី១ ត្រូវចូលជាស្ថាពរតាំងពីថ្ងៃផុតអំឡុងពេលនៃការប្តឹងឧទ្ធរណ៍។[42] ក្នុងករណីនេះការចាត់ទុកបណ្តឹងទាំងមូល រួមទាំងសាលក្រមនៃការជំនុំជម្រះលើកទី១ នឹងត្រូវរលត់ដោយអានុភាព

[41] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៦៩ កថាខណ្ឌទី១

[42] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៦៩ កថាខណ្ឌទី៣

ប្រតិសកម្ម។ ការដកពាក្យបណ្ដឹងឧទ្ធរណ៍ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ប៉ុន្តែនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សា ការដកពាក្យបណ្ដឹងឧទ្ធរណ៍អាចធ្វើដោយផ្ទាល់មាត់បាន។ ដោយឡែកការដកពាក្យបណ្ដឹងឧទ្ធរណ៍មួយផ្នែក គឺហៅថាមោឃៈ ដោយសារគោលការណ៍នៃភាពអវិភាគនៃបណ្ដឹងឧទ្ធរណ៍។ ការដកពាក្យបណ្ដឹងមិនមានឥទ្ធិពលទៅលើសាលក្រមដើម ឬ អានុភាពនៃការជំនុំជម្រះលើកទី១ទេ ហើយមិនឱ្យមានការខូចផលប្រយោជន៍ដល់ចុងបណ្ដឹងឧទ្ធរណ៍ទេ ហេតុដូច្នេះមិនចាំបាច់មានការយល់ព្រមពីចុងបណ្ដឹងឧទ្ធរណ៍ឡើយ។ ក្រោយការដកពាក្យបណ្ដឹងឧទ្ធរណ៍ បើអំឡុងពេលសម្រាប់ប្ដឹងឧទ្ធរណ៍មិនទាន់កន្លងផុតទេ ភាគីម្ខាងទៀតព្រមទាំងដើមបណ្ដឹងឧទ្ធរណ៍ដែលបានដកពាក្យបណ្ដឹងរួចហើយ ក៏អាចប្ដឹងឧទ្ធរណ៍ម្ដងទៀតបានដែរ។ នៅពេលដែលដកពាក្យបណ្ដឹងឧទ្ធរណ៍ អាចមានការសងពន្ធដាក់ពាក្យសុំពាក់កណ្ដាលលុះត្រានៅក្នុងករណីដែលបណ្ដឹងឧទ្ធរណ៍ត្រូវបានដកមុនកាលបរិច្ឆេទ នៃការទាញហេតុផលដោយផ្ទាល់មាត់លើកដំបូងនៅតុលាការនៃបណ្ដឹងឧទ្ធរណ៍ ដើមបណ្ដឹងឧទ្ធរណ៍អាចដាក់ពាក្យសុំឱ្យសងពាក់កណ្ដាលនៃពន្ធដាក់ពាក្យសុំ។ ឧទាហរណ៍៖ ភាគី "ខ" បានប្ដឹងឧទ្ធរណ៍ទាំងមូលចំពោះសេចក្ដីសម្រេចរបស់តុលាការជាន់ទាបដែលបានសម្រេចឱ្យភាគី "ខ" បង់ប្រាក់ចំនួន ១០,០០០ដុល្លារ ឱ្យទៅដើមចោទ "ក"។ ប្រសិនបើភាគី "ខ" ប្ដឹងឧទ្ធរណ៍ភាគី "ខ" ត្រូវបង់ពន្ធដាក់ពាក្យសុំនៃបណ្ដឹងឧទ្ធរណ៍ចំនួន ៤៦៥,០០០រៀល។ ករណីនេះប្រសិនបើភាគី "ខ" ដកបណ្ដឹងឧទ្ធរណ៍ មុនពេលទាញហេតុផលដោយផ្ទាល់មាត់ភាគី "ខ" អាចដាក់ពាក្យសុំឱ្យសងពន្ធខាងលើនេះពាក់កណ្ដាលវិញដែលមានចំនួនស្មើនឹង ២៣២,៥០០រៀល។ ប្រសិនបើភាគីទាំងសងខាងមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទនៃកាទាញហេតុផលដោយផ្ទាល់មាត់ នៅក្នុងការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ទេ ហើយមិនបានដាក់ពាក្យសុំឱ្យតុលាការកំណត់កាលបរិច្ឆេទជាថ្មីទៀត ក្នុងអំឡុងពេល ០១ខែទេ បើភាគីទាំងសងខាងអវត្តមាននៅកាលបរិច្ឆេទលើកទី២ម្ដងទៀត តុលាការត្រូវចាត់ទុកថាបានដកបណ្ដឹងឧទ្ធរណ៍។[43]

➢ ការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារ គឺភាគីត្រូវធ្វើសេចក្ដីថ្លែងការណ៍ដែលធ្វើឱ្យមានការខូចផលប្រយោជន៍របស់ខ្លួនទទួលស្គាល់ថា ការទាមទាររបស់ខ្លួនពុំមានមូលហេតុត្រឹមត្រូវ ឬ ទទួលស្គាល់ថាការទាមទាររបស់ភាគីម្ខាងទៀតមានមូលហេតុត្រឹមត្រូវចំពោះការទាមទារ។ ដោយការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារជាសេចក្ដីថ្លែងការណ៍តាមផ្លូវបណ្ដឹងដែលភាគីម្ខាងទទួលស្គាល់ពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការទាមទារ ហើយវិវាទរវាងភាគីទាំងសងខាងត្រូវបានដោះស្រាយដោយសេចក្ដីថ្លែងការណ៍នេះ សកម្មភាពទាំងនេះនាំឱ្យបណ្ដឹងត្រូវបានបញ្ចប់ដោយមិនចាំបាច់រងចាំសាលដីកាទេ។ ចំពោះល័ក្ខខ័ណ្ឌចាំបាច់ក្នុងការទទួលស្គាល់នូវការទាមទារ គឺជាសកម្មភាពបណ្ដឹងមួយយ៉ាងសំខាន់ក្នុងការបញ្ចប់នីតិវិធីនៃបណ្ដឹងឧទ្ធរណ៍ ដូច្នេះហើយភាគី

[43] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៦៩ កថាខណ្ឌទី៤

ចាំបាច់ត្រូវតែជាបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើបណ្ដឹង។ ចំពោះអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅអាចធ្វើការលះបង់ ឬ ទទួលស្គាល់នូវការទាមទារមានសុពលភាពបាន លុះត្រាតែត្រូវបានធ្វើដោយអ្នកតំណាងដែលច្បាប់បានកំណត់ លើកលែងតែអនីតិជនដែលអាចធ្វើសកម្មភាពដោយឯករាជ្យ។ រីឯជននៅក្រោមហិតូបត្ថម្ភ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ត្រូវមានការប្រគល់សិទ្ធិពិសេស ដើម្បីធ្វើសកម្មភាពក្នុងការលះបង់ការទាមទារ ឬ ទទួលស្គាល់នូវការទាមទារនេះ។ យ៉ាងណាមិញអានុភាពនៃការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារ តុលាការនៃបណ្ដឹងឧទ្ធរណ៍ ត្រូវពិនិត្យអំពីល័ក្ខខ័ណ្ឌនៃបណ្ដឹង និងល័ក្ខខ័ណ្ឌសមត្ថភាពរបស់ភាគីនោះ បើពិនិត្យទៅឃើញថាភាគីមានល័ក្ខខ័ណ្ឌគ្រប់គ្រាន់ក្នុងការលះបង់ ឬ ទទួលស្គាល់នូវការទាមទារក្រឡាបញ្ជីត្រូវចុះក្នុងកំណត់ហេតុនាំឱ្យបណ្ដឹងត្រូវបានបញ្ចប់ ហើយកំណត់ហេតុនោះមានអានុភាពដូចគ្នានឹងសាលដីកាស្ថាពរដែរ។ ម្យ៉ាងវិញទៀតកំណត់ហេតុដែលបានចុះអំពីការលះបង់នូវការទាមទាររបស់ដើមបណ្ដឹងឧទ្ធរណ៍ មានអានុភាពដូចគ្នានឹងសាលដីកា ដែលច្រានចោលនូវការទាមទាររបស់ដើមបណ្ដឹងឧទ្ធរណ៍ដែរ។ ចំណែកឯកំណត់ហេតុដែលចុះអំពីការទទួលស្គាល់នូវការទាមទាររបស់ចុងបណ្ដឹងឧទ្ធរណ៍ មានអានុភាពដូចគ្នានឹងសាលដីកាដែលទទួលស្គាល់នូវការទាមទាររបស់ដើមបណ្ដឹងឧទ្ធរណ៍ដែរ។

➢ ការសះជាតាមផ្លូវបណ្ដឹង គឺជាសកម្មភាពមួយដែលដើមបណ្ដឹងឧទ្ធរណ៍ និងចុងបណ្ដឹងឧទ្ធរណ៍ធ្វើសម្បទានឱ្យគ្នាទៅវិញទៅមកនូវការអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្ដឹង នេះជាការព្រមព្រៀងគ្នាបញ្ចប់វិវាទនៅក្នុងនីតិវិធីបណ្ដឹងតាមរយៈការសម្រុះសម្រួលគ្នាចំពោះទំនាក់ទំនងនៃសិទ្ធិដែលជាចំណុចវិវាទ ដោយភាគីទាំងសងខាងចាំបាច់ត្រូវបង្ហាញខ្លួននៅចំពោះមុខតុលាការនៃបណ្ដឹងឧទ្ធរណ៍នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយព្រមព្រៀងគ្នាដោយផ្ទាល់មាត់។ ចំពោះល័ក្ខខ័ណ្ឌចាំបាច់នៃការសះជាតាមផ្លូវបណ្ដឹង ក៏ជាសកម្មភាពបណ្ដឹងដែរ ដូច្នេះដើម្បីធ្វើការសះជាបានភាគីចាំបាច់ត្រូវតែជាបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ ដូច្នេះបើមានភាគីណាមួយជាបុគ្គលដែលត្រូវបានកម្រិតសមត្ថភាពបានធ្វើការសះជានោះ គឺពុំមានអានុភាពឡើយ។ ចំពោះការតំណាងដោយអាណត្តិសម្រាប់ភាគី អ្នកតំណាងដែលច្បាប់បានកំណត់សម្រាប់អនីតិជន ជននៅក្រោយអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ មានលក្ខណៈដូចគ្នានឹងការលះបង់ ឬ ការទទួលស្គាល់នូវកាទាមទារដែរ ។ អានុភាពនៃការសះជាមានអានុភាពបញ្ចប់បណ្ដឹងដោយការសះជា គឺជាការព្រមព្រៀងបញ្ចប់វិវាទរបស់ភាគីនៃបណ្ដឹងឧទ្ធរណ៍ដែលបានកត់ត្រានៅក្នុងកំណត់ហេតុ ហេតុនេះហើយលទ្ធផលនៃការសះជាតាមផ្លូវបណ្ដឹងនេះ នាំឱ្យនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍ត្រូវបានបញ្ចប់ផងដែរ ។ កំណត់ហេតុនៃការសះជា មានអានុភាពដូចគ្នានឹងសាលដីកាស្ថាពរដែរ ប្រសិនបើក្នុងកំណត់ហេតុនេះ មានចុះអំពីសិទ្ធិទាមទារឱ្យផ្ដល់តាវកាលិកជាក់ស្ដែងដោយមានការកំណត់ពេលអនុវត្ត និងបែបផែននៃការអនុវត្ត ដូច្នេះហើយកំណត់ហេតុសះជាត្រូវមានអានុភាពអនុវត្ត ហើយកំណត់ហេតុនេះ

ក្លាយទៅជាលិខិតអនុវត្ត ដែលភាគីអាចសម្រេចនូវសិទ្ធិទាមទារតាមរយៈការអនុវត្តដោយបង្ខំបាន។ បើការសះជាតាមផ្លូវបណ្ដឹងមានវិការៈភាគីអាចអះអាងអំពីមោឃភាព ឬ ការលុបចោលការសះជានោះដោយយកវិការៈក្នុងការបង្ហាញឆន្ទៈមកធ្វើជាមូលហេតុនៅពេលក្រោយបាន។ ករណីមានជម្លោះអំពីអានុភាពនៃការសះជា នោះនីតិវិធីនៃការដោះស្រាយជម្លោះនេះមិនមែនជាការសុំជំនុំជម្រះសាជាថ្មីដូចករណីសាលដីកាទេ គឺគ្រាន់តែជាការស្នើសុំឱ្យតុលាការនៃបណ្ដឹងឧទ្ធរណ៍ កំណត់នូវកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់សាជាថ្មីតែប៉ុណ្ណោះ។ បើសិនជាមានពាក្យសុំឱ្យតុលាការនៃបណ្ដឹងឧទ្ធរណ៍កំណត់នូវកាលបរិច្ឆេទជាថ្មីម្ដងទៀត ដោយមានមូលហេតុមានវិការៈក្នុងការសះជា តុលាការនៃបណ្ដឹងឧទ្ធរណ៍ចាំបាច់ត្រូវកំណត់ នូវកាលបរិច្ឆេទនោះម្ដងទៀតតាមពាក្យសុំរបស់ភាគី ហើយនៅកាលបរិច្ឆេទជាថ្មីនេះ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវវិនិច្ឆ័យជាមុនថា ការសះជាដែលបានធ្វើពីមុននោះមានសុពលភាព ឬ គ្មានសុពលភាព។ បើការវិនិច្ឆ័យឃើញថា ការសះជានោះមានវិការៈ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវធ្វើការបញ្ជាក់ថា បណ្ដឹងនោះមិនទាន់ត្រូវបានបញ្ចប់ទេ ហើយត្រូវបន្តការវិនិច្ឆ័យលើបណ្ដឹងនោះ។ ប៉ុន្តែបើវិនិច្ឆ័យឃើញថា ការសះជាដែលបានធ្វើពីមុននោះមានសុពលភាព តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវចេញសាលដីកាដែលប្រកាសអំពីការបញ្ចប់បណ្ដឹងដោយការសះជានោះ។ ចំពោះបន្ទុកនៃប្រាក់ប្រដាប់ក្ដី ភាគីដែលត្រូវទទួលបន្ទុកនៃប្រាក់ប្រដាប់ក្ដី គឺអាស្រ័យទៅលើការព្រមព្រៀងរបស់ភាគីនោះ ប៉ុន្តែប្រសិនបើភាគីគ្មានការព្រមព្រៀងគ្នាអំពីប្រាក់ប្រដាប់ក្ដីទេ ភាគីនីមួយៗត្រូវទទួលបន្ទុកក្នុងការបង់រៀងៗខ្លួន។ បើការសះជាបានសម្រេចលទ្ធផលមុនពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដើមបណ្ដឹងឧទ្ធរណ៍ ទទួលបានការសងមកវិញនូវចំនួនពាក់កណ្ដាលនៃពន្ធដែលបានបង់រួចមកហើយ។

## ២. ការបញ្ចប់បណ្ដឹងឧទ្ធរណ៍ដោយឆ្លងកាត់សេចក្ដីសម្រេចរបស់តុលាការ

ការបញ្ចប់បណ្ដឹងឧទ្ធរណ៍ដោយឆ្លងកាត់សេចក្ដីសម្រេចរបស់តុលាការវិញ គឺជាការចេញសាលដីកាចំពោះបណ្ដឹងឧទ្ធរណ៍ ឬ បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ ដែលអាចជាសាលដីកាលើកចោលបណ្ដឹងឧទ្ធរណ៍ ឬ សាលដីកាច្រានចោលបណ្ដឹងឧទ្ធរណ៍ ឬ សាលដីកាទទួលស្គាល់បណ្ដឹងឧទ្ធរណ៍។

### ២.១. សាលដីកាលើកចោលបណ្ដឹងឧទ្ធរណ៍

តុលាការនៃបណ្ដឹងឧទ្ធរណ៍ចេញសាលដីកាលើកបណ្ដឹងឧទ្ធរណ៍ចោល ក្នុងករណីបណ្ដឹងឧទ្ធរណ៍មិនស្របច្បាប់ ឬ ខុសល័ក្ខខ័ណ្ឌនៃបណ្ដឹងឧទ្ធរណ៍ដែលមិនអាចកែតម្រូវបាន ដូចជាករណីផុតសិទ្ធិប្ដឹងឧទ្ធរណ៍ ឬ គ្មានផលប្រយោជន៍នៃបណ្ដឹងឧទ្ធរណ៍ជាអាទិ៍ ហេតុនេះតុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវចេញសាលដីកាលើកបណ្ដឹងឧទ្ធរណ៍ចោល ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់។[44] ឧទាហរណ៍៖ ដើមបណ្ដឹង

[44] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៦៨

ឧទ្ធរណ៍ ដាក់ពាក្យប្ដឹងឧទ្ធរណ៍ប្ដឹងចុងបណ្ដឹងឧទ្ធរណ៍ ដោយផុតកំណត់នៃការប្ដឹងឧទ្ធរណ៍ នាំឱ្យបណ្ដឹងឧទ្ធរណ៍ មិនស្របនឹងច្បាប់ដែលមិនអាចកែតម្រូវ នោះតុលាការនៃបណ្ដឹងឧទ្ធរណ៍ចេញសេចក្ដីសម្រេចបញ្ចប់ដែលមាន ខ្លឹមសារ លើកចោលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ របស់ដើមបណ្ដឹងឧទ្ធរណ៍ និងប្រាក់ប្រដាប់ក្ដី ក៏ជាបន្ទុករបស់ដើមបណ្ដឹងឧទ្ធរណ៍។

ក្នុងករណីបណ្ដឹងឧទ្ធរណ៍ត្រូវបានលើកចោល បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំក៏ត្រូវលើកចោលដែរ ប្រសិនបើ បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំនោះធ្វើឡើងហួសអំឡុងពេលប្ដឹងឧទ្ធរណ៍ ដែលនាំឱ្យបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំបាន បាត់បង់អានុភាពព្រោះមិនស្របនឹងនឹងច្បាប់។ ប៉ុន្តែបើបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំនោះធ្វើឡើងមិនហួសអំឡុង ពេលប្ដឹងឧទ្ធរណ៍ និងមានល័ក្ខខ័ណ្ឌនៃបណ្ដឹងឧទ្ធរណ៍គ្រប់គ្រាន់ ដែលហៅថាបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំដោយ ឯករាជ្យ ហើយទោះបីជាតុលាការលើកចោលបណ្ដឹងឧទ្ធរណ៍ក៏ដោយ ក៏មិនប៉ះពាល់ ឬ បាត់បង់អានុភាពដល់ បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំដែរ។

### ២.២. សាលដីកាច្រានចោលបណ្ដឹងឧទ្ធរណ៍

តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវចេញសាលដីកាច្រានចោលបណ្ដឹងឧទ្ធរណ៍ ក្នុងករណីតុលាការយល់ឃើញ ថាសាលក្រមនៃការជំនុំជម្រះលើកទី១ត្រឹមត្រូវ ទោះបីជាសំអាងហេតុនៃការជំនុំជម្រះលើកទី១ មិនត្រឹមត្រូវក៏ដោយ បើយល់ឃើញថាសេចក្ដីសម្រេចបញ្ចប់នៃសាលក្រមនៃការជំនុំជម្រះលើកទី១នោះត្រឹមត្រូវ បើផ្អែកលើសំអាងហេតុ ផ្សេងទៀត។ [45] នេះដោយសារតែអាជ្ញាអស់ជំនុំមិនត្រូវកើតឡើងទៅលើសេចក្ដីវិនិច្ឆ័យ នៅក្នុងសំអាងហេតុនៃ សាលក្រមដើមទេដែលមានបញ្ញត្តិក្នុងមាត្រា១៩៤ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ហេតុដូច្នេះភាពមិន ត្រឹមត្រូវនៃសំអាងហេតុនោះគ្មានឥទ្ធិពលទៅលើអានុភាពនៃសាលក្រមឡើយ។[46] ឧទាហរណ៍៖ ដើមចោទ "ក" ធ្វើបណ្ដឹងបដិសេធបិតុភាពដោយយក "ខ" ជាចុងចម្លើយ តុលាការនៃការជំនុំជម្រះលើកទី១ មានសំអាងហេតុ ថាចុងចម្លើយកើតក្នុងអំឡុងពេល៣០០ថ្ងៃគិតចាប់ពីថ្ងៃលែងលះ តុលាការនៃការជំនុំជម្រះលើកទី១ចេញសេចក្ដី សម្រេចបញ្ចប់មានខ្លឹមសារ បដិសេធបិតុភាពរវាងដើមចោទ និងចុងចម្លើយ។ ដើមបណ្ដឹងឧទ្ធរណ៍ "ក" បានប្ដឹង ឧទ្ធរណ៍បន្តចំពោះសេចក្ដីសម្រេចខាងលើដែលមានសំអាងហេតុថ្មីថា ចុងចម្លើយកើតក្រោយអំឡុងពេល៣០០ថ្ងៃ គិតចាប់ពីថ្ងៃលែងលះ តុលាការនៃបណ្ដឹងឧទ្ធរណ៍យល់ឃើញថាសេចក្ដីសម្រេចបញ្ចប់នៃសាលក្រមនៃការជំនុំជម្រះ លើកទី១នោះត្រឹមត្រូវ ហើយចេញសេចក្ដីសម្រេចបញ្ចប់ដោយមានខ្លឹមសារ បដិសេធបិតុភាពរវាងដើមចោទ និង ចុងចម្លើយដដែល ទើបចេញសាលដីកាច្រានចោលបណ្ដឹងឧទ្ធរណ៍។

[45] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៧៧

[46] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៩៤ កថាខណ្ឌទី៣

ម្យ៉ាងទៀតបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំវិញ ប្រសិនបើបណ្តឹងឧទ្ធរណ៍ត្រូវបានច្រានចោល ក៏បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំត្រូវច្រានចោលដែរ។

ប្រសិនបើសាលដីកាច្រានចោលបណ្តឹងឧទ្ធរណ៍ចូលជាស្ថាពរ នោះសាលក្រមដើមនៃការជំនុំជម្រះលើកទី១ក៏ចូលជាស្ថាពរដែរ។ ក្នុងករណីសាលក្រមដើមជាសាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិក សាលក្រមដើមក្លាយទៅលិខិតអនុវត្ត។[47]

### ២.៣. សាលដីកាទទួលស្គាល់បណ្តឹងឧទ្ធរណ៍

ផ្ទុយមកវិញតុលាការនៃបណ្តឹងឧទ្ធរណ៍ចេញសាលដីកាទទួលស្គាល់បណ្តឹងឧទ្ធរណ៍ ក្នុងករណីតុលាការនៃបណ្តឹងឧទ្ធរណ៍យល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១មានភាពមិនត្រឹមត្រូវ ឬ ខុសនីតិវិធីធ្ងន់ធ្ងរ តុលាការត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី១ ហើយតុលាការនៃបណ្តឹងឧទ្ធរណ៍អាចធ្វើការវិនិច្ឆ័យដោយខ្លួនឯងជំនួសសាលាដំបូង ឬ បញ្ជូនត្រលប់ ឬ ផ្ទេររឿងក្តី។

#### ២.៣.១. ការលុបចោល និងការវិនិច្ឆ័យដោយខ្លួនឯង

នៅពេលតុលាការនៃបណ្តឹងឧទ្ធរណ៍ទទួលស្គាល់បណ្តឹងឧទ្ធរណ៍ក្នុងពីរករណី គឺតុលាការនៃបណ្តឹងឧទ្ធរណ៍យល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១ មានភាពមិនត្រឹមត្រូវ ឬ ខុសនីតិវិធីធ្ងន់ធ្ងរះ

- ក្នុងករណីតុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី១ ប្រសិនបើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១មានភាពមិនត្រឹមត្រូវ គឺជាសាលក្រមដែលមានកំហុស។ ឧទាហរណ៍ៈ សាលក្រមដើមសម្រេចឱ្យដើមចោទឈ្នះក្តីដែលមានខ្លឹមសារថា បង្គាប់ឱ្យចុងចម្លើយលុបចោលនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដី L ទាំងមូល ដោយមូលហេតុរំលាយកិច្ចសន្យាលក់ទិញចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២០ ផ្អែកលើអត្ថិភាពនៃអង្គហេតុរំលាយកិច្ចសន្យា ប៉ុន្តែតុលាការនៃបណ្តឹងឧទ្ធរណ៍យល់ឃើញថាគ្មានអត្ថិភាពនៃអង្គហេតុរំលាយទេដែលមិនមានភាពត្រឹមត្រូវ ដោយផ្អែកលើសំអាងហេតុផ្សេង គប្បីឱ្យដើមចោទចាញ់ក្តី (ចុងបណ្តឹងឧទ្ធរណ៍)។ ក្នុងករណីនេះ តុលាការនៃបណ្តឹងឧទ្ធរណ៍មិនលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី១ទាំងស្រុងនោះទេ ប៉ុន្តែធ្វើការផ្លាស់ប្តូរ ឬ កែប្រែខ្លឹមសារសាលក្រមនៃការជំនុំជម្រះលើកទី១។ ដូច្នេះករណីនេះតុលាការនៃបណ្តឹងឧទ្ធរណ៍ជំនុំជម្រះលើសាលក្រមដើម ដោយចេញសេចក្តីសម្រេចបញ្ចប់នៃសាលដីកាដោយកែប្រែ ឬ ផ្លាស់ប្តូរនូវសាលក្រមដើម។
- ចំពោះករណីតុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី១ បើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១ខុសនីតិវិធីធ្ងន់ធ្ងរ។ កំហុសនីតិវិធីធ្ងន់ធ្ងរ មានដូចជាការសាកសួរ

---

[47] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៣៥០ កថាខណ្ឌទី២ ចំណុច ក

សាក្សីនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការប្រកាសសាលក្រមដោយចៅក្រមដែលមិនមែនជាអ្នកវិនិច្ឆ័យជាអាទិ៍។ ឧទាហរណ៍៖ តុលាការនៃការជំនុំជម្រះលើកទី១ នៅដំណាក់នីតិវិធីត្រៀមទាញហេតុផល បានធ្វើការសាកសួរសាក្សីដែលជាកំហុសនៃនីតិវិធី ដំណាក់កាលនេះជាដំណាក់កាលរៀបចំការអះអាង ចំណុចវិវាទ និងភស្តុតាង។ ប៉ុន្តែតុលាការនៃការជំនុំជម្រះលើកទី១ ទទួលស្គាល់ចម្លើយរបស់សាក្សី "គ"។ មកដល់តុលាការនៃបណ្តឹងឧទ្ធរណ៍នឹងធ្វើការសាកសួរសាក្សី "គ" ជាថ្មីម្តងទៀត។ ក្នុងករណីតុលាការនៃបណ្តឹងឧទ្ធរណ៍មិនជឿលើចម្លើយរបស់សាក្សី "គ" តុលាការនឹងលុបចោលសាលក្រមដើម។ ប៉ុន្តែប្រសិនបើតុលាការនៃបណ្តឹងឧទ្ធរណ៍ជឿលើចម្លើយរបស់សាក្សី "គ" តុលាការនឹងច្រានចោលបណ្តឹងឧទ្ធរណ៍។ ម្យ៉ាងទៀតករណីតុលាការយល់ឃើញថាមានភាពចាំបាច់ក្នុងការកំណត់ចំណុចវិវាទថ្មី តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវចេញដីកាសម្រេចបង្វិលមកនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាថ្មីនៅតុលាការដើម ដែលមានកំណត់ក្នុងមាត្រា១១៦ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ដូច្នេះករណីនេះតុលាការនៃបណ្តឹងឧទ្ធរណ៍ជំនុំជម្រះលើសាលក្រមដើមដោយចេញសេចក្តីសម្រេចបញ្ចប់នៃសាលដីកា ដោយលុបចោលនូវសាលក្រមដើម។

### ២.៣.២. ការលុបចោល និងការបញ្ជូនត្រលប់ទៅតុលាការដើមវិញ

តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី១ ដោយបញ្ជូនត្រលប់ទៅតុលាការដើម ចំពោះករណីតុលាការនៃបណ្តឹងឧទ្ធរណ៍បានទទួលពាក្យបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមលើកចោលបណ្តឹងរបស់តុលាការនៃការជំនុំជម្រះលើកទី១ ប៉ុន្តែតុលាការនៃបណ្តឹងឧទ្ធរណ៍យល់ឃើញថាសាលក្រមនៃការជំនុំជម្រះលើកទី១នោះមិនត្រឹមត្រូវស្របតាមច្បាប់ ហើយមានភាពចាំបាច់ត្រូវទាញហេតុផលបន្ថែមទៀតចំពោះរឿងក្តីនោះ។[48] ឧទាហរណ៍៖ នៅសាលាដំបូងបានចេញសេចក្តីសម្រេចបញ្ចប់លើកចោលបណ្តឹង ដោយបណ្តឹងនោះមិនស្របនឹងច្បាប់ ហើយប្តឹងឧទ្ធរណ៍ចំពោះសាលក្រមដែលបានលើកបណ្តឹងចោល ប៉ុន្តែសាលាឧទ្ធរណ៍យល់ថាបណ្តឹងនោះមិនមែនបណ្តឹងដែលខុសនឹងច្បាប់ទេ ទើបចេញសេចក្តីសម្រេចបញ្ចប់ដែលមានខ្លឹមសារលុបចោលសាលក្រមរបស់សាលាដំបូង និងបញ្ជូនរឿងនេះទៅសាលាដំបូងវិញ។

ករណីតុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី១ ដោយបញ្ជូនត្រលប់ទៅតុលាការដើម ចំពោះករណីតុលាការនៃបណ្តឹងឧទ្ធរណ៍បានទទួលពាក្យបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមដែលទទួលស្គាល់ការទាមទារ ប៉ុន្តែមានកំហុសនីតិវិធីធ្ងន់ធ្ងរក្នុងការជំនុំជម្រះលើកទី១។ ឧទាហរណ៍៖ នៅពេលទាញហេតុផលដោយផ្ទាល់មាត់ ដោយភាគីមិនបានទទួលការបញ្ជូនដីកាកោះតាមច្បាប់នៅក្នុងការជំនុំជម្រះ

[48] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៨០ កថាខណ្ឌទី១

លើកទី១របស់សាលាដំបូង នោះតុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវលុបចោលសាលក្រមដើម និងបញ្ជូនត្រលប់ដើម្បីធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឡើងវិញ។[49]

ដោយឡែកក្នុងករណីតុលាការនៃបណ្តឹងឧទ្ធរណ៍លុបចោលនូវសាលក្រមដើម ហើយបញ្ជូនត្រលប់ទៅតុលាការដើម តុលាការនៃបណ្តឹងឧទ្ធរណ៍នឹងមិនសម្រេចអំពីប្រាក់ប្រដាប់ក្តីនោះទេ ពីព្រោះការសម្រេចនេះមិនទាន់បានកំណត់អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិរបស់ភាគីនៅឡើយ។ ការសម្រេចនេះពាក់ព័ន្ធតែជាមួយនឹងកំហុសនីតិវិធីរបស់តុលាការជាន់ទាបតែប៉ុណ្ណោះ។[50] ការសម្រេចអំពីប្រាក់ប្រដាប់ក្តី គឺជាការកំណត់អំពីបន្ទុកនៃការចំណាយដែលត្រូវបានប្រើប្រាស់នៅក្នុងអំឡុងពេលនីតិវិធីរបស់តុលាការដោយភាគី ហេតុនេះមូលដ្ឋាននៃការសម្រេចគឺផ្អែកទៅលើការកំណត់ជាស្ថាពរនូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត។

យ៉ាងណាមិញសាលដីកាបញ្ជូនរឿងក្តីត្រលប់ទៅវិញ អាចប្តឹងសាទុក្ខបាន។ ប៉ុន្តែបើសាលដីកាបញ្ជូនរឿងក្តីត្រលប់ទៅវិញចូលជាស្ថាពរ រឿងក្តីនោះនឹងត្រូវផ្ទេរទៅតុលាការដើម។

### ២.៣.៣. ការលុបចោល និងការផ្ទេរនូវរឿងក្តីទៅតុលាការផ្សេង

តុលាការនៃបណ្តឹងឧទ្ធរណ៍លុបចោលសាលក្រមដើម និងផ្ទេររឿងក្តីទៅតុលាការដែលមានសមត្ថកិច្ចក្នុងករណីតុលាការនៃការជំនុំជម្រះលើកទី១ បានធ្វើការជំនុំជម្រះលើរឿងក្តីដែលខ្លួនគ្មានសមត្ថកិច្ច។ ជាគោលការណ៍តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវផ្ទេររឿងក្តីទៅតុលាការ (សាលាដំបូង) ដែលមានសមត្ថកិច្ចដោយផ្ទាល់វិញ ដោយមិនចាំបាច់បញ្ជូនរឿងក្តីនោះ ត្រលប់ទៅតុលាការដើមដែលបានចេញសាលក្រមនៃការជំនុំជម្រះលើកទី១វិញពោលគឺតុលាការជំនុំជម្រះលើរឿងក្តីដែលខ្លួនគ្មានសមត្ថកិច្ច។ ឧទាហរណ៍៖ ដើមចោទប្តឹងលែងលះជាមួយនឹងចុងចម្លើយ។ ដើមចោទមានលំនៅឋាននៅខេត្តក្រចេះ ហើយចុងចម្លើយមានលំនៅឋាននៅខេត្តកំពង់ចាម ពួកគេបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅខេត្តកំពង់ចាម។ បន្ទាប់មកដើមចោទ និងចុងចម្លើយបានរស់នៅខេត្តសៀមរាបអស់រយៈពេលចំនួន៥ឆ្នាំ ក្នុងអំឡុងពេលដើមចោទប្តឹងលែងលះជាមួយនឹងចុងចម្លើយពេលប៉ុន្មានឆ្នាំចុងក្រោយអ្នកទាំងពីរមានទំនាស់នឹងគ្នា ចុងចម្លើយបានចាកចេញពីសៀមរាបមករស់នៅភ្នំពេញ។ ដើមចោទបានប្តឹងលែងលះចុងចម្លើយ មកសាលាដំបូងរាជធានីភ្នំពេញ ហើយសាលាដំបូងនេះក៏បានចាត់ការលើបណ្តឹង និងចេញសាលក្រមបន្ទាប់មកចុងចម្លើយបានប្តឹងឧទ្ធរណ៍នឹងសាលក្រមនោះ។ ក្នុងករណីតុលាការនៃបណ្តឹងឧទ្ធរណ៍យល់ឃើញថាតុលាការនៃការជំនុំជម្រះលើកទី១បានធ្វើការជំនុំជម្រះលើរឿងក្តីដែលខ្លួនគ្មានសមត្ថកិច្ច ដូចនេះតុលាការនៃបណ្តឹងឧទ្ធរណ៍នឹងលុបចោលសាលក្រមដើម ហើយផ្ទេររឿងក្តីទៅតុលាការដែលមានសមត្ថកិច្ចគឺសមត្ថកិច្ច

[49] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៨០

[50] មេរៀនស្តីពីបណ្តឹងឧទ្ធរណ៍ ឧទ្ទេសនាមដោយ លោកមេធាវី អ៊ីវ ប៉ូលី

សាលាដំបូងខេត្តសៀមរាប។ ដោយសារនៅក្នុងរឿងក្តីទាក់ទងនឹងឋានៈបុគ្គល សមត្ថកិច្ចជម្រះក្តីជាសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូង ដែលមានសមត្ថកិច្ចលើលំនៅឋានរបស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គល។

# ជំពូកទី៣
# បណ្តឹងសាទុក្ខ

ប្រសិនបើនៅក្រោយពេលដែលសាលាឧទ្ធរណ៍បានចេញសាលដីកា ភាគីនៅតែមិនខុសចិត្តទៀត នោះភាគីអាចធ្វើបណ្តឹងសាទុក្ខទៅតុលាការកំពូលដែលជាតុលាការនៃការជំនុំជម្រះលើកចុងក្រោយ។ យ៉ាងណាមិញបណ្តឹងសាទុក្ខ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលត្រូវគោរពតាមលំហូរនីតិវិធីដូចជា ការដាក់ពាក្យបណ្តឹងសាទុក្ខតាមរបៀបនៃការធ្វើបណ្តឹងសាទុក្ខមានកម្មវត្ថុ និងល័ក្ខខ័ណ្ឌឱ្យបានគ្រប់គ្រាន់ អានុភាពនៃការដាក់ពាក្យបណ្តឹងសាទុក្ខ និងបន្ថែមជាមួយបណ្តឹងសាទុក្ខបន្ទាប់បន្សំ ការដកពាក្យបណ្តឹងសាទុក្ខ នីតិវិធីនិងការជំនុំជម្រះនៃបណ្តឹងសាទុក្ខ និងចុងក្រោយការចេញសាលដីកានៃការជំនុំជម្រះបណ្តឹងសាទុក្ខ។ ដើម្បីឱ្យកាន់តែច្បាស់នៅខាងក្រោមនេះនឹងធ្វើការបកស្រាយអំពីលំហូរនីតិវិធីទាំងអស់ដូចជា៖

## ផ្នែកទី១៖ និយមន័យនៃបណ្តឹងសាទុក្ខ

អត្ថន័យទូទៅបណ្តឹងសាទុក្ខ គឺជាប្រភេទនៃបណ្តឹងឧបាស្រ័យមួយដែលទាមទារឱ្យតុលាការកំពូលដើម្បីវិនិច្ឆ័យពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវចំពោះការអនុវត្តច្បាប់ក្នុងសាលក្រម ឬ សាលដីកាចុងក្រោយ។ ចំពោះអត្ថន័យបណ្តឹងសាទុក្ខនៅក្នុងរឿងរដ្ឋប្បវេណី គឺជាបណ្តឹងឧបាស្រ័យទៅតុលាការកំពូលចំពោះសាលដីកាចុងក្រោយនៃការជំនុំជម្រះលើកទី២របស់សាលាឧទ្ធរណ៍ ឬ សាលដីកាចុងក្រោយដែលត្រូវបានជំនុំជម្រះលើកទី១របស់សាលាឧទ្ធរណ៍តាមបញ្ញត្តិច្បាប់ពិសេស ឬ មួយក៏ជាសាលក្រមចុងក្រោយដែលបានជំនុំជម្រះលើកទី១ ដោយសាលាដំបូងក្នុងករណីដែលភាគីបានព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍ ប៉ុន្តែរក្សាទុកនូវសិទ្ធិប្តឹងសាទុក្ខដែលហៅថាបណ្តឹងសាទុក្ខផ្លោះ។[51] ដោយឡែកតុលាការដែលជំនុំជម្រះលើបណ្តឹងសាទុក្ខហៅថា "តុលាការនៃបណ្តឹងសាទុក្ខ" ហើយការជំនុំជម្រះនេះហៅថា "ការជំនុំជម្រះលើកចុងក្រោយ ឬ ការជំនុំជម្រះលើកទី២"។ បានសេចក្តីថាការជំនុំជម្រះនៃបណ្តឹងសាទុក្ខ គឺការជំនុំជម្រះលើអង្គច្បាប់ដែលតុលាការកំពូលវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃសាលក្រម ឬ សាលដីកាដើម ពោលគឺពិនិត្យមើលជាថ្មីម្តងទៀតទៅលើសាលក្រម ឬ សាលដីកាដើម ដោយផ្អែកទៅលើធនធានដែលត្រូវបានប្រើប្រាស់សម្រាប់វិនិច្ឆ័យនៅក្នុងសាលក្រម ឬ សាលដីកាដើមនោះ ហេតុដូច្នេះខុសគ្នាពីការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ដែលធ្វើការទទួលស្គាល់នូវអង្គហេតុថ្មីឡើងវិញ ឬ អាចផ្អែកទៅលើធនធានថ្មីដែលសម្រាប់ប្រើប្រាស់ក្នុងការវិនិច្ឆ័យ ពោលគឺវិនិច្ឆ័យទាំងលើអង្គហេតុ និងអង្គច្បាប់។ ក្នុងន័យនេះជាគោលការណ៍តុលាការនៃបណ្តឹងសាទុក្ខ ត្រូវបានចងដោយអង្គហេតុដែលត្រូវបានទទួលស្គាល់ជាស្ថាពរដោយស្របច្បាប់ក្នុងសាលក្រម ឬ សាលដីកាដើម។ យ៉ាងណាមិញបើភាគីណាម្ខាងបានប្តឹងសាទុក្ខ ហើយភាគី

[51] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៨៣

ម្ខាងទៀតបានប្តឹងតបដែលបណ្តឹងនេះហៅថាបណ្តឹងសាទុក្ខបន្ទាប់បន្សំ។ ជារួមមកបណ្តឹងសាទុក្ខមានបីប្រភេទដូចជាបណ្តឹងសាទុក្ខ បណ្តឹងសាទុក្ខឆ្លោះ និងបណ្តឹងសាទុក្ខបន្ទាប់បន្សំ។

**ផ្នែកទី២៖ មូលហេតុ និងកម្មវត្ថុនៃបណ្តឹងសាទុក្ខ**

ដើម្បីធ្វើឡើងនូវបណ្តឹងសាទុក្ខ គឺត្រូវមានមូលហេតុ និងកម្មវត្ថុត្រឹមត្រូវ។ មូលហេតុ និងកម្មវត្ថុនៃបណ្តឹងសាទុក្ខនឹងធ្វើការបកស្រាយដូចនៅក្រោម៖

**១. មូលហេតុនៃបណ្តឹងសាទុក្ខ**

ភាគីមិនអាចធ្វើបណ្តឹងសាទុក្ខបាន ដោយគ្រាន់តែផ្អែកទៅលើមូលដ្ឋានថាខ្លួនរងការខូចផលប្រយោជន៍ពីសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃបណ្តឹងសាទុក្ខនោះទេ។ ហេតុដូចនេះហើយដែលនាំឱ្យមានការប្តឹងសាទុក្ខនេះកើតឡើងមានមូលហេតុពីរយ៉ាងដូចជា៖

មូលហេតុទូទៅ គឺចង់សម្តៅទៅលើការវិនិច្ឆ័យ ឬ ការសម្រេចសេចក្តីរបស់តុលាការផ្ទុយពីរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងៗដែលបានជះឥទ្ធិពលលើសាលក្រម ឬ សាលដីកា។[52] ការសម្រេចសេចក្តីរបស់តុលាការជាន់ទាបផ្ទុយពីរដ្ឋធម្មនុញ្ញនៅត្រង់នេះ មានន័យថាក្នុងករណីបទដ្ឋានគតិយុត្តដែលយកមកអនុវត្តជាដើម គឺមោឃភាពដោយផ្ទុយនឹងរដ្ឋធម្មនុញ្ញ ប៉ុន្តែគេបកស្រាយថាមានអានុភាព ឬ ក្នុងករណីបទដ្ឋានគតិយុត្តមានអានុភាពដោយស្របតាមរដ្ឋធម្មនុញ្ញ ប៉ុន្តែគេបកស្រាយថាមោឃភាព ហើយមិនបានយកមកអនុវត្ត។ ម៉្យាងវិញទៀតចំពោះការសម្រេចសេចក្តីរបស់តុលាការជាន់ទាបផ្ទុយនឹងច្បាប់ ឬ បទដ្ឋានគតិយុត្តវិញ គឺជាភាពដែលមានកំហុសក្នុងការបកស្រាយច្បាប់ ឬ បទដ្ឋានគតិយុត្ត។[53] ឧទាហរណ៍៖ ភាគីដែលឈ្នះក្តីទាំងស្រុងនៅក្នុងការជំនុំជម្រះរបស់សាលាឧទ្ធរណ៍ គឺភាគីនោះគ្មានផលប្រយោជន៍ក្នុងការប្តឹងសាទុក្ខទេ ប៉ុន្តែបើភាគីនោះធ្វើការប្តឹងសាទុក្ខបែបនេះនឹងត្រូវបានលើកចោល ដោយសារបណ្តឹងសាទុក្ខនេះផ្ទុយនឹងច្បាប់។ ប្រសិនបើតុលាការនៃបណ្តឹងសាទុក្ខទទួលស្គាល់ថាមានកំហុស ឬ ការបំពានច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀតនៅក្នុងការចាត់ចែងនីតិវិធី ឬ ក្នុងការវិនិច្ឆ័យរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ ហើយបែបនេះមានឥទ្ធិពលទៅលើការវិនិច្ឆ័យដែលបានបង្ហាញក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលដីកានោះពិតប្រាកដមែន ទើបបណ្តឹងសាទុក្ខនោះមានមូលហេតុត្រឹមត្រូវ។

មូលហេតុដាច់ខាតវិញនោះ គឺសម្តៅទៅលើការខុសនីតិវិធីធ្ងន់ធ្ងរ។[54] ហើយការខុសនីតិវិធីធ្ងន់ធ្ងរនេះមានដូចជា៖

---

[52] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៨៤

[53] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៨៤

[54] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៨៥

➢ តុលាការដែលចេញសាលដីកា ឬ សាលក្រមមិនត្រូវបានចាត់តាំងដោយស្របទៅនឹងច្បាប់។ ឧទាហរណ៍៖ សាលដីកាដែលចេញដោយបុគ្គលដែលគ្មានលក្ខណៈសម្បត្តិជាចៅក្រម ឬ ចៅក្រម០២នាក់ចេញសាលក្រមដែលត្រូវធ្វើដោយក្រុមប្រឹក្សាជំនុំជម្រះ០៣នាក់ ឬ សាលដីកាដែលចេញដោយចៅក្រមដែលមិនមែនជាចៅក្រមនៅពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។

➢ ចៅក្រមដែលច្បាប់មិនអនុញ្ញាតឱ្យចូលរួមក្នុងការចេញសាលដីកា ឬ សាលក្រមតែបានចូលរួម។ ជាគោលការណ៍មានតែចៅក្រម ដែលបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដែលជាមូលដ្ឋាននៃការចេញសាលក្រម ឬ សាលដីកាប៉ុណ្ណោះ ទើបអាចចេញសាលក្រម ឬ សាលដីកាបាន។ ឧទាហរណ៍៖ ចៅក្រមដែលបានវិនិច្ឆ័យ និងចេញសាលដីកា ឬ សាលក្រម ទោះបីជាមានមូលហេតុនៃការដកហូតចៅក្រមក៏ដោយ ដូចជាសហព័ទ្ធរបស់ចៅក្រមជាភាគីក្នុងរឿងក្តី ឬ ចៅក្រម និងភាគីធ្លាប់មានរឿងក្តីពីមុនមក។[55]

➢ ភាពផ្ទុយនឹងបញ្ញត្តិស្តីពីសមត្ថកិច្ចផ្តាច់មុខរបស់តុលាការ។ ឧទាហរណ៍៖ ពាក្យបណ្តឹងលែងលះបានដាក់ទៅសាលាដំបូងខុស ពីសាលាដំបូងដែលមានសមត្ថកិច្ចនៅទីលំនៅរបស់ភាគី។

➢ ការខ្វះសិទ្ធិតំណាងដែលកំណត់ដោយច្បាប់ សិទ្ធិតំណាងដោយអាណត្តិ ឬ ការប្រគល់សិទ្ធិចាំបាច់សម្រាប់អ្នកតំណាងដើម្បីធ្វើសកម្មភាពបណ្តឹង។ មានន័យថាជននោះបានធ្វើសកម្មភាពក្នុងនាមជាអ្នកអាណាព្យាបាលទូទៅ ទាំងខ្លួនមិនមែនជាអ្នកអាណាព្យាបាលទូទៅ ឬ មេធាវីដែលមិនបានទទួលការប្រគល់សិទ្ធិបានធ្វើសកម្មភាពបណ្តឹង។

➢ ភាពផ្ទុយនឹងបញ្ញត្តិស្តីពីការបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ។ ដូច្នេះក្នុងករណីច្បាប់បានបញ្ញត្តិឱ្យបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ ប៉ុន្តែនៅពេលទាញហេតុផលដោយផ្ទាល់មាត់មិនបានធ្វើជាសាធារណៈទេ ទាំងគ្មានការព្រួយបារម្ភពីការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈទាល់តែសោះ។ ផ្ទុយមកវិញប្រសិនបើភាពជាសាធារណៈបណ្តាលឱ្យខូចសណ្តាប់ធ្នាប់សាធារណៈ ឬ ករណីដែលបញ្ញត្តិពិសេសនៅក្នុងច្បាប់ នោះសាលសវនាការនៃការទាញហេតុផលដោយផ្ទាល់មាត់ មិនត្រូវធ្វើជាសាធារណៈទេ។

➢ សាលក្រម ឬ សាលដីកាគ្មានសំអាងហេតុ ឬ មានសំអាងហេតុតែផ្ទុយនឹងគ្នា។ ចំពោះភាពគ្មានសំអាងហេតុ គឺជាសំអាងហេតុដែលខ្វះខាតទាំងស្រុង ឬ មួយផ្នែក ដើម្បីឈានដល់ការចេញសេចក្តីសម្រេចបញ្ចប់។ ម្យ៉ាងទៀតភាពមានសំអាងហេតុតែផ្ទុយគ្នា គឺជាសំអាងហេតុដែលសរសេរខ្លឹមសារមុនក្រោយផ្ទុយគ្នាចំពោះចំណុចសំខាន់ដែលមានឥទ្ធិពលខ្លាំងដល់សាលក្រម ឬ សាលដីកា។ ឧទាហរណ៍៖ ខ្លឹមសារដែលសរសេរក្នុងសំអាងហេតុ ផ្ទុយគ្នានឹងចំនួនទឹកប្រាក់ដែលត្រូវបង្គាប់ឱ្យបង់។

---

[55] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៧

### ២. កម្មវត្ថុនៃបណ្តឹងសាទុក្ខ

កម្មវត្ថុនៃបណ្តឹងសាទុក្ខ គឺសម្តៅលើសេចក្តីសម្រេចដែលអាចប្តឹងសាទុក្ខបានមានតែសេចក្តីសម្រេចចុងក្រោយនោះចេញពីសាលាដំបូង ឬ សាលាឧទ្ធរណ៍ទាំងអស់ ប៉ុន្តែការចេញសេចក្តីសម្រេចនេះមិនទាន់ចូលជាស្ថាពរ។ ម៉្យាងទៀតក្នុងករណីពិសេស ប្រសិនបើភាគីមានការព្រមព្រៀងគ្នាប្តឹងសាទុក្ខផ្លោះទៅតុលាការកំពូលថាមិនធ្វើបណ្តឹងឧទ្ធរណ៍នៅក្រោយពេលដែលសាលាដំបូងចេញសាលក្រម ដោយរក្សាសិទ្ធិធ្វើបណ្តឹងសាទុក្ខហើយបានធ្វើលិខិតជាលាយលក្ខណ៍អក្សរនោះ ភាគីអាចធ្វើបណ្តឹងសាទុក្ខទៅតុលាការកំពូលបានតែម្តងដោយមិនចាំបាច់ឆ្លងកាត់សាលាឧទ្ធរណ៍ក៏បាន។ ចំពោះការយល់ព្រមដើម្បីផ្លោះសាលាឧទ្ធរណ៍ទៅតុលាការកំពូលនេះអាចធ្វើបានក្នុងករណីដែលជារឿងក្តីផ្នែករដ្ឋប្បវេណី ឬ ពាណិជ្ជកម្មដែលតម្លៃកម្មវត្ថុនៃបណ្តឹងមិនលើសពី ៥,០០០,០០០ រៀល។[56]

ដោយឡែកកម្មវត្ថុដែលមិនអាចប្តឹងសាទុក្ខបានមានដូចជា៖

➢ សាលក្រមរបៀប ឬ ដីកាសម្រេច ឬ សេចក្តីសម្រេចដែលមិនមែនជាសាលក្រម ឬ សាលដីកាមិនអាចយកមកធ្វើបណ្តឹងសាទុក្ខបាននោះឡើយ។ ចំពោះសាលក្រមរបៀបមិនអាចយកមកធ្វើជាមូលដ្ឋានសម្រាប់ធ្វើបណ្តឹងសាទុក្ខដោយឯករាជ្យបានឡើយ ការប្តឹងត្រូវផ្អែកលើសាលក្រម ឬ សាលដីកាចុងក្រោយ។ ប្រសិនបើគេបានប្តឹងសាទុក្ខចំពោះសាលក្រមចុងក្រោយ ឬ សាលដីកាចុងក្រោយ សាលក្រមរបៀបនោះក៏ជាកម្មវត្ថុនៃការវិនិច្ឆ័យជាមួយគ្នានៅតុលាការកំពូលផងដែរ។ ដូចគ្នានេះផងដែរចំពោះសេចក្តីសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្តី ដែលជាប់ជាមួយនឹងសាលក្រម ឬ សាលដីកាចុងក្រោយក៏មិនអាចយកមកធ្វើជាមូលដ្ឋានសម្រាប់ការធ្វើបណ្តឹងសាទុក្ខដោយឯករាជ្យតែឯងបានឡើយ។ [57]

## ផ្នែកទី៣៖ ល័ក្ខខ័ណ្ឌនៃបណ្តឹងសាទុក្ខ

ជាទូទៅគ្រប់បណ្តឹងទាំងអស់អាចមានប្រសិទ្ធិភាព ឬ អាចនិយាយម្យ៉ាងទៀតថាអាចមាននូវអានុភាពទៅបាន លុះត្រាតែបណ្តឹងនោះបង្កើតឡើងស្របទៅតាមច្បាប់ដែលបានចូលជាធរមានរួចហើយ។ មិនខុសគ្នាពីបណ្តឹងផ្សេងៗនោះទេ បណ្តឹងសាទុក្ខអាចកើតមាន ឬ អាចធ្វើបានឱ្យមាននូវអានុភាព គឺតម្រូវឱ្យការធ្វើបណ្តឹងនោះស្របទៅតាមច្បាប់ ឬ ល័ក្ខខ័ណ្ឌស្របច្បាប់នៃបណ្តឹងសាទុក្ខនោះ។ បណ្តឹងសាទុក្ខនេះទៀតសោតក៏មាននូវល័ក្ខខ័ណ្ឌពីរយ៉ាងដែលច្បាប់បានតម្រូវ៖

➢ អ្នកមានសិទ្ធិធ្វើបណ្តឹងសាទុក្ខ

➢ អំឡុងពេលនៃការធ្វើបណ្តឹងសាទុក្ខ

---

[56] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៦០, មាត្រា២៨៣

[57] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២៨៦

### ១. អ្នកមានសិទ្ធិធ្វើបណ្តឹងសាទុក្ខ

អ្នកដែលមានសិទ្ធិធ្វើបណ្តឹងសាទុក្ខ គឺជាភាគីដែលមិនពេញចិត្តនឹងសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១របស់សាលាដំបូង ឬ សាលដីកាចុងក្រោយនៃការជំនុំជម្រះលើកទី២របស់សាលាឧទ្ធរណ៍ ឬ សាលដីកាចុងក្រោយក្នុងនាមការជំនុំជម្រះលើកទី១របស់សាលាឧទ្ធរណ៍ដែលមិនទាន់ចូលជាស្ថាពរ។ នៅក្នុងនីតិវិធីនៃបណ្តឹងសាទុក្ខត្រូវបានហៅថា ដើមបណ្តឹងសាទុក្ខ និងចុងបណ្តឹងសាទុក្ខ។ មានន័យថាបណ្តឹងសាទុក្ខអាចធ្វើឡើងដោយដើមចោទ ឬ ចុងចម្លើយ ឬ ដើមបណ្តឹងឧទ្ធរណ៍ ឬ ចុងបណ្តឹងឧទ្ធរណ៍ ដែលមិនពេញចិត្ត និងបាត់បង់នូវផលប្រយោជន៍ដោយសារសាលក្រមនៃការជំនុំជម្រះលើកទី១របស់សាលាដំបូង ឬ សាលដីកានៃការជំនុំជម្រះលើកទី២របស់សាលាឧទ្ធរណ៍។ ម្យ៉ាងទៀតភាគីដែលបាត់បង់ផលប្រយោជន៍ គឺជាភាគីដែលចាញ់ក្តីទាំងស្រុង ឬ មួយផ្នែក ភាគីនោះមានសិទ្ធិក្នុងការធ្វើបណ្តឹងសាទុក្ខ ហេតុនេះភាគីដែលឈ្នះក្តីទាំងស្រុងគ្មានផលប្រយោជន៍ក្នុងការធ្វើបណ្តឹងសាទុក្ខទេ ពោលគឺគ្មានសិទ្ធិប្តឹងសាទុក្ខ។ ក្នុងករណីដែលភាគីដែលឈ្នះក្តីទាំងស្រុងធ្វើបណ្តឹងសាទុក្ខ បណ្តឹងសាទុក្ខនោះនឹងត្រូវបានតុលាការលើកចោលដោយមូលហេតុផ្ទុយនឹងច្បាប់។

សិទ្ធិប្តឹងសាទុក្ខកើតឡើង ក្នុងករណីដែលមានការព្រមព្រៀងរវាងភាគីទាំងសងខាងជាមុនថាមិនប្តឹងឧទ្ធរណ៍ ការព្រមព្រៀងមិនប្តឹងឧទ្ធរណ៍នោះគឺជាការព្រមព្រៀងផ្លោះទៅបណ្តឹងសាទុក្ខតែម្តង។ ចំពោះការយល់ព្រមដើម្បីផ្លោះសាលាឧទ្ធរណ៍ទៅតុលាការកំពូលនេះ អាចធ្វើបានក្នុងករណីដែលជារឿងក្តីផ្នែករដ្ឋប្បវេណី ឬ ពាណិជ្ជកម្ម ដែលតម្លៃកម្មវត្ថុនៃបណ្តឹងមិនលើសពី ៥,០០០,០០០ រៀល។[58]

### ២. អំឡុងពេលនៃការធ្វើបណ្តឹងសាទុក្ខ

អំឡុងពេលនៃការធ្វើបណ្តឹងសាទុក្ខ គឺចង់សម្តៅទៅលើថេរវេលាកំណត់ឱ្យមានបណ្តឹងសាទុក្ខ។ អំឡុងពេលនៃបណ្តឹងសាទុក្ខនេះបែងចែកជាពីរទៀតគឺៈ

- អំឡុងពេលនៃការដាក់ពាក្យបណ្តឹងសាទុក្ខ
- អំឡុងពេលនៃការដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ

#### ២.១. អំឡុងពេលនៃការដាក់ពាក្យបណ្តឹងសាទុក្ខ

យោងតាមមាត្រា២៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចែងថានីតិវិធីបណ្តឹងសាទុក្ខអនុវត្តដូចគ្នានឹងនីតិវិធីបណ្តឹងឧទ្ធរណ៍ ដូច្នេះអំឡុងពេលនៃការដាក់ពាក្យបណ្តឹងសាទុក្ខក៏ដូចគ្នា គឺមានអំឡុងពេល ០១ខែ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រម ឬ សាលដីកា ឬ ថ្ងៃដែលបានជូនដំណឹងអំពីការសម្រេចច្រានចោល ឬ លើកចោលនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ។ នៅត្រង់នេះមានន័យថាប្រសិនបើភាគីណាមួយ

---

[58] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២៨៣ កថាខណ្ឌទី២

ដែលបានទទួលការបញ្ជូននូវលិខិតសាលក្រមរបស់សាលាដំបូង ឬ សាលដីការបស់សាលាឧទ្ធរណ៍ បើភាគីមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់តុលាការជាន់ទាបនោះ ដោយមូលហេតុថាការសម្រេចនោះផ្ទុយពីច្បាប់ ឬ មិនស្របតាមរដ្ឋធម្មនុញ្ញ ឬ បទដ្ឋានគតិយុត្តផ្សេងៗទៀត ឬ ខុសនីតិវិធីធ្ងន់ធ្ងរ ភាគីអាចមានសិទ្ធិក្នុងការដាក់ពាក្យប្តឹងសាទុក្ខចំពោះសេចក្តីសម្រេចនៅរយៈពេល ០១ខែ។[59]

ផ្ទុយមកវិញប្រសិនបើភាគីមិនបានធ្វើការប្តឹងសាទុក្ខក្នុងអំឡុងពេលដែលច្បាប់បានកំណត់នោះទេ មានន័យថាសេចក្តីសម្រេចរបស់តុលាការជាន់ទាបបានចូលជាស្ថាពរដែលមានអានុភាពអនុវត្ត។ កាលណាសេចក្តីសម្រេចរបស់តុលាការជាន់ទាបចូលជាស្ថាពរដែលអាចមានអានុភាពអនុវត្តហើយនោះ មានន័យថាភាគីដែលមិនសុខចិត្តនឹងសេចក្តីសម្រេចនោះ នឹងបាត់បង់សិទ្ធិក្នុងការធ្វើបណ្តឹងសាទុក្ខហើយ។ ម្យ៉ាងវិញទៀតក្នុងករណីដែលភាគីបានទទួលនូវការជូនដំណឹងអំពីដីកាសម្រេចច្រានចោល ឬ លើកចោលនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ហើយភាគីមិនបានធ្វើការប្តឹងក្នុងរយៈពេល ០១ខែ ដូចដែលច្បាប់បានកំណត់នោះទេ ភាគីក៏បាត់បង់នូវសិទ្ធិធ្វើបណ្តឹងសាទុក្ខនេះដែរ ចំពោះដីកាសម្រេចនៅត្រង់នេះ គឺសម្តៅទៅលើតែសេចក្តីសម្រេចដែលចេញដោយសាលាដំបូងដែលជាតុលាការនៃនីតិវិធីជំនុំជម្រះលើកទី១ប៉ុណ្ណោះ។ បន្ថែមពីនេះសេចក្តីសម្រេចនេះមិនមែនចេញដោយសាលាឧទ្ធរណ៍នោះទេ ព្រោះថាសាលាឧទ្ធរណ៍មិនអាចចេញសាលក្រមកំបាំងមុខបាននោះទេ។[60] ក្នុងករណីអនុវត្តដូចគ្នាទៅនឹងករណីភាគីមានការព្រមព្រៀងគ្នា ជាលាយលក្ខណ៍អក្សរថាពួកគេនឹងមិនប្តឹងឧទ្ធរណ៍ តែរក្សាទុកប្តឹងសាទុក្ខ។

### ២.២. អំឡុងពេលនៃការដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខក្នុងករណីដែលភាគីដើមបណ្តឹងសាទុក្ខ នៅពេលដាក់ពាក្យបណ្តឹងពុំបានសរសេរបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខនៅក្នុងពាក្យបណ្តឹងទេ នោះដើមបណ្តឹងសាទុក្ខត្រូវតែដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្តឹងសាទុក្ខទៅតុលាការនៃបណ្តឹងសាទុក្ខ ក្នុងអំឡុងពេល ៣០ថ្ងៃ បន្ទាប់ពីបានទទួលការបញ្ជូនលិខិតទទួលពាក្យបណ្តឹង។[61] ប្រសិនបើភាគីសរសេរបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខផ្ទុយនឹងមាត្រា២៨៩ នៃនីតិវិធីរដ្ឋប្បវេណីដែលស្តីពីការសរសេរមូលហេតុនៃបណ្តឹងសាទុក្ខ នោះតុលាការនៃបណ្តឹងសាទុក្ខត្រូវកំណត់អំឡុងពេលសមរម្យ ហើយបង្គាប់ឱ្យដើមបណ្តឹងសាទុក្ខកែតម្រូវនូវចំណុចខ្វះខាតក្នុងអំឡុងពេលនោះដោយចេញដីកាសម្រេច។

---

[59] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២៦៤ កថាខណ្ឌទី១

[60] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២៧៣

[61] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២៨៩ កថាខណ្ឌទី១

ចំពោះអំឡុងពេលនៃការដាក់ពាក្យបណ្តឹងសាទុក្ខ និងការដាក់លិខិតបញ្ជាក់អំពីមូលហេតុមិនអាចពន្យារពេលបានទេ។

**ផ្នែកទី៤៖ របៀបធ្វើបណ្តឹងសាទុក្ខ**

ក្នុងការធ្វើបណ្តឹងសាទុក្ខ គឺដើមបណ្តឹងសាទុក្ខតម្រូវឱ្យសរសេរពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរទៅតុលាការដើម ភាគីដើមបណ្តឹងសាទុក្ខពុំត្រូវធ្វើបណ្តឹងដោយផ្ទាល់មាត់ដូចនឹងនីតិវិធីរឿងក្តីដែលមានតម្លៃទឹកប្រាក់តិចនោះទេ។ ចំពោះពាក្យបណ្តឹងសាទុក្ខត្រូវសរសេរនូវចំណុចមួយចំនួនដូចជា៖

- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ភាគី និងអ្នកតំណាងដែលច្បាប់បានកំណត់។ ការសរសេរឈ្មោះ និងអាសយដ្ឋានរបស់ភាគីពិតជាមានសារៈសំខាន់ណាស់ ដើម្បីឱ្យតុលាការធ្វើការបញ្ជូនដីកាកោះ និងលិខិត ឬ ឯកសារផ្សេងៗទៅភាគីនោះ។
- សញ្ញាណនៃសាលក្រម ឬ សាលដីកាចុងក្រោយដែលតុលាការដើមបានចេញ និងសេចក្តីដែលប្តឹងសាទុក្ខនោះ។ ការសរសេរបែបនេះ គឺចង្អុលបង្ហាញអំពីអ្វីដែលខ្លួនមិនសុខចិត្ត និងអ្វីដែលខ្លួនទាមទារ ដើម្បីឱ្យតុលាការយកមកធ្វើការវិនិច្ឆ័យ ដោយហេតុថាតុលាការមិនអាចធ្វើការវិនិច្ឆ័យនូវអ្វីដែលភាគីមិនបានធ្វើការឧបាស្រ័យឡើយជាគោលការណ៍តុលាការអកម្ម។
- មូលហេតុនៃបណ្តឹងសាទុក្ខ វាជាចំណុចសំខាន់នៃពាក្យបណ្តឹងសាទុក្ខព្រោះតុលាការនៃបណ្តឹងសាទុក្ខវិនិច្ឆ័យទៅលើអង្គច្បាប់ ហេតុនេះពាក្យបណ្តឹងត្រូវសរសេរអំពីមូលហេតុនៃបណ្តឹងនោះ។

បន្ទាប់ពីភាគីធ្វើបណ្តឹងសាទុក្ខតាមល័ក្ខខ័ណ្ឌរួច ត្រូវដាក់ពាក្យទៅតុលាការដើម។ ហើយតុលាការដើមត្រូវធ្វើការធ្វើឱ្យបានឆាប់រហ័សនូវពាក្យបណ្តឹងសាទុក្ខនោះ និងសំណុំរឿងទៅតុលាការនៃបណ្តឹងសាទុក្ខ។[62] ជារួមការអនុវត្តនៃការដាក់ពាក្យបណ្តឹងសាទុក្ខស្រដៀងទៅនឹងការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ដែរ។

**ផ្នែកទី៥៖ អានុភាពនៃពាក្យបណ្តឹងសាទុក្ខ**

កាលណាដែលពាក្យបណ្តឹងសាទុក្ខបានទៅដល់តុលាការនៃបណ្តឹងសាទុក្ខ នោះមានន័យថាអានុភាពនៃបណ្តឹងសាទុក្ខនឹងកើតមាន។ នេះក៏មិនខុសគ្នាអំពីអានុភាពនៃពាក្យបណ្តឹងឧទ្ធរណ៍ដែរ ដែលអានុភាពនោះអាចធ្វើឱ្យបង្អាក់ ឬ រារាំងការចូលជាស្ថាពរនៃសាលក្រម ឬ សាលដីកាដើម អានុភាពនៃការផ្ទេរការជំនុំជម្រះក្តី និងអានុភាពអវិភាគនៃបណ្តឹងសាទុក្ខ។

**១. អានុភាពបង្អាក់ការចូលជាស្ថាពរ**

អានុភាពបង្អាក់ការចូលជាស្ថាពរគឺមានន័យថា នៅពេលដែលភាគីដើមបណ្តឹងសាទុក្ខបានដាក់ពាក្យបណ្តឹងសាទុក្ខក្នុងអំឡុងពេល ដែលច្បាប់បានកំណត់នោះវានឹងមានអានុភាពបង្អាក់ ឬ រារាំងការចូលជាស្ថាពរ

[62] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២៨៧

របស់សាលក្រម ឬ សាលដីកាដើម។ ត្រង់នេះមានន័យថាប្រសិនបើភាគីដើមបណ្ដឹងសាទុក្ខបានដាក់ពាក្យបណ្ដឹងក្នុងរយៈពេល០១ខែដែលជារយៈពេលច្បាប់កំណត់នោះ បន្ទាប់ពីទទួលបានលិខិតសាលក្រម ឬ សាលដីកា ទោះបីជារយៈពេលនៃការចូលជាស្ថាពរនៃសាលក្រម ឬ សាលដីកាបានចូលមកដល់ ឬ បានកន្លងផុតក៏ដោយក៏សាលក្រម ឬ សាលដីកានោះមិនអាចចូលជាស្ថាពរដែរ។ ផ្ទុយមកវិញក្នុងករណីសាលក្រម ឬ សាលដីកាដែលភ្ជាប់នឹងប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ចំពោះផ្នែកណាមួយតាមពាក្យសុំដោយដីកាសម្រេច សាលក្រម ឬ សាលដីកានោះមានអានុភាពអនុវត្តបាន ទោះបីមានបណ្ដឹងសាទុក្ខក៏ដោយ។[63]

**២. អានុភាពនៃការផ្ទេរការជំនុំជម្រះក្ដី**

នៅពេលដែលមានពាក្យបណ្ដឹងសាទុក្ខ នោះការជំនុំជម្រះដោយតុលាការជាន់ទាប ពោលគឺសាលាដំបូង ឬ សាលាឧទ្ធរណ៍ នឹងត្រូវផ្ទេរទៅតុលាការនៃបណ្ដឹងសាទុក្ខជាអ្នកមានសមត្ថកិច្ចក្នុងការវិនិច្ឆ័យ និងចេញសេចក្ដីសម្រេច ព្រោះបណ្ដឹងសាទុក្ខមិនស្ថិតក្រោមសមត្ថកិច្ចរបស់តុលាការជាន់ទាបនោះទេ។

**៣. អានុភាពអវិភាគនៃបណ្ដឹងសាទុក្ខ**

អានុភាពអវិភាគនៃបណ្ដឹងសាទុក្ខ គឺជាការដែលដើមបណ្ដឹងសាទុក្ខបានធ្វើឧបាស្រ័យតែផ្នែកណាមួយនៃសាលក្រម ឬ សាលដីកាដើមក៏ដោយក៏បណ្ដឹងនោះមានអានុភាពបង្អាក់ការចូលជាស្ថាពរ និងមានការផ្ទេរការជំនុំជម្រះត្រូវកើតមានឡើងទៅលើការទាមទារទាំងអស់ដែលមាននៅក្នុងសាលក្រម ឬ សាលដីកានោះ។ បានសេចក្ដីថាទោះបីជាដើមបណ្ដឹងសាទុក្ខធ្វើបណ្ដឹងឧបាស្រ័យតែមួយផ្នែកនៅក្នុងសាលក្រម ឬ សាលដីកាដើម ក៏ផ្នែកដែលមិនបានធ្វើឧបាស្រ័យមិនអាចចូលជាស្ថាពរទេ ហើយក៏មិនអាចយកទៅអនុវត្តបានឡើយ។ លើកលែងតែមានការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នដោយតុលាការដើម ឬ ក៏ដោយតុលាការនៃបណ្ដឹងសាទុក្ខទើបផ្នែកដែលមិនបានធ្វើឧបាស្រ័យនោះអាចអនុវត្តបាន។[64]

**ផ្នែកទី៦៖ បណ្ដឹងសាទុក្ខផ្លោះ**

បណ្ដឹងសាទុក្ខផ្លោះ គឺជាបណ្ដឹងមួយដែលគូភាគីបានព្រមព្រៀងគ្នាមិនប្ដឹងឧទ្ធរណ៍នៅក្រោយពេលដែលតុលាការបានចេញសាលក្រមចុងក្រោយដែលត្រូវបានធ្វើការជំនុំជម្រះលើកទី១ ដោយសាលាដំបូង ដោយរក្សាទុកនូវសិទ្ធិប្ដឹងសាទុក្ខ បណ្ដឹងសាទុក្ខអាចធ្វើទៅតុលាការកំពូលដោយផ្ទាល់បាន។ បណ្ដឹងសាទុក្ខអាចធ្វើចំពោះសាលក្រមចុងក្រោយរបស់សាលាដំបូងបាន លើកលែងតែករណីដែលបានកំណត់ខាងក្រោមនេះ៖

- គូភាគីបានព្រមព្រៀងគ្នាមិនប្ដឹងឧទ្ធរណ៍ ដោយរក្សាទុកសិទ្ធិប្ដឹងសាទុក្ខក្រោយពេលតុលាការបានចេញសាលក្រមចុងក្រោយដោយរំលងការវិនិច្ឆ័យបណ្ដឹងឧទ្ធរណ៍។

---

[63] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៨៦, មាត្រា២៧៣, មាត្រា១៩៣ កថាខណ្ឌទី២

[64] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៩៣ កថាខណ្ឌទី២, មាត្រា១៩៦ និងមាត្រា២៩៨

➢ សេចក្ដីព្រមព្រៀងដែលមិនប្ដឹងឧទ្ធរណ៍ខាងលើនេះពុំមានអានុភាពឡើយ ប្រសិនបើមិនបានធ្វើលិខិតជាលាយលក្ខណ៍អក្សរ។

➢ ភាគីទាំងសងខាងមិនមានវិវាទអំពីការទទួលស្គាល់អង្គហេតុទេ នៅក្នុងសាលក្រមជំនុំជម្រះលើកទី១។ បានសេចក្ដីថាបើគូភាគីមិនមានទំនាស់ អំពីការទទួលស្គាល់អង្គហេតុនៅក្នុងសាលក្រមជំនុំជម្រះលើកទី១ទេ អាចប្ដឹងសាទុក្ខបាន ដោយសារតែតុលាការនៃបណ្ដឹងសាទុក្ខវិនិច្ឆ័យតែអង្គច្បាប់តែប៉ុណ្ណោះ។

## ផ្នែកទី៧៖ បណ្ដឹងសាទុក្ខបន្ទាប់បន្សំ

បណ្ដឹងសាទុក្ខបន្ទាប់បន្សំ គឺជាបណ្ដឹងមួយដែលធ្វើឡើងដោយឆ្លៀតឱកាសនៅពេលមានបណ្ដឹងសាទុក្ខ។ មានន័យថានៅក្រោយពេលដែលដើមបណ្ដឹងសាទុក្ខធ្វើបណ្ដឹងសាទុក្ខចំពោះសាលក្រម ឬ សាលដីកាដែលចេញដោយតុលាការដើមនោះ ចុងបណ្ដឹងសាទុក្ខបានឆ្លៀតឱកាសពេលនឹងធ្វើបណ្ដឹងឧបាស្រ័យជាមួយនឹងបណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងសាទុក្ខ ដើម្បីទាមទារនូវចំណុចដែលខ្លួនចាញ់នៅក្នុងសាលក្រម ឬ សាលដីការបស់តុលាការដើម។ ជាឧទាហរណ៍៖ សាលាឧទ្ធរណ៍បានចេញសាលដីកាឱ្យដើមបណ្ដឹងឧទ្ធរណ៍ឈ្នះ ៣ចំណុចក្នុងចំណោម ៤ចំណុចដែលគាត់បានទាមទារ ហើយដើមបណ្ដឹងឧទ្ធរណ៍មិនធ្វើបណ្ដឹងសាទុក្ខនោះទេ។ ប៉ុន្តែបើចុងបណ្ដឹងឧទ្ធរណ៍ បានធ្វើបណ្ដឹងសាទុក្ខឧបាស្រ័យនឹងសាលដីកាដែលតុលាការឧទ្ធរណ៍បានចេញសេចក្ដីសម្រេចបញ្ចប់។ ពេលនោះដើមបណ្ដឹងឧទ្ធរណ៍ក៏បានធ្វើបណ្ដឹងសាទុក្ខដែរ ដែលបណ្ដឹងសាទុក្ខនោះជាបណ្ដឹងសាទុក្ខបន្ទាប់បន្សំ ដែលអមទៅជាមួយបណ្ដឹងសាទុក្ខរបស់ចុងបណ្ដឹងឧទ្ធរណ៍។

អំឡុងពេលធ្វើបណ្ដឹងសាទុក្ខបន្ទាប់បន្សំ ដូចគ្នានឹងបណ្ដឹងសាទុក្ខដែរ ពោលគឺ ០១ខែ គិតចាប់ពីថ្ងៃទទួលបានលិខិតសាលក្រម ឬ ថ្ងៃដែលបានជូនដំណឹងអំពីដីកាសម្រេចច្រានចោល ឬ លើកចោលនូវបណ្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខចំពោះអំឡុងពេល ០១ខែ មិនអាចពន្យារពេលបានទេ។ ប៉ុន្តែក្នុងករណីបើបណ្ដឹងសាទុក្ខបន្ទាប់បន្សំនោះធ្វើឡើងមិនហួសអំឡុងពេលប្ដឹងសាទុក្ខ និងមានល័ក្ខខ័ណ្ឌនៃបណ្ដឹងសាទុក្ខគ្រប់គ្រាន់ ករណីនេះហៅថាបណ្ដឹងសាទុក្ខបន្ទាប់បន្សំបានធ្វើឡើងដោយឯករាជ្យ។ ចំពោះរបៀបធ្វើពាក្យបណ្ដឹងសាទុក្ខបន្ទាប់បន្សំ និងនីតិវិធីនៃបណ្ដឹងសាទុក្ខបន្ទាប់បន្សំ រមែងត្រូវអនុលោមទៅតាមបញ្ញត្តិនៃបណ្ដឹងឧទ្ធរណ៍ ពោលគឺត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្ដឹងសាទុក្ខបន្ទាប់បន្សំ។

## ផ្នែកទី៨៖ នីតិវិធីនៃបណ្ដឹងសាទុក្ខ

យើងបានសិក្សារួចមកហើយអំពីបណ្ដឹងសាទុក្ខដែលមានកម្មវត្ថុ ល័ក្ខខ័ណ្ឌ និងរបៀបធ្វើបណ្ដឹងសាទុក្ខព្រមទាំងអានុភាពបណ្ដឹងសាទុក្ខ និងបន្ថែមនូវបណ្ដឹងសាទុក្ខបន្ទាប់បន្សំ។ ហើយក្នុងផ្នែកនេះនឹងមានការបកស្រាយអំពីដំណើរនៃនីតិវិធីនៃបណ្ដឹងសាទុក្ខមានដូចជា ការទទួល ការពិនិត្យ និងការបញ្ជូនពាក្យបណ្ដឹងសាទុក្ខ។

**១. ការទទួលពាក្យបណ្តឹងសាទុក្ខ**

ពាក្យបណ្តឹងសាទុក្ខ ត្រូវដាក់នៅតុលាការដើមដែលបានចេញសាលក្រម ឬ សាលដីកានោះក្នុងអំឡុងពេលកំណត់សម្រាប់ធ្វើបណ្តឹងសាទុក្ខ។ ដោយឡែកតុលាការដើមពុំមានសមត្ថកិច្ចពិនិត្យពាក្យបណ្តឹងសាទុក្ខទេ គ្រាន់តែជាតុលាការដែលទទួលពាក្យបណ្តឹងសាទុក្ខរបស់ភាគីតែប៉ុណ្ណោះ។ បន្ទាប់មកតុលាការដើមត្រូវធ្វើការផ្ញើឱ្យបានឆាប់រហ័សនូវពាក្យបណ្តឹងសាទុក្ខនោះ និងសំណុំរឿងទៅតុលាការនៃបណ្តឹងសាទុក្ខ។

**២. ការពិនិត្យពាក្យបណ្តឹងសាទុក្ខ**

នៅពេលតុលាការដើមបញ្ជូនមកតុលាការនៃបណ្តឹងសាទុក្ខ បន្ទាប់ពីបានទទួលការដាក់ពាក្យបណ្តឹងសាទុក្ខរបស់ភាគីនៃដើមបណ្តឹងសាទុក្ខរួចហើយ តុលាការនៃបណ្តឹងសាទុក្ខត្រូវពិនិត្យថាពាក្យបណ្តឹងនេះត្រឹមត្រូវតាមច្បាប់ឬទេ។ ក្នុងករណីតុលាការនៃបណ្តឹងសាទុក្ខពិនិត្យឃើញថា ពាក្យបណ្តឹងសាទុក្ខមិនបានសរសេរចំណុចសំខាន់ដែលចែងក្នុងមាត្រា២៦៥ និងមាត្រា២៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ តុលាការនៃបណ្តឹងសាទុក្ខត្រូវតែបង្គាប់ឱ្យភាគីដើមបណ្តឹងសាទុក្ខកែតម្រូវពាក្យបណ្តឹងនោះ ក្នុងអំឡុងពេលមួយដែលច្បាប់បានកំណត់។ ផ្ទុយមកវិញប្រសិនបើភាគីដើមបណ្តឹងសាទុក្ខ មិនបានកែប្រែពាក្យបណ្តឹងសាទុក្ខនោះទេក្នុងរយៈពេលមួយដែលតុលាការបានកំណត់ តុលាការនៃបណ្តឹងសាទុក្ខត្រូវលើកចោលពាក្យបណ្តឹងសាទុក្ខនោះដោយដីកាសម្រេច។ ចំណែកប្រាក់ប្រដាប់ក្តីក៏តុលាការនៃបណ្តឹងសាទុក្ខ និងបណ្តឹងសាទុក្ខបន្ទាប់បន្សំត្រូវពិនិត្យផងដែរលើពន្ធដាក់ពាក្យសុំដែលត្រូវគណនាទៅតាមតម្លៃកម្មវត្ថុនៃបណ្តឹងដែលមានចំនួន២ដង នៃពន្ធដាក់ពាក្យសុំ។

**៣. ការបញ្ជូនពាក្យបណ្តឹងសាទុក្ខ**

ប្រសិនបើពាក្យបណ្តឹងសាទុក្ខត្រឹមត្រូវតាមទម្រង់ច្បាប់ តុលាការត្រូវបញ្ជូនពាក្យបណ្តឹងសាទុក្ខនោះទៅឱ្យចុងបណ្តឹងសាទុក្ខ។ ក្នុងករណីដែលមិនអាចបញ្ជូនពាក្យបណ្តឹងសាទុក្ខ (រាប់បញ្ចូលនូវករណីដែលភាគីមិនបានបង់ប្រាក់ប្រដាប់ក្តីដែលចាំបាច់ដើម្បីបញ្ជូនពាក្យបណ្តឹងសាទុក្ខ) ត្រូវអនុលោមទៅតាមករណីដែលពាក្យបណ្តឹងសាទុក្ខមិនត្រឹមត្រូវតាមទម្រង់ច្បាប់ មាត្រា២៦៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**៤. ការកំណត់កាលបរិច្ឆេទនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់**

នៅក្រោយពេលដែលបានទទួលពាក្យបណ្តឹងសាទុក្ខ និងពិនិត្យឃើញថាបណ្តឹងនោះធ្វើឡើងត្រឹមត្រូវហើយតុលាការនៃបណ្តឹងសាទុក្ខ ត្រូវធ្វើការកំណត់នូវកាលបរិច្ឆេទសម្រាប់ធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានឆាប់រហ័ស និងធ្វើការកោះហៅគូភាគីឱ្យចូលរួម។ គួរបញ្ជាក់ផងដែរថាបណ្តឹងសាទុក្ខធ្វើឡើងដោយផ្អែកលើមូលហេតុនៃភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្តដែលមានឥទ្ធិពលលើសាលដីកា ឬសាលក្រម និងខុសនីតិវិធីធ្ងន់ធ្ងរប៉ុណ្ណោះ ដូច្នេះតុលាការធ្វើការវិនិច្ឆ័យតែទៅលើអង្គច្បាប់ប៉ុណ្ណោះ។ ហេតុនេះ តុលាការមិនចាំបាច់ធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីរៀបចំនូវសេចក្តីអះអាងរបស់ភាគីកំណត់ចំណុចវិវាទ

និងរៀបចំភស្តុតាងទេ នីតិវិធីនេះត្រូវបានធ្វើនៅក្នុងនីតិវិធីជំនុំជម្រះលើកទី១រួចហើយ ហេតុដូចនេះតុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់តែម្តង។ នៅក្រោយពេលដែលបានកំណត់កាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់រួចរាល់ តុលាការត្រូវធ្វើការបញ្ជូនដីកាកោះទៅភាគីដើម្បីឱ្យភាគីចូលរួមក្នុងនីតិវិធី។ ការបញ្ជូនដីកាកោះអាចធ្វើការបញ្ជូនទៅភាគីជាមួយគ្នានឹងលិខិតទទួលពាក្យបណ្តឹងលើកលែងតែករណីដែលតុលាការលើកចោលពាក្យបណ្តឹងសាទុក្ខនោះ ឬ តុលាការបង្គាប់ឱ្យដើមបណ្តឹងសាទុក្ខដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ឬ មួយតុលាការចេញដីកាបង្គាប់ឱ្យកែតម្រូវជាដើម។

## ផ្នែកទី៩៖ ការជំនុំជម្រះបណ្តឹងសាទុក្ខ

នៅដំណាក់កាលជំនុំជម្រះលើកចុងក្រោយ ត្រូវគោរពតាមគោលការណ៍នៃការជំនុំជម្រះបណ្តឹងសាទុក្ខ និងមានការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងសាទុក្ខដែលមានចំនួនពីរលើក។

### ១. គោលការណ៍នៃការជំនុំជម្រះបណ្តឹងសាទុក្ខ

ជាគោលការណ៍ដើម្បីធ្វើការវិនិច្ឆ័យ និងចេញសាលដីកានៃបណ្តឹងសាទុក្ខតុលាការត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ លើកលែងតែករណីដែលតុលាការច្រានចោលបណ្តឹងសាទុក្ខដោយមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់។[65] ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើឡើងត្រឹមទំហំដែលភាគីបានទាមទារឱ្យផ្លាស់ប្តូរនៅក្នុងសាលក្រម ឬ សាលដីកានៃតុលាការដើមតែប៉ុណ្ណោះ។[66] ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើតែទៅលើចំណុចណាដែលបានធ្វើការឧបាស្រ័យតែប៉ុណ្ណោះ ចំពោះចំណុចណាដែលភាគីមិនបានធ្វើឧបាស្រ័យតុលាការមិនអាចយកមកធ្វើការវិនិច្ឆ័យឡើយ។ ការកំណត់បែបនេះ គឺទាញចេញពីគោលការណ៍ហាមឃាត់មិនឱ្យផ្លាស់ប្តូរដែលធ្វើឱ្យខូចប្រយោជន៍ភាគី។ មានន័យថាការផ្លាស់ប្តូរសាលក្រម ឬ សាលដីការបស់តុលាការដើមអាចធ្វើបានត្រឹមតែកម្រិតដែលបានធ្វើឧបាស្រ័យបណ្តឹងសាទុក្ខតែប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើមានពាក្យបណ្តឹងសាទុក្ខបន្ទាប់បន្សំ ការវិនិច្ឆ័យរបស់តុលាការនៃបណ្តឹងសាទុក្ខក៏ត្រូវប្រែប្រួលតាមការទាមទារនោះដែរ។

### ២. ការទាញហេតុផលដោយផ្ទាល់មាត់ករណីបណ្តឹងសាទុក្ខលើកទី១

តុលាការនៃបណ្តឹងសាទុក្ខ ត្រូវធ្វើការជំនុំជម្រះលើកចុងក្រោយចំពោះសាលក្រម ឬ សាលដីកាដើមដែលការជំនុំជម្រះបណ្តឹងសាទុក្ខ តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់។ ចំពោះក្នុងការទាញហេតុផលដោយផ្ទាល់មាត់ករណីបណ្តឹងសាទុក្ខលើកទី១មានសមាសភាពចៅក្រមជំនុំជម្រះ ពោលគឺសភារដ្ឋប្បវេណីនៃតុលាការកំពូលមានសមត្ថកិច្ចជំនុំជម្រះបណ្តឹងសាទុក្ខ ចំពោះសាលដីកាផ្នែករដ្ឋប្បវេណីរបស់

[65] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៩៤

[66] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៧២ កថាខណ្ឌទី១

សាលាឧទ្ធរណ៍ ឬ សាលក្រមរដ្ឋប្បវេណីរបស់សាលាដំបូង។ ដូច្នេះការជំនុំជម្រះក្តីត្រូវធ្វើឡើងដោយមានចៅក្រម ចំនួន ០៥រូប ក្នុងនោះមានចៅក្រម ០១រូប ត្រូវបានចាត់តាំងឱ្យធ្វើជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ ដើម្បីធ្វើជាអ្នកដឹកនាំកិច្ចដំណើរការនៃនីតិវិធី។[67]

ចំណែកឯសកម្មភាពនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាគោលការណ៍នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់របស់តុលាការនៃបណ្តឹងសាទុក្ខ គឺជាការវិនិច្ឆ័យតែទៅលើអង្គច្បាប់ប៉ុណ្ណោះ។ ដោយតុលាការនៃបណ្តឹងសាទុក្ខធ្វើការពិនិត្យ និងវិនិច្ឆ័យតែអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃសាលក្រម ឬ សាលដីកាចុងក្រោយលើការអនុវត្តច្បាប់តែប៉ុណ្ណោះ។ ការវិនិច្ឆ័យនេះ គឺផ្អែកទៅលើការអះអាងរបស់ភាគី និងភស្តុតាងដែលបានដាក់នៅតុលាការដើមតាមរយៈការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវក្នុងការអនុវត្តច្បាប់ចំពោះអង្គហេតុដែលបានទទួលស្គាល់នៅតុលាការដើម ហើយតុលាការនៃបណ្តឹងសាទុក្ខមិនទទួលស្គាល់អង្គហេតុឡើងវិញទេ។ ការវិនិច្ឆ័យលើអង្គច្បាប់របស់តុលាការនៃបណ្តឹងសាទុក្ខ គឺដើម្បីឱ្យមានការឯកភាពគ្នារបស់តុលាការជាន់ទាបក្នុងការបកស្រាយច្បាប់ និងអនុវត្តច្បាប់។ ការទាញហេតុផលដោយផ្ទាល់មាត់នៅតុលាការនៃបណ្តឹងសាទុក្ខតម្រូវឱ្យភាគីធ្វើសេចក្តីថ្លែងការណ៍។ ដោយហេតុថាសេចក្តីសម្រេចរបស់តុលាការនៃបណ្តឹងសាទុក្ខជាសេចក្តីសម្រេចចុងក្រោយបិទផ្លូវតវ៉ា ហើយសេចក្តីសម្រេចនេះអាចក្លាយទៅជាយុត្តិសាស្ត្រសម្រាប់ឱ្យតុលាការជាន់ទាបធ្វើការអនុវត្តតាម។[68]

### ៣. ការទាញហេតុផលដោយផ្ទាល់មាត់ករណីបណ្តឹងសាទុក្ខលើកទី២

ការទាញហេតុផលដោយផ្ទាល់មាត់ករណីបណ្តឹងសាទុក្ខលើកទី២ គឺជាករណីដែលតុលាការនៃបណ្តឹងសាទុក្ខបានបដិសេធនូវសាលដីកាដើម ហើយបានបញ្ជូនរឿងក្តីនោះត្រលប់ទៅតុលាការដើមវិញ ឬ ផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា ដើម្បីឱ្យធ្វើការជំនុំជម្រះរឿងក្តីនោះម្តងទៀត បន្ទាប់មកនៅពេលដែលតុលាការដើមដែលបានទទួលការបញ្ជូនរឿងក្តីត្រលប់មកវិញ ឬ តុលាការដែលបានទទួលការផ្ទេររឿងក្តីនោះបានចេញសាលដីកា ហើយបើមានភាគីណាមួយមិនសុខចិត្តនឹងសេចក្តីសម្រេចនោះ និងបានប្តឹងសាទុក្ខម្តងទៀត ដូចនេះនីតិវិធីតុលាការនៃបណ្តឹងសាទុក្ខលើកទី២នឹងធ្វើការជំនុំជម្រះដោយសភាពេញអង្គ។ សភាពេញអង្គត្រូវបង្កើតឱ្យមានដំណើរការដោយដីកាសម្រេចរបស់ប្រធានតុលាការកំពូល ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខលើកទី២ ក្នុងករណីដែលមានការស្នើសុំឱ្យមានការពិនិត្យ និងសម្រេចឡើងវិញចំពោះរឿងក្តីណាមួយពីព្រះមហាក្សត្រដែលជាព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ សភាពេញអង្គប្រព្រឹត្តទៅ

---

[67] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤ មាត្រា៥៩ និង មាត្រា៦៥

[68] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា២៨៣

តាមការកោះអញ្ជើញរបស់ប្រធានតុលាការកំពូល សភានេះត្រូវមានសមាសភាពចៅក្រមយ៉ាងតិច ០៩រូប ដែលមានចៅក្រមជាតំណាងនៃសភាទាំងអស់នៃតុលាការកំពូល ហើយសភាពេញអង្គដំណើរការក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល។[69]

រីឯសកម្មភាពនៃការទាញហេតុផលដោយផ្ទាល់មាត់ នៅក្នុងករណីបណ្តឹងសាទុក្ខលើកទី២នេះ គឺធ្វើទៅតាមលំដាប់លំដោយដូចគ្នានឹងសកម្មភាពទាញហេតុផលដោយផ្ទាល់មាត់ នៅក្នុងបណ្តឹងសាទុក្ខលើកដំបូងដែរ ប៉ុន្តែអាចមានសាក្សី និងអ្នកជំនាញចូលរួមក្នុងសវនាការដែរ ដោយប្រធានក្រុមប្រឹក្សាអាចអញ្ជើញសាក្សី និងអ្នកជំនាញនោះមកឈរមុខតុលាការ ដើម្បីឱ្យអ្នកទាំងនោះជួយបំភ្លឺដល់រឿងក្តី ដើម្បីឱ្យតុលាការងាយស្រួលក្នុងការវិនិច្ឆ័យ និងចេញសាលដីកា។ ករណីមានបន្ថែមសាក្សី និងអ្នកជំនាញនេះដោយសារតែបណ្តឹងសាទុក្ខលើកទី២ តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការពិនិត្យឡើងវិញទាំងអង្គហេតុ និងអង្គច្បាប់។

## ផ្នែកទី១០៖ ការបញ្ចប់បណ្តឹងសាទុក្ខ

បន្ទាប់ពីធ្វើការជំនុំជម្រះដោយទាញហេតុផលដោយផ្ទាល់មាត់រួច តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការបញ្ចប់បណ្តឹងសាទុក្ខដោយមានពីរយ៉ាងគឺ ការបញ្ចប់បណ្តឹងសាទុក្ខដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ ឬ ការបញ្ចប់បណ្តឹងសាទុក្ខដោយឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ។

### ១. ការបញ្ចប់បណ្តឹងសាទុក្ខដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ

ការបញ្ចប់បណ្តឹងសាទុក្ខដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ អាចធ្វើឡើងក្នុងទម្រង់ពីរយ៉ាងគឺ អាចជាការបញ្ចប់បណ្តឹងសាទុក្ខដោយស្វ័យប្រវត្តិ ឬ ការបញ្ចប់បណ្តឹងសាទុក្ខដោយសកម្មភាពភាគី។

#### ១.១. ការបញ្ចប់បណ្តឹងសាទុក្ខដោយស្វ័យប្រវត្តិ

ការបញ្ចប់បណ្តឹងសាទុក្ខដោយស្វ័យប្រវត្តិមានន័យថា កាលណាភាគីណាមួយបានទទួលមរណភាពហើយគ្មានអ្នកណាទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងនាំឱ្យបណ្តឹងនោះត្រូវបានបញ្ចប់ដោយស្វ័យប្រវត្តិ។ តាមធម្មតាបើទោះបីជាមានភាគីណាម្ខាងបានទទួលមរណភាពក៏ដោយ ក៏សន្តតិជនរបស់ភាគីនោះនឹងត្រូវទទួលបន្តនូវនីតិវិធីនៃបណ្តឹងដែលបានធ្វើពីមុនមក ហើយនីតិវិធីបណ្តឹងសាទុក្ខនោះមិនត្រូវបានបញ្ចប់ទេ។ ក្នុងករណីដែលសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងបានរលត់ដោយសារការរួមបញ្ចូលគ្នានៃនីតិបុគ្គលនាំឱ្យសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងត្រូវធ្លាក់លើបុគ្គលតែម្នាក់ ហើយដើមបណ្តឹងសាទុក្ខ និងចុងបណ្តឹងសាទុក្ខបានក្លាយទៅជាបុគ្គលតែមួយ ដោយសារតែភាគីណាម្ខាងបានទទួលបន្តនូវឋានៈតាមផ្លូវបណ្តឹងរបស់ភាគីម្ខាងទៀត ដោយសារការរួមបញ្ចូលគ្នានៃនីតិបុគ្គល ឬ ដោយសន្តតិកម្ម ដូច្នេះតុលាការនឹងចេញសាលដីកាបញ្ចប់បណ្តឹងដោយស្វ័យប្រវត្តិដោយសារតែមានភាគីជាបុគ្គលតែមួយ។

[69] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤ មាត្រា៦២

### ១.២. ការបញ្ចប់បណ្តឹងសាទុក្ខដោយសកម្មភាពភាគី

ការបញ្ចប់បណ្តឹងដោយសកម្មភាពរបស់ភាគី ក្នុងនោះអាចជាសកម្មភាពនៃការដកពាក្យបណ្តឹង ការលះបង់ ឬ ការទទួលស្គាល់ការទាមទារ និងការសះជាតាមផ្លូវបណ្តឹងរបស់ភាគីនឹងធ្វើឱ្យសកម្មភាពនៃបណ្តឹងត្រូវបញ្ចប់ផងដែរ៖

➢ ការដកពាក្យបណ្តឹង ទោះបីជានីតិវិធីបណ្តឹងកំពុងដំណើរការក៏ដោយក៏ដើមបណ្តឹងសាទុក្ខអាចធ្វើការដកពាក្យបណ្តឹងទាំងអស់ ឬ មួយផ្នែកបានដែររហូតដល់ពេលដែលតុលាការនៃបណ្តឹងសាទុក្ខចេញសាលដីកាចុងក្រោយ។ ដោយហេតុថាបណ្តឹងជាសកម្មភាពរបស់ដើមបណ្តឹងសាទុក្ខក្នុងការទាមទារឱ្យតុលាការនៃបណ្តឹងសាទុក្ខចេញសេចក្តីសម្រេចលុបចោល ឬ កែប្រែសាលដីកាដើម ឬ សាលក្រមដើម ដូច្នេះការដកពាក្យបណ្តឹងសាទុក្ខធ្វើឡើងតាមឆន្ទៈរបស់ដើមបណ្តឹងសាទុក្ខប៉ុណ្ណោះ ហេតុនេះចុងបណ្តឹងសាទុក្ខពុំមានសិទ្ធិដកពាក្យបណ្តឹងសាទុក្ខឡើយ។ ក៏ប៉ុន្តែក្រោយពីចុងបណ្តឹងសាទុក្ខបានដាក់ឯកសារត្រៀមតាមការបង្គាប់របស់តុលាការ ឬ បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់រួចហើយ ការដកពាក្យបណ្តឹងសាទុក្ខដោយផ្អែកទៅលើឆន្ទៈរបស់ដើមបណ្តឹងសាទុក្ខពុំមានអានុភាពឡើយ លើកលែងតែមានការយល់ព្រមពីចុងបណ្តឹងសាទុក្ខផងដែរ ពីព្រោះថាចុងបណ្តឹងសាទុក្ខបានឆ្លើយតបទៅនឹងការទាមទាររបស់ដើមបណ្តឹងសាទុក្ខ ហើយចុងបណ្តឹងសាទុក្ខក៏មានផលប្រយោជន៍ក្នុងការទទួលបានសាលដីកាឈ្នះក្តីដែរ។[70] ចំណែកឯល័ក្ខខ័ណ្ឌនៃការដកពាក្យបណ្តឹងសាទុក្ខវិញនោះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ប៉ុន្តែការដកពាក្យបណ្តឹងរបស់ដើមបណ្តឹងសាទុក្ខអាចធ្វើឡើងដោយផ្ទាល់មាត់ក៏បាននៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។ នៅពេលដែលមានការដកពាក្យបណ្តឹងដោយផ្ទាល់មាត់ក្រឡាបញ្ជីត្រូវចុះអំពីការដកពាក្យបណ្តឹងនោះនៅក្នុងកំណត់ហេតុនៃការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីកុំឱ្យមានវិវាទនៅពេលក្រោយ។ ប្រសិនបើការដកពាក្យបណ្តឹងធ្វើឡើងជាលាយលក្ខណ៍អក្សរ តុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ជូនលិខិតដកពាក្យបណ្តឹងនោះទៅចុងបណ្តឹងសាទុក្ខ។ បើចុងបណ្តឹងសាទុក្ខមិនប្តឹងតវ៉ាក្នុងអំឡុងពេល០២សប្តាហ៍ បន្ទាប់ពីបានទទួលការបញ្ជូនលិខិតដកពាក្យបណ្តឹងទេ ត្រូវបានចាត់ទុកថាចុងបណ្តឹងសាទុក្ខបានយល់ព្រមនឹងការដកពាក្យបណ្តឹងនេះ។ បើដើមបណ្តឹងសាទុក្ខធ្វើការដកពាក្យបណ្តឹងដោយផ្ទាល់មាត់នៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ប៉ុន្តែចុងបណ្តឹងសាទុក្ខបានអវត្តមាននៅកាលបរិច្ឆេទនោះ តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការបញ្ជូនឯកសារចម្លងនៃកំណត់ហេតុ ដែលបានចុះអំពីការដកពាក្យបណ្តឹងនោះទៅចុងបណ្តឹងសាទុក្ខ។ ក្នុងអំឡុងពេល០២សប្តាហ៍បន្ទាប់ពីបានទទួលនូវការបញ្ជូននោះ បើចុងបណ្តឹងសាទុក្ខមិនបានធ្វើការតវ៉ាទេ ត្រូវចាត់ទុកថាខ្លួនបានយល់ព្រមចំពោះការដកពាក្យបណ្តឹងសាទុក្ខនោះផងដែរ។ ប៉ុន្តែបើ

[70] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២១៧ កថាខណ្ឌទី១

ដើមបណ្តឹងសាទុក្ខធ្វើការដកពាក្យបណ្តឹងដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដែលភាគីចុងបណ្តឹងសាទុក្ខមានវត្តមាននៅកាលបរិច្ឆេទនោះដែរ បើចុងបណ្តឹងសាទុក្ខមិនបានតវ៉ាក្នុងអំឡុងពេល០២សប្តាហ៍គិតចាប់ពីកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់នោះក៏ត្រូវចាត់ទុកថា ចុងបណ្តឹងសាទុក្ខបានយល់ព្រមចំពោះការដកពាក្យបណ្តឹងនោះដែរ។ ត្រូវចាត់ទុកថាដកពាក្យបណ្តឹងផងដែរ ក្នុងករណីដែលភាគីទាំងសងខាងមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយភាគីទាំងសងខាង មិនបានដាក់ពាក្យសុំឱ្យតុលាការនៃបណ្តឹងសាទុក្ខកំណត់កាលបរិច្ឆេទនោះជាថ្មីម្តងទៀត ក្នុងអំឡុងពេល០១ខែទេនោះក៏ត្រូវចាត់ទុកថាបានដកពាក្យបណ្តឹងសាទុក្ខដែរ។ ហើយបើភាគីទាំងសងខាងមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ពីរដងជាប់គ្នា ក៏ត្រូវចាត់ទុកថាបានដកពាក្យបណ្តឹងសាទុក្ខផងដែរ។[71] ដូចនេះការដកពាក្យបណ្តឹងសាទុក្ខអាចដកតែមួយផ្នែក ឬ ទាំងមូលនៅពេលដែលមានការដកពាក្យបណ្តឹងនោះត្រូវបានធ្វើឡើង ផ្នែកដែលត្រូវបានដក ឬ បណ្តឹងទាំងមូលត្រូវបានចាត់ទុកថាមិនបានចាត់ការតាំងពីដំបូង ហើយរឿងក្តីត្រូវរលត់ដោយអានុភាពប្រតិសកម្ម។ ពោលគឺត្រូវចាត់ទុកថាតុលាការមិនបានចាត់ការបណ្តឹងនោះតាំងពីដំបូងមកម្ល៉េះ ចំណែកឯសកម្មភាពរបស់តុលាការ និងភាគីដែលបានធ្វើកន្លងមករហូតដល់ពេលដកពាក្យបណ្តឹងសាទុក្ខនោះក៏ត្រូវបាត់បង់អានុភាពដែរ។ ប្រសិនបើមានការដកពាក្យបណ្តឹងសាទុក្ខ នោះនាំឱ្យអានុភាពនៃសាលដីកាដើម ឬ សាលក្រមដើមត្រូវចូលជាស្ថាពរ ក្នុងករណីអំឡុងពេលសម្រាប់ធ្វើបណ្តឹងសាទុក្ខបានកន្លងផុត ក៏ប៉ុន្តែដើមបណ្តឹងសាទុក្ខមិនអាចធ្វើការដកពាក្យបណ្តឹងសាទុក្ខបានឡើយ បើតុលាការនៃបណ្តឹងសាទុក្ខបានប្រកាសសាលដីកា។ យ៉ាងណាមិញនៅពេលដែលដើមបណ្តឹងសាទុក្ខបានធ្វើការដកពាក្យបណ្តឹងសាទុក្ខនៅមុនពេលចប់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដើមបណ្តឹងសាទុក្ខអាចដាក់ ឬ សុំឱ្យតុលាការនៃបណ្តឹងសាទុក្ខសងមកវិញនូវចំនួនពាក់កណ្តាលនៃពន្ធដាក់ពាក្យបណ្តឹងដែលខ្លួនបានបង់ទៅតុលាការរួចមកហើយ ។

- ការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារជាសេចក្តីថ្លែងការណ៍តាមផ្លូវបណ្តឹងដែលភាគីម្ខាងទទួលស្គាល់ពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការទាមទារ ហើយវិវាទរវាងភាគីទាំងសងខាងត្រូវបានដោះស្រាយដោយសេចក្តីថ្លែងការណ៍នេះ សកម្មភាពទាំងនេះនាំឱ្យបណ្តឹងត្រូវបានបញ្ចប់ដោយមិនចាំបាច់រង់ចាំសាលដីកាទេ។ ចំពោះល័ក្ខខ័ណ្ឌចាំបាច់ក្នុងការទទួលស្គាល់នូវការទាមទារ ភាគីចាំបាច់ត្រូវតែជាបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹង។ យ៉ាងណាមិញអានុភាពនៃការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារតុលាការនៃបណ្តឹងសាទុក្ខត្រូវពិនិត្យអំពីល័ក្ខខ័ណ្ឌនៃបណ្តឹង បើឃើញថាភាគីមានល័ក្ខខ័ណ្ឌគ្រប់គ្រាន់ក្នុងការលះបង់ ឬ ទទួលស្គាល់នូវ

[71] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២១៩

ការទាមទារក្រឡាបញ្ជីត្រូវចុះក្នុងកំណត់ហេតុនាំឱ្យបណ្តឹងត្រូវបានបញ្ចប់ ហើយកំណត់ហេតុនោះមានអានុភាពដូចគ្នានឹងសាលដីកាស្ថាពរដែរ។

➢ ការសះជាតាមផ្លូវបណ្តឹង គឺជាសកម្មភាពមួយដែលដើមបណ្តឹងសាទុក្ខ និងចុងបណ្តឹងសាទុក្ខធ្វើការសម្រុះសម្រួលគ្នាបញ្ចប់នូវនីតិវិធីបណ្តឹង ដោយត្រូវបង្ហាញខ្លួននៅចំពោះមុខតុលាការនៃបណ្តឹងសាទុក្ខនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។ ចំពោះល័ក្ខខ័ណ្ឌចាំបាច់នៃការសះជាតាមផ្លូវបណ្តឹងក៏ភាគីចាំបាច់ត្រូវតែជាបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹងសាទុក្ខ ដូច្នេះបើមានភាគីណាមួយជាបុគ្គលដែលត្រូវបានកម្រិតសមត្ថភាពបានធ្វើការសះជានោះពុំមានអានុភាពឡើយ។ អានុភាពនៃការសះជា មានអានុភាពបញ្ចប់បណ្តឹងដោយការសះជា ដែលបានកត់ត្រានៅក្នុងកំណត់ហេតុហើយលទ្ធផលនៃការសះជាតាមផ្លូវបណ្តឹងនេះនាំឱ្យនីតិវិធីនៃបណ្តឹងសាទុក្ខត្រូវបានបញ្ចប់ផងដែរ និងមានអានុភាពដូចគ្នាផងដែរនឹងសាលដីកាស្ថាពរ។ ប្រសិនបើក្នុងកំណត់ហេតុនេះមានចុះអំពីសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកជាក់ស្តែង ដោយមានការកំណត់ពេលអនុវត្តដូច្នេះកំណត់ហេតុសះជាមានអានុភាពអនុវត្តដែលក្លាយទៅជាលិខិតអនុវត្ត។ ប៉ុន្តែអានុភាពអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុមិនមានឡើយ ទោះបីជាកំណត់ហេតុសះជាមានអានុភាពដូចគ្នានឹងសាលដីកាស្ថាពរក៏ដោយដោយសារតែការសះជាតាមផ្លូវបណ្តឹង គឺជាការបញ្ចប់វិវាទដែលមានខ្លឹមសារនៃទំនាក់ទំនងគតិយុត្តផ្អែកលើការព្រមព្រៀងរបស់ភាគី ដែលមានលក្ខណៈខុសពីសាលដីកាដែលធ្វើការសម្រេចសេចក្តីដោយផ្អែកលើភស្តុតាងដែលអនុវត្តច្បាប់ចំពោះអង្គហេតុនោះ។ បើការសះជាតាមផ្លូវបណ្តឹងមានវិការៈភាគីអាចអះអាងអំពីមោឃភាព ឬការលុបចោលការសះជា នោះនីតិវិធីនៃការដោះស្រាយជម្លោះនេះមិនមែនជាការសុំជំនុំជម្រះសាជាថ្មីដូចករណីសាលដីកាទេ គឺគ្រាន់តែជាការស្នើសុំឱ្យតុលាការនៃបណ្តឹងសាទុក្ខកំណត់នូវកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់សាជាថ្មីតែប៉ុណ្ណោះ។ បើសិនជាមានពាក្យសុំឱ្យតុលាការនៃបណ្តឹងសាទុក្ខត្រូវកំណត់នូវកាលបរិច្ឆេទជាថ្មី ដោយមានមូលហេតុមានវិការៈក្នុងការសះជា។ បើការវិនិច្ឆ័យឃើញថាការសះជានោះមានវិការៈតុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការបញ្ជាក់ថាបណ្តឹងនោះមិនទាន់ត្រូវបានបញ្ចប់ទេ ហើយត្រូវបន្តការវិនិច្ឆ័យលើបណ្តឹងនោះ។ ប៉ុន្តែបើវិនិច្ឆ័យឃើញថា ការសះជាដែលបានធ្វើពីមុននោះមានសុពលភាព តុលាការនៃបណ្តឹងសាទុក្ខត្រូវចេញសាលដីកាដែលប្រកាសអំពីការបញ្ចប់បណ្តឹងដោយការសះជានោះ។ ចំពោះបន្ទុកនៃប្រាក់ប្រដាប់ក្តី ភាគីដែលត្រូវទទួលបន្ទុកនៃប្រាក់ប្រដាប់ក្តី គឺអាស្រ័យទៅលើការព្រមព្រៀងរបស់ភាគីនោះ ប៉ុន្តែប្រសិនបើភាគីគ្មានការព្រមព្រៀងគ្នាអំពីប្រាក់ប្រដាប់ក្តីទេ ភាគីនីមួយៗត្រូវទទួលបន្ទុកក្នុងការបង់រៀងៗខ្លួន។ បើការសះជាបានសម្រេចលទ្ធផលមុនពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដើមបណ្តឹងសាទុក្ខទទួលបានការសងមកវិញនូវចំនួនពាក់កណ្តាលនៃពន្ធដែលបានបង់រួចមកហើយ ។

## ២. ការបញ្ចប់បណ្តឹងសាទុក្ខដោយឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ

ផ្ទុយមកវិញបើមិនមានការបញ្ចប់បណ្តឹងសាទុក្ខ ដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការនោះទេ តុលាការនៃបណ្តឹងសាទុក្ខនឹងបញ្ចប់បណ្តឹងសាទុក្ខដោយចេញសាលដីកាក្នុងបីករណីដូចជា ការលើកចោលនូវបណ្តឹងសាទុក្ខដោយដីកាសម្រេច ឬ សាលដីកាច្រានចោលបណ្តឹងសាទុក្ខ ឬ សាលដីកាទទួលស្គាល់នូវបណ្តឹងសាទុក្ខ។

### ២.១. ការលើកចោលបណ្តឹងសាទុក្ខដោយដីកាសម្រេច

ការលើកចោលនូវបណ្តឹងសាទុក្ខនេះមានន័យថា បណ្តឹងសាទុក្ខនោះមិនបានធ្វើដោយស្របទៅតាមច្បាប់ ឬ ផ្ទុយពីច្បាប់ ហើយមិនអាចនឹងកែប្រែបាន ឬ លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខមិនត្រូវបានដាក់ទៅតុលាការតាមថេរវេលាដែលច្បាប់បានកំណត់ ឬ មួយក៏លិខិតបញ្ជាក់អំពីមូលហេតុនោះមិនបានដាក់ទៅតុលាការនៃបណ្តឹងសាទុក្ខ។ ហើយការលើកចោលមួយនេះ តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការលើកចោលដោយចេញនូវដីកាសម្រេច។ បន្ថែមពីនេះប្រសិនបើតុលាការនៃបណ្តឹងសាទុក្ខមិនបានចេញនូវដីកាសម្រេចលើកចោលបណ្តឹងសាទុក្ខនោះទេ ជាគោលការណ៍តុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ជូនឯកសារចម្លងនៃលិខិតបញ្ជាក់ពីមូលហេតុនៃបណ្តឹងសាទុក្ខទៅចុងបណ្តឹងសាទុក្ខ ហើយការធ្វើបែបនេះក្នុងគោលបំណងផ្តល់ឱកាសឱ្យចុងបណ្តឹងសាទុក្ខដាក់នូវឯកសារត្រៀម។[72]

### ២.២. សាលដីកាច្រានចោលបណ្តឹងសាទុក្ខ

ក្នុងការជំនុំជម្រះលើអង្គសេចក្តីតុលាការត្រូវមើល ជាបឋមទៅលើឯកសារជាលាយលក្ខណ៍អក្សរដែលមានដូចជា លិខិតពាក្យបណ្តឹង លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ឯកសារត្រៀមដំបូងដែលចុងបណ្តឹងសាទុក្ខបានដាក់ និងឯកសារផ្សេងៗទៀត ហើយប្រសិនបើតុលាការរកឃើញដោយផ្អែកលើឯកសារទាំងអស់នោះថាគ្មានមូលហេតុប្តឹងសាទុក្ខទេ តុលាការនៃបណ្តឹងសាទុក្ខអាចចេញសាលដីកាច្រានចោលនូវបណ្តឹងសាទុក្ខនោះដោយមិនចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់។ តុលាការនៃបណ្តឹងសាទុក្ខនៅតែអាចច្រានចោលពាក្យបណ្តឹងសាទុក្ខនោះ ទោះបីជាបានទាញហេតុផលដោយផ្ទាល់មាត់ហើយ ព្រោះថាបើតុលាការពិនិត្យ និងយល់ឃើញថាពុំមានមូលហេតុសម្រាប់ធ្វើបណ្តឹងសាទុក្ខទេ។[73]

### ២.៣. សាលដីកាទទួលស្គាល់បណ្តឹងសាទុក្ខ

តុលាការនៃបណ្តឹងសាទុក្ខទទួលស្គាល់ពាក្យបណ្តឹងសាទុក្ខ មានន័យថាពាក្យបណ្តឹងនោះធ្វើឡើងត្រឹមត្រូវតាមច្បាប់។ ដូចនេះកាលដែលតុលាការនៃបណ្តឹងសាទុក្ខទទួលស្គាល់នូវបណ្តឹងសាទុក្ខហើយ តុលាការត្រូវ

[72] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៨៤, មាត្រា២៩២

[73] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៨៦, មាត្រា២៧៧

លុបចោលនូវសាលក្រម និងសាលដីកាដើម។ ការបដិសេធចោលត្រង់នេះមានន័យថាតុលាការនៃការជំនុំជម្រះលើអង្គច្បាប់ លុបចោលនូវសាលក្រមដើម ឬ សាលដីកាដើម។

### ២.៣.១. ការបដិសេធចោល និងបញ្ជូនត្រលប់ទៅតុលាការដើមវិញ

ក្នុងករណីដែលតុលាការនៃបណ្ដឹងសាទុក្ខទទួលស្គាល់ថា ពាក្យបណ្ដឹងសាទុក្ខនោះមានមូលហេតុត្រឹមត្រូវ តុលាការនៃបណ្ដឹងសាទុក្ខត្រូវធ្វើការបដិសេធនូវសាលក្រម ឬ សាលដីកាដើម ហើយត្រូវបញ្ជូនរឿងក្ដីនោះត្រលប់ទៅតុលាការដើមវិញ។ ការបដិសេធចោលរឿងក្ដីនៃបណ្ដឹងសាទុក្ខគឺមានភាពខុសពីការលុបចោលរឿងក្ដីដោយតុលាការនៃបណ្ដឹងឧទ្ធរណ៍ ព្រោះថាក្រោយការបដិសេធចោលនូវសាលក្រម ឬ សាលដីកាដើមតុលាការនៃបណ្ដឹងសាទុក្ខពុំចាំបាច់ពិនិត្យ និងទទួលស្គាល់សាជាថ្មីទៅលើអង្គហេតុនៃរឿងក្ដីនោះទេ គ្រាន់តែបញ្ជូនរឿងក្ដីទៅតុលាការដើមវិញ។ ជាបឋមក្នុងករណីដែលមិនបានធ្វើការទទួលស្គាល់អង្គហេតុសាជាថ្មីមិនអាចធ្វើការជំនុំជម្រះចំពោះសាលក្រម ឬ សាលដីកាដើមទេតុលាការនៃបណ្ដឹងសាទុក្ខត្រូវបញ្ជូនរឿងក្ដីនោះទៅតុលាការដើមវិញ ឬ ក្នុងករណីដែលយល់ឃើញថា ការបញ្ជូនត្រលប់នោះមិនសមស្របទេ ដោយសារមានការកម្រិតនៃកថាខណ្ឌទី៣ មាត្រា២៩៩ ត្រូវផ្ទេររឿងក្ដីនោះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា។[74] ហើយតុលាការដែលបានទទួលនូវការបញ្ជូនត្រលប់មកវិញ ឬ ដែលបានទទួលនូវការផ្ទេរនោះ ត្រូវធ្វើការជំនុំជម្រះដោយធ្វើការទាញហេតុផលដោយផ្ទាល់មាត់សាជាថ្មី ចំពោះរឿងក្ដីនោះតាមនីតិវិធីនៃថ្នាក់ជំនុំជម្រះនោះ។ ការទាញហេតុផលដោយផ្ទាល់មាត់នេះទៀតសោតគឺជាការបើកឡើងវិញ និងបន្តនូវការទាញហេតុផលដោយផ្ទាល់មាត់ដែលត្រូវបានធ្វើពីមុនមក ហើយចៅក្រមដែលពាក់ព័ន្ធនឹងសាលដីកាដើម ឬ សាលក្រមដើម មិនអាចចូលរួមក្នុងការទាញហេតុផលដោយផ្ទាល់មាត់បានទេ។ ក្នុងករណីដែលមានការផ្លាស់ប្ដូរចៅក្រម នៅមុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ភាគីត្រូវធ្វើសេចក្ដីថ្លែងការណ៍នូវលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលបានធ្វើពីមុនមក។ ក្នុងការផ្លាស់ប្ដូរចៅក្រមដូចនេះ ព្រោះថាប្រសិនបើតុលាការដើមនៅតែធ្វើការវិនិច្ឆ័យដូចមុន ឬ នៅតែធ្វើការចាត់ចែងដូចមុននោះ ទោះជាតុលាការនៃបណ្ដឹងសាទុក្ខបានបញ្ជូនត្រលប់ទៅវិញប៉ុន្មានក៏ដោយ ក៏រឿងក្ដីនោះមិនអាចដោះស្រាយចប់ឡើយ។ សេចក្ដីវិនិច្ឆ័យលើអង្គហេតុដែលមានអានុភាពចងត្រូវបានកម្រិត តែសេចក្ដីវិនិច្ឆ័យអំពីអង្គហេតុដែលតុលាការនៃបណ្ដឹងសាទុក្ខអាចវិនិច្ឆ័យបានដូចជា អង្គហេតុដែលទាក់ទងទៅនឹងចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិប៉ុណ្ណោះ។ ជារួមមកវិញដើម្បីឱ្យមានអានុភាពចងក្នុងការវិនិច្ឆ័យនោះបាន គឺចៅក្រមណាដែលមានការពាក់ព័ន្ធនឹងសាលដីកា ឬ សាលក្រមដើមដែលត្រូវបានបដិសេធចោល មិនត្រូវអនុញ្ញាតឱ្យចូលរួមក្នុងការសម្រេចសេចក្ដីក្រោយបាននោះទេ។

[74] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៩៩

### ២.៣.២. ការបដិសេធចោល និងការផ្ទេររឿងក្តីទៅតុលាការផ្សេង

ជាគោលការណ៍តុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលនូវសាលដីកាដើម ឬ សាលក្រមដើម តុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ជូនរឿងក្តីនោះត្រលប់ទៅតុលាការដើមវិញ ក៏ប៉ុន្តែក្នុងករណីដូចជា តុលាការដើមមិនអាចរកចៅក្រមផ្សេងមកជំនួសចៅក្រមដែលមានការទាក់ទងនឹងការចេញសាលដីកាដើម ឬ សាលក្រមដើមដែលត្រូវបានតុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលនោះ ដោយសារតែចំនួនចៅក្រមនៅក្នុងតុលាការដើមនោះមិនគ្រប់គ្រាន់តុលាការនៃបណ្តឹងសាទុក្ខត្រូវផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា។ ការកំណត់បែបនេះក្នុងគោលបំណងជៀសវាងការយឺតយ៉ាវ ឬ ការរាំងស្ទះដល់ដំណើរការនៃនីតិវិធីបណ្តឹង។[75] ចំពោះតុលាការដែលទទួលការផ្ទេររឿងក្តីនេះ ត្រូវធ្វើការសម្រេចសេចក្តីដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់សាជាថ្មី ហើយចំនួនចៅក្រមត្រូវអនុវត្តដូចគ្នានឹងករណីបញ្ជូនរឿងក្តីត្រលប់ទៅតុលាការដើមវិញដែរ។ ចំណែកឯភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលបានធ្វើពីមុនមក។

### ២.៣.៣. ការបដិសេធចោល និងការវិនិច្ឆ័យដោយខ្លួនឯង

តុលាការនៃបណ្តឹងសាទុក្ខ ត្រូវធ្វើការសម្រេចសេចក្តីអំពីរឿងក្តីផ្ទាល់ដោយខ្លួនឯងក្នុងករណីដូចខាងក្រោម៖

- តុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលនូវសាលដីកាដើម ឬ សាលក្រមដើមដោយយកមូលហេតុថាតុលាការនៃការជំនុំជម្រះដើមមានកំហុសក្នុងការអនុវត្តរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្ត ចំពោះអង្គហេតុដែលបានចូលជាស្ថាពរ ហើយតុលាការនៃបណ្តឹងសាទុក្ខអាចសម្រេចសេចក្តីអំពីរឿងក្តីនោះ ដោយផ្អែកលើអង្គហេតុនេះបាន។ មានន័យថាតុលាការនៃបណ្តឹងសាទុក្ខអាចធ្វើការវិនិច្ឆ័យដោយខ្លួនឯងចំពោះសាលក្រម ឬ សាលដីកាដើមនោះបានក្នុងករណីដែលសាលក្រម ឬ សាលដីកានោះធ្វើឡើងដោយមានកំហុសក្នុងការអនុវត្តរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្តលើអង្គហេតុដែលបានកំណត់ជាស្ថាពរនៅក្នុងសាលក្រម ឬ សាលដីកាដើមនោះប៉ុណ្ណោះ។
- តុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលនូវសាលដីកាដើម ឬ សាលក្រមដើមដោយយកមូលហេតុថារឿងក្តីនោះមិនស្ថិតនៅក្រោមសិទ្ធិជម្រះក្តីរបស់តុលាការ។ មានន័យថាតុលាការដើមបានធ្វើការជំនុំជម្រះលើរឿងក្តីដែលខ្លួនគ្មានសិទ្ធិ នោះតុលាការនៃបណ្តឹងសាទុក្ខនឹងធ្វើការជំនុំជម្រះលើរឿងក្តីនោះដោយខ្លួនឯង។

✍📖✍

[75] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា២៩៩

# ជំពូកទី៤
# បណ្តឹងជំទាស់

បណ្តឹងជំទាស់គឺជាប្រព័ន្ធនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលឯករាជ្យ និងសង្ខេប ដែលអាចធ្វើឡើងចំពោះដីកាសម្រេចដែលជាសេចក្តីសម្រេចមិនមែនជាសាលក្រម ឬ សាលដីកា។ នីតិវិធីនៃបណ្តឹងជំទាស់មានលក្ខណៈងាយស្រួល និងឆាប់រហ័ស បើប្រៀបធៀបជាមួយនឹងការប្តឹងឧទ្ធរណ៍ ឬ សាទុក្ខ ហើយត្រូវបញ្ចប់ដោយដីកាសម្រេចដែលជានីតិវិធីចេញដីកាសម្រេច។ ដោយបណ្តឹងជំទាស់ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ហេតុដូច្នេះត្រង់ចំណុចនោះ ខុសពីការតវ៉ាដែលជាការឧបាស្រ័យចំពោះដីកាសម្រេចទៅតុលាការសាមី។

## ផ្នែកទី១៖ និយមន័យនៃបណ្តឹងជំទាស់

បណ្តឹងជំទាស់ គឺជាបណ្តឹងមួយដែលជាប្រព័ន្ធនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលឯករាជ្យ និងសង្ខេបដែលអាចធ្វើឡើងចំពោះដីកាសម្រេចតែប៉ុណ្ណោះ និងបញ្ចប់ដោយដីកាសម្រេចដូចគ្នា។ ប្រសិនបើយើងធ្វើការប្រៀបធៀបបណ្តឹងជំទាស់ជាមួយ នឹងបណ្តឹងផ្សេងទៀតដែលស្ថិតក្នុងប្រភេទបណ្តឹងឧបាស្រ័យដែលមានបណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខនោះយើងឃើញថា នីតិវិធីរបស់បណ្តឹងជំទាស់មានភាពឆាប់រហ័ស និងងាយស្រួលជាង។ ចំពោះតុលាការដែលមានសមត្ថកិច្ចលើបណ្តឹងជំទាស់ គឺមានតែតុលាកាជាន់ខ្ពស់ជាងតុលាការដែលចេញដីកាសម្រេចនោះ។ ជាឧទាហរណ៍៖ ប្រសិនបើសាលាឧទ្ធរណ៍ចេញដីកាសម្រេច ដូចនេះមានន័យថាតុលាការកំពូល គឺជាតុលាការដែលមានសមត្ថកិច្ចលើបណ្តឹងជំទាស់។ យ៉ាងណាមិញដីកាសម្រេចលើបណ្តឹងជំទាស់ គឺមិនអាចប្តឹងជំទាស់ទៀតបានទេ។[76]

## ផ្នែកទី២៖ មូលហេតុ និងកម្មវត្ថុនៃបណ្តឹងជំទាស់

### ១. មូលហេតុនៃបណ្តឹងជំទាស់

មិនខុសគ្នាពីបណ្តឹងឧទ្ធរណ៍ ក៏ដូចជាបណ្តឹងសាទុក្ខនោះទេ ដែលបណ្តឹងជំទាស់កើតមានឡើងក៏ព្រោះតែភាគីមិនពេញចិត្តទៅនឹងដីកាសម្រេចដែលចេញដោយសាលាដំបូង ឬ ក៏សាលាឧទ្ធរណ៍នោះ។ គ្រប់បញ្ហាទាំងអស់ដែលទាក់ទងនឹងដំណើរការនីតិវិធី ឬ ដែលកើតឡើងដោយនីតិវិធីនៃការជំនុំជម្រះ សុទ្ធតែដាក់ឱ្យតុលាការជាន់ខ្ពស់សម្រេចដែរនោះនឹងរឹតតែមានភាពស្មុគស្មាញទៅវិញ ហើយអាចធ្វើឱ្យមានការយឺតយ៉ាវក្នុងការជំនុំជម្រះរឿងក្តីនោះដោយសារតែបញ្ហាដែលកើតចេញ ដូច្នេះជាការល្អប្រសិនបើឱ្យបញ្ហាដែលមិនសូវពាក់ព័ន្ធនឹងអង្គសេចក្តីនៃរឿងក្តី ហើយដែលត្រូវការសម្រេចឱ្យឆាប់អាចដោះស្រាយបានដោយនីតិវិធីសង្ខេបដែលអាចធ្វើឡើងដាច់ដោយឡែកនោះ ដែលហៅថាបណ្តឹងជំទាស់។ ក៏មានមូលហេតុមួយទៀតដែលបណ្តាលឱ្យមានបណ្តឹងជំទាស់

[76] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៥៩ កថាខណ្ឌទី៣

គឺនៅពេលភាគីណាមួយទទួលនូវឥទ្ធិពលពីដីកាសម្រេច ដែលនាំឱ្យខូចប្រយោជន៍ដល់សិទ្ធិ ឬ ឋានៈគតិយុត្ត របស់ខ្លួន។ ហើយបណ្តឹងជំទាស់នេះអាចធ្វើបានក្នុងមូលហេតុដែលមានភាពផ្ទុយនឹងច្បាប់ ឬ បទដ្ឋានគតិយុត្ត ដែលមានឥទ្ធិពលលើដីកាសម្រេចដើម។

## ២. កម្មវត្ថុនៃបណ្តឹងជំទាស់

កម្មវត្ថុនៃបណ្តឹងជំទាស់គឺ ត្រូវតែជាដីកាសម្រេចតែមួយប៉ុណ្ណោះ។[77] ចំពោះដីកាសម្រេចដែលអាចធ្វើការប្តឹងជំទាស់បានមានដូចជា៖

- ដីកាសម្រេចបដិសេធ៖
  - ដីកាសម្រេចឱ្យលុបចោលដីកាសម្រេចជួយសង្គ្រោះលើពាក្យបណ្តឹង (មាត្រា៧០ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
  - ដីកាសម្រេចឱ្យលុបចោលប្រាតិភោគ (មាត្រា៧៣ កថាខណ្ឌទី៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
  - ដីកាសម្រេចលើកបណ្តឹងចោល (មាត្រា៧៨ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
  - ដីកាសម្រេចលើកចោលពាក្យសុំឱ្យរក្សាការពារភស្តុតាង (មាត្រា១៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
  - ដីកាសម្រេចលើកចោលពាក្យសុំទទួលបន្តនីតិវិធីនៃបណ្តឹង (មាត្រា១៧៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
  - ដីកាសម្រេចលើកចោល និងច្រានចោលបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី (មាត្រា៣១៤ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
  - ដីកាសម្រេចលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន (មាត្រា៣២៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
  - ដីកាសម្រេចការលុបចោលការរឹបអូស (មាត្រា៣៨១ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
  - ដីកាសម្រេចលើកចោលពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ (មាត្រា៤១៩ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
  - ដីកាសម្រេចលើកចោលការទាមទារឱ្យចែករំលែក (មាត្រា៤០៩ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[77] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៥៩ កថាខណ្ឌទី១

- ដីកាសម្រេចលុបចោលដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់ (មាត្រា៤៧៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចរបស់តុលាការអនុវត្ត ដែលលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ (មាត្រា៣៤៥ កថាខណ្ឌទី១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចរបស់សាលាដំបូង ដែលលើកចោលពាក្យសុំតវ៉ាចំពោះការចែងរបស់អាជ្ញាសាលា ដែលលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ (មាត្រា៣៤៥ កថាខណ្ឌទី១ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

➢ ដីកាសម្រេចអនុញ្ញាត មិនអនុញ្ញាត និងបញ្ជោះ

- ដីកាសម្រេចនូវការអនុញ្ញាត ឬមិនអនុញ្ញាតឱ្យចូលអន្តរាគមន៍ (មាត្រា៤៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចបង្គាប់ឱ្យដាក់ប្រាតិភោគ (មាត្រា៦៧ កថាខណ្ឌទី៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចឱ្យជួយសង្គ្រោះលើពាក្យបណ្តឹង (មាត្រា៧០ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចបង្គាប់ឱ្យនាំខ្លួនសាក្សី និងដីកាសម្រេចពិន័យសាក្សីជាសាច់ប្រាក់ដោយមិនចូលតាមដីកាកោះ (មាត្រា១៣២ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចពិន័យភាគីដែលបន្លំសេចក្តីថ្លែងការណ៍ (មាត្រា១៤០ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ (មាត្រា១៥២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចឱ្យតតិយជនបង់ប្រាក់ពិន័យ ដោយមិនគោរពដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ (មាត្រា១៥៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចរបស់សាលាដំបូង ដែលបង្គាប់ឱ្យអាជ្ញាសាលាលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ (មាត្រា៣៤៥ កថាខណ្ឌទី១ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចអនុញ្ញាតឱ្យរឹបអូស (មាត្រា៣៨១ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចបង្គាប់ឱ្យប្រគល់ចលនវត្ថុដែលត្រូវរឹបអូស (មាត្រា៣៩០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

- ដីកាសម្រេចបង្គាប់ឱ្យអាជ្ញាសាលាលក់សិទ្ធិលើបំណុល (មាត្រា៤១៣ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចអនុញ្ញាត ឬមិនអនុញ្ញាតឱ្យលក់ (មាត្រា៤៧៥ នៃក្រមនិតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចឱ្យប្រគល់នាវា (មាត្រា៤៨៣ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ដីកាសម្រេចអនុញ្ញាតឱ្យយកវត្ថុបញ្ចាំមកសងផ្ទាល់ (មាត្រា៥០៤ កថាខណ្ឌទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

➢ ដីកាសម្រេចផ្សេងៗ៖

- ដីកាសម្រេចផ្ទេរសិទ្ធិ និងដីកាសម្រេចលើបណ្ដឹង (មាត្រា២១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចសេចក្ដីថា ការដកហូត ឬ បណ្ដឹងផិតចិត្តពុំត្រឹមត្រូវ (មាត្រា៣០ កថាខណ្ឌទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចអំពីពាក្យសុំឱ្យតុលាការបង្គាប់ឱ្យដើមចោទ ដាក់ប្រាតិភោគលើប្រាក់ប្រដាប់ក្ដីដោយដើមចោទគ្មានទីលំនៅច្បាស់លាស់ ឬ ពិតប្រាកដ (មាត្រា៦៧ កថាខណ្ឌទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចដែលសម្រេចថា បណ្ដឹងផាត់ចោលគ្មានមូលហេតុត្រឹមត្រូវ (មាត្រា១៤៥ កថាខណ្ឌទី៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចកែតម្រូវសាលក្រម (មាត្រា១៩២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចចាប់ផ្ដើមជំនុំជម្រះសាជាថ្មី (មាត្រា៣១៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

## ផ្នែកទី៣៖ លក្ខខណ្ឌនៃបណ្ដឹងជំទាស់

ក្នុងការធ្វើបណ្ដឹងជំទាស់បាន លុះត្រាតែមាននូវល័ក្ខខ័ណ្ឌត្រូវបំពេញជាមុនសិន ហើយល័ក្ខខ័ណ្ឌនោះមានដូចជា៖

### ១. ភាគីនៃបណ្ដឹងជំទាស់

ក្នុងករណីចំណុចដែលត្រូវបានវិនិច្ឆ័យដោយដីកាសម្រេចដែលជាកម្មវត្ថុនៃបណ្ដឹងជំទាស់ មានមូលដ្ឋានដែលមានបុគ្គលពាក់ព័ន្ធនឹងផលប្រយោជន៍ ដើមបណ្ដឹងជំទាស់ត្រូវធ្វើពាក្យសុំប្ដឹងជំទាស់ប្រឆាំងទៅនឹងបុគ្គលនោះ ហើយតុលាការក៏ត្រូវឱ្យបុគ្គលនោះចូលរួមនៅក្នុងនីតិវិធីទាំងឡាយនៃការប្ដឹងជំទាស់នោះ។ ឧទាហរណ៍៖ ក្នុងករណីដែលដើមចោទបានដាក់ពាក្យសុំឱ្យតុលាការចេញដីកាសម្រេចបង្គាប់ឱ្យចុងចម្លើយ ផ្ដល់ឯកសារដែលចុងចម្លើយកាន់កាប់ ហើយតុលាការចេញដីកាសម្រេចបង្គាប់ឱ្យផ្ដល់ឯកសារ ដោយទទួលស្គាល់ពាក្យសុំនោះ ប្រសិនបើ

ចុងចម្លើយប្ដឹងជំទាស់ចំពោះដីកាសម្រេចនោះ ចុងចម្លើយត្រូវយកដើមចោទមកធ្វើជាភាគីម្ខាងទៀត។ ប្រសិនបើដើមចោទប្ដឹងជំទាស់ចំពោះដីកាសម្រេចច្រានចោលពាក្យសុំ ដើមចោទនោះត្រូវយកចុងចម្លើយមកធ្វើជាភាគីម្ខាងទៀតវិញ។ ក៏ប៉ុន្តែមានករណីខ្លះដែលសេចក្ដីសម្រេចធ្វើឡើងតាមរយៈដីកាសម្រេច តែគ្មានបុគ្គលណាពាក់ព័ន្ធនឹងផលប្រយោជន៍ទេ។ ឧទាហរណ៍៖ ដីកាសម្រេចដាក់ពិន័យស៊ីវិល ចំពោះសាក្សី ឬ ដីកាសម្រេចដាក់ពិន័យស៊ីវិលចំពោះតតិយជនដែលមិនគោរពតាមដីកាសម្រេចបង្គាប់ឱ្យផ្ដល់ឯកសារ។

### ២. អំឡុងពេលក្នុងការធ្វើបណ្ដឹងជំទាស់

ការធ្វើបណ្ដឹងជំទាស់ គឺធ្វើបានចំពោះភាគីដែលបានបាត់បង់នូវផលប្រយោជន៍ដោយសារដីកាសម្រេចពីតុលាការដើម។ ការដាក់ពាក្យបណ្ដឹងជំទាស់ គឺអាចធ្វើបានក្នុងអំឡុងពេលចំនួន ០១សប្ដាហ៍គិតចាប់ពីថ្ងៃដែលបានទទួលនូវដំណឹងអំពីដីកាសម្រេច។ ហើយអំឡុងពេលនៃបណ្ដឹងជំទាស់នេះគឺមិនអាចពន្យារពេលបាននោះទេ។[78]

## ផ្នែកទី៤៖ របៀបធ្វើបណ្ដឹងជំទាស់

មិនខុសពីបណ្ដឹងដទៃទៀតនោះទេ ដើម្បីធ្វើបណ្ដឹងជំទាស់ភាគីក៏ត្រូវឱ្យចុះអំពីអត្តសញ្ញាណខ្លួនដូចជាឈ្មោះ អាសយដ្ឋានភាគី និងអ្នកតំណាងដែលច្បាប់បានកំណត់ឱ្យបានច្បាស់លាស់។ ជាមួយគ្នានេះដែរបណ្ដឹងជំទាស់ក៏ទាមទារឱ្យភាគីនៃដើមបណ្ដឹងជំទាស់ចុះអំពីមូលហេតុច្បាស់លាស់នៃការសុំលុបចោល ឬ ការផ្លាស់ប្ដូរដីកាសម្រេចដើម។ ប្រសិនបើភាគីមិនបានសរសេរនូវមូលហេតុច្បាស់លាស់នោះទេ ដើមបណ្ដឹងជំទាស់គប្បីដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងជំទាស់នោះ ទៅតុលាការនៃបណ្ដឹងជំទាស់ក្នុងអំឡុងពេល ០២សប្ដាហ៍គិតចាប់ពីពេលដែលបានដាក់នូវពាក្យបណ្ដឹងជំទាស់នោះ។[79] ប្រសិនបើដើមបណ្ដឹងជំទាស់មិនបានដាក់លិខិតបញ្ជាក់ពីមូលហេតុក្នុងអំឡុងពេលដែលច្បាប់បានកំណត់ ឬ មិនបានចុះអំពីមូលហេតុក្នុងពាក្យបណ្ដឹងនោះទេពាក្យបណ្ដឹងជំទាស់មួយនោះនឹងគ្មានសុពលភាព។ ពាក្យបណ្ដឹងជំទាស់ត្រូវដាក់នៅតុលាការដើម បន្ទាប់មកតុលាការដើមត្រូវបញ្ជូនពាក្យបណ្ដឹងជំទាស់ និងសំណុំរឿងទៅតុលាការនៃបណ្ដឹងជំទាស់ ឬ តុលាការជាន់ខ្ពស់។

## ផ្នែកទី៥៖ អានុភាពនៃពាក្យបណ្ដឹងជំទាស់

ជាទូទៅនៅពេលដែលដាក់ពាក្យបណ្ដឹងជំទាស់ហើយ តុលាការពិនិត្យឃើញថាត្រឹមត្រូវទៅតាមច្បាប់នៃបណ្ដឹងជំទាស់បានកំណត់ដែលដូចជាល័ក្ខខ័ណ្ឌ និងរបៀបបណ្ដឹងជំទាស់នោះ អានុភាពនៃបណ្ដឹងជំទាស់គឺនឹងកើតមានឡើង។ ជាគោលការណ៍ដីកាសម្រេចអាចមានអានុភាពអនុវត្ត ឬ អាចមានអានុភាពបង្កើតទំនាក់ទំនង

[78] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៣០៣ កថាខណ្ឌទី១, កថាខណ្ឌទី២

[79] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៣០១ កថាខណ្ឌទី២

គតិយុត្ត លុះត្រាតែត្រូវបានជូនដំណឹងដែលគេអាចទទួលស្គាល់ថាសមរម្យ។ ដូចនេះកាលណាដែលបណ្តឹងជំទាស់មាននូវអានុភាព ដីកាសម្រេចដើមដែលមានអានុភាពនោះនឹងត្រូវបង្អាក់។ ឧទាហរណ៍៖ ក្នុងករណីដែលបណ្តឹងជំទាស់ ត្រូវបានដាក់ចំពោះដីកាសម្រេចបង្គាប់ឱ្យប្រគល់ចលនវត្ថុដែលត្រូវបានរឹបអូស ដូចនេះភាគីដែលត្រូវបង្គាប់នោះ មិនចាំបាច់ប្រគល់ចលនវត្ថុដែលត្រូវបានរឹបអូស ដែលតុលាការដើមបង្គាប់ឱ្យប្រគល់ឡើយ។[80] ប៉ុន្តែនៅក្នុងនីតិវិធីអនុវត្តដោយបង្ខំ បណ្តឹងជំទាស់មិនអាចមានអានុភាពបង្អាក់ដីកាសម្រេចដើមបានឡើយ។ ប៉ុន្តែបើការផ្អាកការអនុវត្តដោយបង្ខំជាបណ្តោះអាសន្ន ឬ ការចាត់ចែងផ្សេងទៀតនោះ អាចធ្វើបានតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់តុលាការ ទើបអាចបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំជាបណ្តោះអាសន្ន ឬ បង្គាប់ឱ្យធ្វើការចាត់ចែងចាំបាច់ផ្សេងទៀត រហូតដល់ពេលមានដីកាសម្រេចអំពីបណ្តឹងជំទាស់នោះ។

## ផ្នែកទី៦៖ នីតិវិធី និងការជំនុំជម្រះលើបណ្តឹងជំទាស់

យោងតាមមាត្រា៣០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីដែលបញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ និងនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងជំទាស់ និងនីតិវិធីនៃតុលាការបណ្តឹងជំទាស់នោះ លើកលែងតែករណីដែលបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈបណ្តឹង ឬ នីតិវិធីនោះ។ ហេតុដូច្នេះបណ្តឹងជំទាស់ចំពោះដីកាសម្រេចដែលត្រូវបានធ្វើដោយសាលាដំបូង បញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ នីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ត្រូវយកមកអនុវត្តដូចគ្នាដែរ ដោយសារបណ្តឹងជំទាស់នេះ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការនៃការជំនុំជម្រះលើកទី២ដូចបណ្តឹងឧទ្ធរណ៍។ បញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នានេះ មានដូចជាមាត្រា២៦៣ (ការលះបង់សិទ្ធិប្តឹងឧទ្ធរណ៍), កថាខណ្ឌទី៦ នៃមាត្រា២៦៥ (របៀបប្តឹងឧទ្ធរណ៍), មាត្រា២៦៦ (សិទ្ធិពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍របស់តុលាការនៃបណ្តឹងឧទ្ធរណ៍), មាត្រា២៦៨ (ការលើកចោលបណ្តឹងឧទ្ធរណ៍ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់), មាត្រា២៧០ (បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ), មាត្រា២៧៣ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីនីតិវិធីនៃការជំនុំជម្រះលើកទី១) ជាអាទិ៍។ ប៉ុន្តែប្រសិនបើមានបញ្ញត្តិផ្សេង ឬ មានភាពផ្ទុយនឹងលក្ខណៈបណ្តឹងជំទាស់ នោះអនុញ្ញាតឱ្យមានករណីលើកលែង។ ករណីលើកលែងនេះមានដូចជាអំឡុងពេលសម្រាប់ប្តឹងជំទាស់ (មាត្រា៣០៣) ,អំឡុងពេលដើម្បីដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងជំទាស់ (មាត្រា៣០១ កថាខណ្ឌទី២), ភាពអាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដោយឆន្ទានុសិទ្ធិ (មាត្រា៣០៦ កថាខណ្ឌទី១), ការអនុញ្ញាតឱ្យធ្វើការសួរ (មាត្រា៣០៦ កថាខណ្ឌទី៦) ជាអាទិ៍។

រីឯចំពោះបណ្តឹងជំទាស់ ដីកាសម្រេចដែលត្រូវបានធ្វើដោយសាលាឧទ្ធរណ៍ក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី១ និងនីតិវិធីនៃបណ្តឹងជំទាស់នោះ បញ្ញត្តិស្តីពីបណ្តឹងសាទុក្ខ និងនីតិវិធីទាក់ទងនឹងការជំនុំជម្រះ

[80] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៣០៥ កថាខណ្ឌទី១

បណ្ដឹងសាទុក្ខត្រូវយកមកអនុវត្តដូចគ្នាផងដែរ លើកលែងតែបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈនៃបណ្ដឹងជំទាស់ ឬ នីតិវិធីបណ្ដឹងជំទាស់នោះ ដោយសារបណ្ដឹងជំទាស់បែបនេះមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងបណ្ដឹងសាទុក្ខចំពោះសាលដីកាចុងក្រោយ ដែលសាលាឧទ្ធរណ៍បានចេញក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី១។ ហេតុដូច្នេះបណ្ដឹងជំទាស់នេះត្រូវបានដាក់ទៅតុលាការកំពូល ហើយបណ្ដឹងជំទាស់នោះអាចធ្វើបានក្នុងករណីដែលមានភាពផ្ទុយនឹងច្បាប់ ឬ បទដ្ឋានគតិយុត្តដែលមានឥទ្ធិពលលើដីកាសម្រេចដើមតែប៉ុណ្ណោះ។ ក្រៅពីនេះបញ្ញត្តិនៃមាត្រា២៨៦ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្ដីពីបណ្ដឹងឧទ្ធរណ៍), មាត្រា២៨៨ (ការបញ្ជូនលិខិតទទួលពាក្យបណ្ដឹងសាទុក្ខ ជាអាទិ៍), កថាខណ្ឌទី២ និងទី៣ នៃមាត្រា២៨៩ (ការសរសេរមូលហេតុនៃបណ្ដឹងសាទុក្ខ), មាត្រា២៩០ (ការលើកចោលបណ្ដឹងសាទុក្ខ) ជាអាទិ៍។

### **១. ការទទួលពាក្យបណ្ដឹងជំទាស់**

ពាក្យបណ្ដឹងជំទាស់ត្រូវដាក់នៅតុលាការដើមចំពោះដីកាសម្រេចនោះ ក្នុងអំឡុងពេលកំណត់សម្រាប់ធ្វើបណ្ដឹងជំទាស់។ ដោយឡែកតុលាការដើមពុំមានសមត្ថកិច្ចពិនិត្យពាក្យបណ្ដឹងជំទាស់ទេ គ្រាន់តែជាតុលាការដែលទទួលពាក្យបណ្ដឹងជំទាស់របស់ភាគីតែប៉ុណ្ណោះ។ បន្ទាប់មកតុលាការដើមត្រូវធ្វើការផ្ញើឱ្យបានឆាប់រហ័សនូវពាក្យបណ្ដឹងជំទាស់នោះ និងសំណុំរឿងទៅតុលាការនៃបណ្ដឹងជំទាស់ ឬ តុលាការជាន់ខ្ពស់។

### **២. ការពិនិត្យពាក្យបណ្ដឹងជំទាស់**

តុលាការនៃបណ្ដឹងជំទាស់ត្រូវធ្វើការពិនិត្យ ប្រសិនបើមានចំណុចណាមិនសមស្រប តុលាការត្រូវតែបង្គាប់ឱ្យដើមបណ្ដឹងជំទាស់ធ្វើការកែប្រែ។ ក្នុងករណីដែលភាគីនោះមិនធ្វើតាមការបង្គាប់ឱ្យកែប្រែរបស់តុលាការទេ តុលាការនឹងមានសិទ្ធិលើកចោលពាក្យបណ្ដឹងជំទាស់នោះដោយដីកាសម្រេច។ ប្រសិនបើពាក្យបណ្ដឹងជំទាស់ត្រឹមត្រូវតាមទម្រង់ច្បាប់ តុលាការត្រូវបញ្ជូនពាក្យបណ្ដឹងជំទាស់នោះទៅឱ្យចុងបណ្ដឹងជំទាស់។

### **៣. ការទាញហេតុផលដោយផ្ទាល់មាត់**

ចំពោះនីតិវិធីបណ្ដឹងជំទាស់ មិនមែនធ្វើតាមវិធីតទល់គ្នារវាងភាគីនៅគ្រប់ពេលវេលាទេ។ យ៉ាងណាមិញចំពោះនីតិវិធីនៃការជំនុំជម្រះបណ្ដឹងជំទាស់វិញនោះត្រូវបញ្ចប់ដោយដីកាសម្រេច តុលាការអាចសម្រេចដោយឆន្ទានុសិទ្ធិបានក្នុងការធ្វើ ឬ មិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់។ ប្រសិនបើតុលាការនៃបណ្ដឹងជំទាស់មិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការអាចធ្វើការសួរដើមបណ្ដឹងជំទាស់ ឬអ្នកផ្សេងទៀតដែលមានទំនាក់ទំនងនឹងផលប្រយោជន៍នៃបណ្ដឹងបាន។ ក្នុងការជំនុំជម្រះនៃបណ្ដឹងជំទាស់នេះ គឺផ្អែកទៅលើការអះអាងរបស់ភាគី និងភស្តុតាងដែលបានដាក់នៅតុលាការដើមតាមរយៈការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវក្នុងការអនុវត្តច្បាប់ ដូច្នេះភាគីអាចដាក់អង្គហេតុថ្មី និងភស្តុតាងថ្មីបាន។

## ផ្នែកទី៧៖ វិសាលភាពនៃការជំនុំជម្រះបណ្តឹងជំទាស់

នៅក្នុងផ្នែកទី៧ ដែលស្តីអំពីវិសាលភាពនៃបណ្តឹងជំទាស់នេះ នឹងលើកយកពីរចំណុចមកពន្យល់ដែល ចំណុចទី១ និយាយអំពីការប្តឹងជំទាស់ចំពោះដីកាសម្រេចនៃសាលាឧទ្ធរណ៍ និងចំណុចទី២ និយាយអំពីការប្តឹងជំទាស់ចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលការបញ្ជា ឬ ការប្រគល់សិទ្ធិ។

### ១. វិសាលភាពនៃការជំនុំជម្រះបណ្តឹងជំទាស់ចំពោះដីកាសម្រេចនៃសាលាឧទ្ធរណ៍

បើទោះជាការប្តឹងជំទាស់អាចធ្វើឡើងទៅតាមការកំណត់ក្នុងបញ្ញត្តិច្បាប់ក៏ដោយ ក៏ប៉ុន្តែចំពោះដីកាសម្រេចចុងក្រោយនៃការជំនុំជម្រះបណ្តឹងជំទាស់ដែលតុលាការនៃបណ្តឹងជំទាស់បានចេញ មិនអាចប្តឹងជំទាស់ទៀតបានឡើយ។ ឧទាហរណ៍៖ ប្រសិនបើមានបណ្តឹងជំទាស់ចំពោះដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារដែលបានចេញដោយសាលាដំបូងក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី១ ភាគីអាចប្តឹងជំទាស់បានទៅសាលាឧទ្ធរណ៍ ប៉ុន្តែនៅពេលតុលាការនៃបណ្តឹងឧទ្ធរណ៍ចេញដីកាសម្រេចចុងក្រោយនៃបណ្តឹងជំទាស់នោះហើយ គឺមិនអាចប្តឹងជំទាស់ទៅតុលាការកំពូលថែមទៀតបានទេ។ ការអនុវត្តបែបនេះ គឺដើម្បីសម្រាលនូវបន្ទុករបស់តុលាការកំពូល។

ផ្ទុយមកវិញចំពោះដីកាសម្រេចដែលសាលាឧទ្ធរណ៍បានធ្វើឡើង ក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី១ អាចប្តឹងជំទាស់ទៅតុលាការកំពូលបាន បើមានបញ្ញត្តិច្បាប់អនុញ្ញាតឱ្យប្តឹងជំទាស់ចំពោះដីកាសម្រេចនោះ។ បណ្តឹងជំទាស់ត្រង់ចំណុចនេះ គឺជាបណ្តឹងជំទាស់ទៅតុលាការកំពូលដែលជាតុលាការវិនិច្ឆ័យទៅលើអង្គច្បាប់ ហើយនីតិវិធីនៃការប្តឹងជំទាស់ទៅតុលាការកំពូលក្នុងករណីនេះ គឺស្រដៀងគ្នាទៅនឹងការអនុវត្តបណ្តឹងសាទុក្ខ ចំពោះសាលដីកាចុងក្រោយរបស់សាលាឧទ្ធរណ៍ដែលចេញក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី១ ដោយហេតុនេះបញ្ញត្តិស្តីពីបណ្តឹងសាទុក្ខ និងនីតិវិធីទាក់ទងទៅនឹងការជំនុំជម្រះបណ្តឹងសាទុក្ខទាំងនោះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងជំទាស់លើដីកាសម្រេចដែលសាលាឧទ្ធរណ៍បានចេញក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី១ និងនីតិវិធីដែលទាក់ទងនឹងបណ្តឹងជំទាស់នោះ លើកលែងតែករណីដែលបញ្ញត្តិនោះមានការផ្ទុយនឹងលក្ខណៈនៃបណ្តឹង ឬ នីតិវិធីនោះ។ ហេតុដូច្នេះបណ្តឹងជំទាស់នេះអាចធ្វើទៅបាន ដោយយកមូលហេតុនៃភាពផ្ទុយនឹងច្បាប់ ឬ បទដ្ឋានគតិយុត្តដែលមានឥទ្ធិពលលើដីកាសម្រេចដើមតែប៉ុណ្ណោះ។

ម្យ៉ាងវិញទៀតមានករណីខ្លះដែលសាលាឧទ្ធរណ៍ចេញដីកាសម្រេច ក្នុងនាមជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍។ ក្នុងករណីនេះភាពអាច ឬ មិនអាចប្តឹងជំទាស់ចំពោះដីកាសម្រេចដែលសាលាឧទ្ធរណ៍ចេញក្នុងនាមជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ អាស្រ័យទៅលើការអនុវត្តតាមបញ្ញត្តិនៃមាត្រា២៥៩។ ដូចនេះ លើកលែងតែករណីដែលមានបញ្ញត្តិច្បាប់អនុញ្ញាតឱ្យប្តឹងជំទាស់ ភាគីមិនអាចប្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាឧទ្ធរណ៍បានឡើយ។ ក្នុងករណីដែលសាលាឧទ្ធរណ៍ចេញដីកាសម្រេចជាដំបូងក្នុងនាមជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ប្រសិនបើបណ្តឹងជំទាស់ចំពោះដីកាសម្រេចត្រូវបានធ្វើឡើងផ្អែកលើបញ្ញត្តិនៃគន្លឹទី១

ដែលអាចអនុវត្តដោយផ្ទាល់ចំពោះបណ្តឹងឧទ្ធរណ៍ ភាគីអាចប្តឹងជំទាស់បាន។ ឧទាហរណ៍៖ ចំពោះដីកាសម្រេច ដែលសម្រេចថាការដកហូត ឬ បណ្តឹងដិតចិត្តចៅក្រមនៃសាលាឧទ្ធរណ៍មិនត្រឹមត្រូវ អាចប្តឹងជំទាស់បានដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៦ មាត្រា៣០ នៅក្នុងគន្លីទី១។ ផ្ទុយមកវិញចំពោះដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារដែលសាលាឧទ្ធរណ៍បានចេញ ក្នុងនាមជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍មិនអាចប្តឹងជំទាស់បានឡើយ ដោយសារបញ្ញត្តិនៃកថាខណ្ឌទី៣ មាត្រា១៥២ មិនត្រូវអនុវត្តដោយផ្ទាល់ចំពោះបណ្តឹងឧទ្ធរណ៍ទេ ហើយត្រូវអនុវត្តដូចគ្នាផងដែរ ក្នុងនាមជាបញ្ញត្តិដែលទាក់ទងនឹង "គន្លីទី២ ស្តីពីនីតិវិធីនៃការជំនុំជម្រះលើកទី១" ដោយយោងតាមបញ្ញត្តិនៃមាត្រា២៧២។

### ២. វិសាលភាពនៃការជំនុំជម្រះបណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលភារៈបញ្ជា ឬ ភារប្រគល់សិទ្ធិ

ចំពោះដីកាសម្រេចរបស់ចៅក្រមទទួលបញ្ជា ឬ ចៅក្រមទទួលបន្ទុកនេះគឺខុសគ្នានឹងដីកាសម្រេចរបស់តុលាការ ដោយនៅទីនេះគេតម្រូវឱ្យមានការគ្រប់គ្រងពិនិត្យដោយតុលាការដែលទទួលបណ្តឹង។ ហេតុនេះបើភាគីមានការតវ៉ា តុលាការដែលទទួលបណ្តឹងត្រូវសម្រេចសេចក្តីដោយដីកាសម្រេច។ ចំពោះដីកាសម្រេចរបស់ចៅក្រមទទួលបញ្ជា ឬ ចៅក្រមទទួលបន្ទុកដែលត្រូវបានជ្រើសតាំងចំពោះរឿងក្តីដែលសាលាឧទ្ធរណ៍ ឬ តុលាការកំពូលកំពុងចាត់ការវិញក៏ដូចគ្នានឹងករណីដែលសាលាដំបូងជាតុលាការទទួលបណ្តឹង ដែលភាគីអាចដាក់ពាក្យសុំប្តឹងតវ៉ាទៅសាលាឧទ្ធរណ៍ ឬ តុលាការកំពូលដែលជាតុលាការទទួលបណ្តឹង។ ចំពោះការស្នើសុំប្តឹងតវ៉ាដែលមានចែងក្នុងមាត្រា៣០២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រសិនបើដីកាសម្រេចនោះត្រូវបានធ្វើឡើងដោយតុលាការទទួលបណ្តឹងនោះភាគីត្រូវធ្វើបណ្តឹងជំទាស់ ហេតុនេះភាគីត្រូវធ្វើបណ្តឹងតវ៉ានៅក្នុងអំឡុងពេល ០១សប្តាហ៍ ក្រោយថ្ងៃទទួលដំណឹងអំពីដីកាសម្រេចដែលមានចែងក្នុងមាត្រា៣០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។ ប្រសិនបើតុលាការទទួលបណ្តឹងជាសាលាឧទ្ធរណ៍ ចំពោះតែករណីនៃកថាខណ្ឌទី២ នៃមាត្រា៣០៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងសាទុក្ខ) អាចប្តឹងជំទាស់ចំពោះដីកាសម្រេចលើពាក្យសុំដែលមានចែងក្នុងកថាខណ្ឌទី១ មាត្រា៣០២ បាន តែប្រសិនបើតុលាការទទួលពាក្យបណ្តឹងជាតុលាការកំពូលវិញ មិនអាចប្តឹងជំទាស់បានឡើយ។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីការបកស្រាយបានយ៉ាងក្បោះក្បាយរួចមក យើងអាចធ្វើការសន្និដ្ឋានបានថា បណ្តឹងឧបាស្រ័យនេះគឺជាបណ្តឹងមួយដែលបង្កើតឡើងដើម្បីឱ្យភាគីដែលមិនសុខចិត្តនឹងសាលក្រម ឬ សាលដីកា ឬ ដីកាសម្រេច ធ្វើការប្តឹងតវ៉ាទៅតុលាការជាន់ខ្ពស់។ ដូច្នេះបណ្តឹងឧបាស្រ័យមានបីប្រភេទដូចជា បណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ និងបណ្តឹងជំទាស់។ បណ្តឹងឧបាស្រ័យនេះអាចប្រព្រឹត្តទៅបានចំពោះតែសាលក្រម ឬ សាលដីកា ឬ ដីកាសម្រេច ដែលមិនទាន់ចូលជាស្ថាពរតែប៉ុណ្ណោះ។ ក៏ប៉ុន្តែក្នុងករណីដែលសេចក្តីសម្រេចនោះបានចូលជាស្ថាពររួចហើយ នោះភាគីនៅតែអាចប្តឹងតវ៉ាបានតែក្នុងប្រភេទបណ្តឹងផ្សេង ពោលគឺបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី។ ដោយសារការប្តឹងឧបាស្រ័យមានបីប្រភេទ ដូច្នេះភាគីត្រូវជ្រើសរើសការធ្វើពាក្យបណ្តឹងឱ្យបានត្រឹមត្រូវ ទៅតាមប្រភេទនៃបណ្តឹងឧបាស្រ័យនីមួយៗ ដូច្នេះភាគីត្រូវសិក្សាទៅលើបណ្តឹងនីមួយៗឱ្យបានច្បាស់លាស់ជាមុនសិន។

នៅពេលនីតិវិធីនៃការជំនុំជម្រះលើកទី១ត្រូវបានបញ្ចប់ ប្រសិនបើមានភាគីណាមិនខុសចិត្តនឹងសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១នោះ ភាគីអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន ដែលបណ្តឹងនោះហៅថាបណ្តឹងឧទ្ធរណ៍ ក្នុងគោលបំណងលុបចោល ឬ ផ្លាស់ប្តូរនូវសាលក្រមនោះ។ ដូច្នេះកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍គឺសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១ដែលមិនទាន់ចូលជាស្ថាពរ របស់សាលាដំបូងទាំងអស់ ប៉ុន្តែមានលើកលែងក្នុងករណីមួយចំនួនដែលច្បាប់មិនបានអនុញ្ញាត។ រីឯមូលហេតុនៃបណ្តឹងឧទ្ធរណ៍ដែលកំណត់ជាក់លាក់នៅក្នុងច្បាប់គឺមានបួនស្ថានភាពដូចជា សាលក្រមនៃការជំនុំជម្រះលើកទី១មិនត្រឹមត្រូវ ឬ នីតិវិធីជំនុំជម្រះលើកទី១នៅសាលាដំបូងផ្ទុយនឹងច្បាប់ធ្ងន់ធ្ងរ ឬ ការលើកបណ្តឹងចោលរបស់សាលាដំបូងមានលក្ខណៈមិនត្រឹមត្រូវ ឬ ការជំនុំជម្រះលើកទី១មានកំហុសចំពោះសមត្ថកិច្ចផ្តាច់មុខ។ ដូចនេះប្រសិនបើភាគីមានហេតុផលច្បាស់លាស់ដូចដែលបានចែងក្នុងច្បាប់ និងជាភាគីដែលមានសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ ភាគីនោះត្រូវធ្វើពាក្យបណ្តឹងឧទ្ធរណ៍នោះក្នុងអំឡុងពេលមួយដែលច្បាប់បានកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។ ក្នុងការធ្វើពាក្យបណ្តឹងឧទ្ធរណ៍ តម្រូវឱ្យភាគីត្រូវបញ្ជាក់អំពី អត្តសញ្ញាណ សញ្ញាណនៃសាលក្រមនៃការជំនុំជម្រះលើកទី១ សេចក្តីដែលប្តឹងចំពោះសាលក្រមនោះ និងមូលហេតុនៃការទាមទារឱ្យលុបចោល ឬ ផ្លាស់ប្តូរនូវសាលក្រមនោះ។ បើភាគីបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទាន់អំឡុងពេលកំណត់ អានុភាពនៃបណ្តឹងឧបាស្រ័យនឹងកើតមាន សាលក្រមនៃការជំនុំជម្រះលើកទី១របស់សាលាដំបូងនឹងត្រូវបង្អាក់នូវការអនុវត្ត បន្ថែមពីនេះ អានុភាពនៃការផ្ទេរការជំនុំជម្រះក្តី និងអានុភាពអវិភាគនៃបណ្តឹងឧទ្ធរណ៍។ បន្ទាប់ពីដើមបណ្តឹងឧទ្ធរណ៍ដាក់ពាក្យបណ្តឹងទៅតុលាការដើម តុលាការដើមត្រូវពិនិត្យ និងបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍ និងសំណុំរឿងទៅតុលាការនៃបណ្តឹងឧទ្ធរណ៍។ នៅពេលតុលាការនៃបណ្តឹងឧទ្ធរណ៍បានទទួលពាក្យបណ្តឹង និងសំណុំរឿង គឺត្រូវពិនិត្យលើល័ក្ខខ័ណ្ឌដែលបានកំណត់ បើយល់ឃើញថាត្រឹមត្រូវ នឹងបញ្ជូនទៅចុងបណ្តឹងឧទ្ធរណ៍ រួចនឹងមាននីតិវិធីជំនុំជម្រះ

ដោយមិនមាននីតិវិធីត្រៀមទាញហេតុផលទេ ប៉ុន្តែនឹងកំណត់កាលបរិច្ឆេទសម្រាប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់តែម្តង ក្នុងនោះត្រូវវិនិច្ឆ័យទាំងអង្គហេតុ និងអង្គច្បាប់។ ចំពោះការទាញហេតុផលដោយផ្ទាល់មាត់ត្រូវគោរពតាមគោលការណ៍នៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ផងដែរ។ ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវបានបញ្ចប់ នោះនីតិវិធីបណ្តឹងឧទ្ធរណ៍ក៏អាចត្រូវបានបញ្ចប់ដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ (ការបញ្ចប់បណ្តឹងដោយស្វ័យប្រវត្តិ ឬ ការបញ្ចប់បណ្តឹងដោយសកម្មភាពភាគី) ឬ ដោយឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ (តុលាការអាចចេញសាលដីកាលើកចោលបណ្តឹងឧទ្ធរណ៍ ឬ សាលដីកាច្រានចោលបណ្តឹងឧទ្ធរណ៍ ឬ សាលដីកាទទួលស្គាល់បណ្តឹងឧទ្ធរណ៍)។ បើភាគីណាម្ខាងមិនសុខចិត្តនឹងសាលដីកាដែលចេញដោយតុលាការនៃបណ្តឹងឧទ្ធរណ៍ ភាគីនោះអាចប្តឹងសាទុក្ខទៅតុលាការជាន់ខ្ពស់ដែលជាតុលាការកំពូល។ ដូចនេះប្រភេទឧបាស្រ័យម៉្យាងទៀតគឺជាបណ្តឹងសាទុក្ខ ដែលភាគីអាចប្តឹងឧបាស្រ័យទៅតុលាការកំពូលដើម្បីវិនិច្ឆ័យពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវចំពោះការអនុវត្តច្បាប់ក្នុងសាលក្រម ឬ សាលដីកាចុងក្រោយ។ បណ្តឹងសាទុក្ខអាចអនុវត្តលើសាលក្រមបានលុះត្រាតែភាគីមានការព្រមព្រៀងមិនប្តឹងឧទ្ធរណ៍ ប៉ុន្តែរក្សាទុកនូវសិទ្ធិប្តឹងសាទុក្ខដែលបណ្តឹងនោះហៅថាបណ្តឹងសាទុក្ខផ្លោះ។ ម្យ៉ាងវិញទៀតមូលហេតុដែលធ្វើឱ្យកើតមានឡើងបណ្តឹងសាទុក្ខនោះមានពីរប្រភេទដោយប្រភេទទីមួយគឺជាមូលហេតុទូទៅដែលមានន័យថាតុលាការដើមធ្វើការវិនិច្ឆ័យ ឬ ការសម្រេចសេចក្តីរបស់តុលាការផ្ទុយពីរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងៗ ហើយប្រភេទទីពីរនោះគឺមូលហេតុដាច់ខាតដែលសម្តៅទៅលើការខុសពីនីតិវិធីធ្ងន់ធ្ងរ។ ដូចនេះប្រសិនបើភាគីយល់ថាសេចក្តីសម្រេចនោះផ្ទុយពីមូលហេតុដែលច្បាប់បានចែង ពោលគឺមូលហេតុទូទៅ និងមូលហេតុដាច់ខាតខាងលើ ភាគីអាចធ្វើបណ្តឹងសាទុក្ខបានក្នុងអំឡុងពេលដែលច្បាប់បានកំណត់។ លើសពីនេះបណ្តឹងសាទុក្ខអាចមានអានុភាព លុះត្រាតែក្នុងពាក្យបណ្តឹងនោះភាគីត្រូវសរសេរជាលាយលក្ខណ៍អក្សរ នូវចំណុចសំខាន់ដែលច្បាប់បានកំណត់ បូករួមទាំងបញ្ជាក់អំពីមូលហេតុអោយបានច្បាស់លាស់ ដោយអានុភាពនៃបណ្តឹងសាទុក្ខដូចគ្នាទៅនឹងអានុភាពបណ្តឹងឧទ្ធរណ៍។ នីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខ ក៏មានភាពស្រដៀងគ្នាទៅនឹងនីតិវិធីនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ដែរ ប៉ុន្តែខុសគ្នាត្រង់ថាបណ្តឹងសាទុក្ខជំនុំជម្រះតែលើអង្គច្បាប់ប៉ុណ្ណោះ ហើយបណ្តឹងសាទុក្ខតុលាការបង្គាប់ឱ្យដាក់នូវឯកសារត្រៀម និងការទាញហេតុដោយផ្ទាល់មាត់អាចមានពីរលើក ប្រសិនបើមានករណីដែលតុលាការនៃបណ្តឹងសាទុក្ខបានបដិសេធនូវសាលដីកាដើម ហើយបានបញ្ជូនរឿងក្តីនោះត្រលប់ទៅតុលាការដើមវិញ ឬ ផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា ដើម្បីឱ្យធ្វើការជំនុំជម្រះរឿងក្តីនោះម្តងទៀត បន្ទាប់មកនៅពេលដែលតុលាការដើមដែលបានទទួលការបញ្ជូនរឿងក្តីត្រលប់មកវិញ ឬ តុលាការដែលបានទទួលការផ្ទេររឿងក្តីនោះបានចេញសាលដីកា ហើយបើមានភាគីណាមួយមិនសុខចិត្តនឹងសេចក្តីសម្រេចនោះ ហើយបានប្តឹងសាទុក្ខម្តងទៀត នោះនីតិវិធីតុលាការនៃបណ្តឹងសាទុក្ខលើកទី២នឹងកើតមាន ដែលធ្វើការជំនុំជម្រះដោយសភាពេញអង្គ។

នៅពេលដែលបញ្ចប់នីតិវិធីបណ្តឹងសាទុក្ខ តុលាការអាចបញ្ចប់នីតិវិធីដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ ឬ ឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ មានន័យថានីតិវិធីបញ្ចប់បណ្តឹងសាទុក្ខ មានសភាពស្រដៀងទៅនឹងនីតិវិធីបញ្ចប់បណ្តឹងឧទ្ធរណ៍។ យ៉ាងណាមិញក្រោយពេលតុលាការជាន់ទាបបានចេញសេចក្តីសម្រេច ភាគីម្ខាងបានធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ បន្ទាប់មកភាគីម្ខាងទៀតបានធ្វើបណ្តឹងតប ដែលបណ្តឹងនេះហៅថាបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ឬ បណ្តឹងសាទុក្ខបន្ទាប់បន្សំ។ ដោយឡែកប្រសិនបើភាគីណាមិនសុខចិត្តនឹងដីកាសម្រេចក្នុងដំណើរនីតិវិធីរបស់តុលាការដើម ភាគីនោះអាចធ្វើបណ្តឹងជំទាស់ទៅតុលាការជាន់ខ្ពស់បាន។ នេះហើយដីកាសម្រេចដែលយកមកធ្វើបណ្តឹងជំទាស់នេះទៀតសោត ក៏ត្រូវតែមានបញ្ញត្តិនៅក្នុងច្បាប់ទើបអាចធ្វើបាន។ ហើយមិនខុសពីប្រភេទបណ្តឹងទាំងពីរខាងលើទេ ការធ្វើពាក្យបណ្តឹងជំទាស់ ល័ក្ខខ័ណ្ឌនៃបណ្តឹងជំទាស់ អានុភាពនៃបណ្តឹងជំទាស់សុទ្ធតែដូចគ្នា ប៉ុន្តែការដាក់ពាក្យបណ្តឹងជំទាស់ គឺធ្វើបានក្នុងអំឡុងពេលតែ ០១សប្តាហ៍ ដែលខុសគ្នាពីអំឡុងពេលនៃការដាក់ពាក្យរបស់បណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខ។ ចំពោះនីតិវិធីនៃការជំនុំជម្រះបណ្តឹងជំទាស់វិញ ត្រូវបញ្ចប់ដោយដីកាសម្រេច តុលាការអាចសម្រេចដោយឆន្ទានុសិទ្ធិបានក្នុងការធ្វើ ឬ មិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់។

ដោយផ្អែកលើការសិក្សាស្រាវជ្រាវ នៅក្នុងអំឡុងពេលប៉ុន្មានខែមកនេះ សង្កេតឃើញថាបណ្តឹងឧបាស្រ័យទាំងបីប្រភេទមានចំណុចដូចគ្នា ហើយក៏មានចំណុចខុសគ្នាដែលធ្វើឱ្យមានភាពស្មុគស្មាញបន្តិច ក៏ប៉ុន្តែបណ្តឹងឧបាស្រ័យពិតជាមានសារៈប្រយោជន៍ណាស់ សម្រាប់បុគ្គលគ្រប់រូបដែលជាភាគីទទួលរងនូវភាពអយុត្តិធម៌ពីការចេញសេចក្តីសម្រេចរបស់តុលាការជាន់ទាប ដែលជាមធ្យោបាយ ឬ ជានីតិវិធីមួយដែលការពារនូវភាពលំអៀង ឬ មានការភាន់ច្រឡំរបស់តុលាការនៅពេលដំណើរការនៅក្នុងរឿងក្តីរដ្ឋប្បវេណី។ ពិសេសជាងនេះទៅទៀតគឺការទប់ស្កាត់នូវការចេញសេចក្តីសម្រេចរបស់តុលាការ ដោយទំនើងចិត្តរបស់ចៅក្រមក្នុងតុលាការជាន់ទាប ឬ ជួយឱ្យមានភាពល្អប្រសើរចំពោះការចេញសេចក្តីសម្រេចគ្រប់តុលាការជាន់ទាបទាំងអស់ ដែលត្រូវតែគោរពតាមភាពយុត្តិធម៌ និងមានភាពត្រឹមត្រូវច្បាស់លាស់មិនលំអៀងជូនប្រជាពលរដ្ឋ។

# អនុសាសន៍

បច្ចុប្បន្នដោយសង្កេតឃើញស្ថានភាពជាក់ស្តែង នៅក្នុងប្រទេសកម្ពុជាយើងមានការរីកចម្រើនលើគ្រប់វិស័យ ជាពិសេសវិស័យច្បាប់ គឺជាវិស័យមួយដែលដើរតួនាទីយ៉ាងសំខាន់សម្រាប់រក្សាស្ថិរភាព និងការអភិវឌ្ឍសង្គមជាតិ ហើយក៏ជាវិស័យមួយដ៏សំខាន់សម្រាប់ការដឹកនាំក៏ដូចជាការគ្រប់គ្រងប្រទេសជាតិឱ្យមាន សុខសន្តិភាព សណ្តាប់ធ្នាប់ របៀបរៀបរយល្អ។ ហេតុនេះប្រជាជនគ្រប់រូប ទោះបីជាកម្មករ និយោជិត និយោជក ជាអ្នកបម្រើការនៅក្នុងស្ថាន័បឯកជន ឬ មួយក៏ជាមន្ត្រីរាជការសាធារណៈ ត្រូវតែគោរពច្បាប់ទាំងអស់គ្នា។ ជាពិសេសស្ថាប័ន ឬ អង្គភាពដែលមានសមត្ថកិច្ចពាក់ព័ន្ធ ដូចជាតុលាការ ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃត្រូវធ្វើយ៉ាងណាដើម្បីឱ្យការអនុវត្តច្បាប់តឹងរឹង ត្រឹមត្រូវ និងមានប្រសិទ្ធភាព។ កាន់តែពិសេសនោះគឺចៅក្រមដែលជាអ្នកកាត់សេចក្តីតំណាងឱ្យស្ថាប័នតុលាការត្រូវជៀសឱ្យឆ្ងាយអំពី ឆន្ទាគតិ សេចក្តីលំអៀងព្រោះស្រលាញ់ ទោសាគតិ សេចក្តីលំអៀងព្រោះស្អប់ មោហាគតិ សេចក្តីលំអៀងព្រោះល្ងង់ ភយាគតិ សេចក្តីលំអៀង ព្រោះខ្លាចបុណ្យខ្លាចអំណាច ឬ ខ្លាចគតិ នៅក្នុងពេលដែលខ្លួនធ្វើការវិនិច្ឆ័យ និងសម្រេចសេចក្តី។ ដោយប្រព័ន្ធតុលាការក៏គួរតែខិតខំធ្វើយ៉ាងណាបង្កើតឱ្យមានចៅក្រមដែលទទួលបន្ទុកជំនុំជម្រះលើរឿងក្តីតែមួយជំនាញបានហើយ ដូចជាចៅក្រមផ្នែករដ្ឋប្បវេណី ផ្នែកព្រហ្មទណ្ឌ ផ្នែកពាណិជ្ជកម្ម ផ្នែកការងារផ្សេងគ្នា មិនគួរឱ្យចៅក្រមតែម្នាក់ធ្វើការវិនិច្ឆ័យគ្រប់ជំនាញដែលនាំឱ្យការសម្រេចសេចក្តីពុំសូវទទួលបាននូវលទ្ធផលល្អ។ ចំពោះក្រសួងមហាផ្ទៃនៅពេលដែលតុលាការបានចេញសាលក្រម ឬ សាលដីកាស្ថាពរហើយ គឺត្រូវខិតខំធ្វើយ៉ាងណាដើម្បីធានាថាការអនុវត្តសាលក្រម ឬ សាលដីកាឱ្យបានត្រឹមត្រូវទៅតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន។ ការបែងចែកបែបនេះ គឺក្នុងគោលបំណងដើម្បីធានាថា ការវិនិច្ឆ័យរឿងក្តីនឹងកាន់តែមានសុក្រឹតភាព ដែលភាគីទាំងសងខាងអាចទទួលយកបាន និងមានការស្ងប់ចិត្តនឹងសេចក្តីសម្រេចនោះ។ ចំណែកឯសាលាជម្រះក្តីជាន់ខ្ពស់ គឺសាលាឧទ្ធរណ៍ក៏គួរតែបង្កើតឱ្យមានបន្ថែមទៀតនៅតាមបណ្តាតំបន់ទាំងអស់នៅប្រទេសកម្ពុជា ដើម្បីបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការធ្វើឧបាស្រ័យទៅតុលាការជាន់ខ្ពស់ កាត់បន្ថយការចំណាយ និងពេលវេលាក្នុងការស្វែងរកយុត្តិធម៌។ ព្រោះថាសព្វថ្ងៃនេះសាលាឧទ្ធរណ៍គឺមាននៅរាជធានីភ្នំពេញ និងតំបន់ចំនួនបីតែប៉ុណ្ណោះ ដូច្នេះនៅពេលភាគីណាមួយមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាជម្រះក្តីជាន់ទាប គឺពិតជាមានការលំបាកក្នុងការប្តឹងមកសាលាឧទ្ធរណ៍ណាស់ ជាពិសេសប្រជាជនក្រីក្រដែលរស់នៅតំបន់ដាច់ស្រយាល និងប្រជាពលរដ្ឋនៅមានកម្រិតផងនោះ ធ្វើឱ្យពួកគាត់ទទួលបាននូវភាពយុត្តិធម៌មិនដូចគ្នាទេ។ ប្រសិនបើធ្វើការពង្រីកបន្ថែមនូវសាលាឧទ្ធរណ៍ទៅតាមបណ្តាតំបន់នានា គឺមានន័យថាជាការធ្វើឱ្យមានសមភាពផ្នែកយុត្តិធម៌សម្រាប់ប្រជាជននៅទីក្រុង និងជនបទ។

# ឯកសារយោង

## ១. លិខិតបទដ្ឋានគតិយុត្ត

- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
- សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៨
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

## ២. សៀវភៅ និង ស្នាដៃអ្នកនិពន្ធ

- សៀវភៅច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
- សៀវភៅមេរៀន ស្តីពីបណ្តឹងឧទ្ធរណ៍ ឧទ្ទេសនាមដោយ លោកមេធាវី អ៊ីវ ប៉ូលី
- សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១៖ នីតិវិធីបណ្តឹង។

## បញ្ជីឧបសម្ព័ន្ធ

**១. គំរូសាលក្រមរដ្ឋប្បវេណីដែលអាចប្តឹងឧទ្ធរណ៍**

**២. គំរូពាក្យបណ្តឹង**

- ពាក្យបណ្តឹងធម្មតា
- ពាក្យបណ្តឹងឧទ្ធរណ៍
- ពាក្យបណ្តឹងសាទុក្ខ
- ពាក្យបណ្តឹងជំទាស់
- ពាក្យសុំអនុវត្តដោយបណ្តោះអាសន្ន
- ពាក្យសុំដកពាក្យបណ្តឹង

**៣. លិខិតជូនដំណឹង និងដីកាបង្គាប់ឱ្យដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹង**

- ដីកាបង្គាប់ឱ្យដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ
- លិខិតជូនដំណឹងអំពីការទទួលពាក្យបណ្តឹងជំទាស់ និងឱ្យដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងជំទាស់
- លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹង

**៤. ដីកាបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តី**

✍📖✍

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង

សាលក្រមលេខ
ចុះថ្ងៃទី ខែ ឆ្នាំ
សំណុំរឿងរដ្ឋប្បវេណីលេខ
ចុះថ្ងៃទី ខែ ឆ្នាំ

## គាថនាមប្រជារាស្ត្រខ្មែរ

ការបរិច្ឆេទ នៃការបញ្ចប់ការទាញហេតុផលផ្ទាត់មាត់ ថ្ងៃទី ខែ ឆ្នាំ
កាលបរិច្ឆេទ នៃប្រកាសសាលក្រមលេខ ចុះថ្ងៃទី ខែ ឆ្នាំ នៅ
សាលាដំបូង ។

**កម្មវត្ថុបណ្តឹង:** ប្តឹងសុំទាមទារប្រាក់

**សមាសភាពជំនុំជម្រះ**

-លោក ជាចៅក្រមជំនុំជម្រះ

-លោក ជាក្រឡាបញ្ជីសវនាការ

**ភាគីដែលបង្ហាញខ្លួនជាអាទិ៍:**

-ដើមចោទឈ្មោះ តំណាងឲ្យ
អាសយដ្ឋានស្ថិតនៅ មហាវិថី សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

-អ្នកតំណាងដោយអាណត្តិឈ្មោះ អត្តលេខ និង ឈ្មោះ
អត្តលេខ ជាមេធាវីនៃ មានការិយាល័យនៅ
ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

-ចុងចម្លើយឈ្មោះ ភេទ អាយុ ឆ្នាំ ជាតិខ្មែរ និងប្រពន្ធឈ្មោះ ភេទ
អាយុ ឆ្នាំ ជាតិខ្មែរ មានទីលំនៅផ្ទះលេខ ក្រុមទី ភូមិ ក្រុង ខេត្ត
។

-អ្នកតំណាងដោយអាណត្តិកញ្ញា អត្តលេខ ជាមេធាវីនៃ

## អង្គហេតុ និង ចំណុចទទាស

**សាលក្រមដែលទាមទារដោយដើមចោទ**

-បង្គាប់ឲ្យចុងចម្លើយសងប្រាក់ដើមចំនួន ( ) ដុល្លាអាមេរិច

-បង្គាប់ឲ្យចុងចម្លើយបង់ការប្រាក់ ( ) ក្នុង ឆ្នាំ តាមការព្រមព្រៀងក្នុងកិច្ចសន្យាលើប្រាក់ដើម ( ) ដុល្លាអាមេរិក គិតចាប់ពីថ្ងៃទី ខែ ឆ្នាំ រហូតដល់ថ្ងៃសងគ្រប់ចំនួន ( ) ដុល្លាអាមេរិក តាមការព្រមព្រៀង។

-បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ពិន័យតាមកិច្ចសន្យា ចំពោះការខកខានបង់ប្រាក់តាមការកំណត់ ( ) ក្នុង ឆ្នាំ ។

-បង្គាប់ឲ្យចុងចម្លើយសងប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្តី ( ) រៀល លើពាក្យបណ្តឹង និងពន្ធផ្សេងៗ មក គ្រឹះស្ថាន វិញ ។

-បង្គាប់ឲ្យចុងចម្លើយសងការខូចខាតចំនួន ( ) ដុល្លាអាមេរិក ។

-បង្គាប់ឲ្យចុងចម្លើយសងថ្លៃសេវាមេធាវីចំនួន ( ) ដុល្លាអាមេរិក ។

-សុំឲ្យតុលាការប្រកាសអនុវត្តជាបណ្តោះអាសន្ន ។

## ការពន្យល់រឿងក្តីគ្រួសៗ

-អង្គហេតុដែលជាមូលហេតុនៃការទាមទារ

នៅថ្ងៃទី ខែ ឆ្នាំ ឈ្មោះ និងឈ្មោះ បានខ្ចីចងការប្រាក់ពី គ្រឹះស្ថាន ចំនួន ( ) ដុល្លាអាមេរិក តាមរយៈកិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ និងយល់ព្រមបង់ការប្រាក់ចំនួន ( ) ក្នុងមួយឆ្នាំ ។ ដើម្បីធានាបំណុលនេះ ចុងចម្លើយបានយកដី និងផ្ទះដែលមានលិខិតបញ្ជាក់ផ្ទេរសិទ្ធិកាន់កាប់លេខ ចុះថ្ងៃទី ខែ ឆ្នាំ ដែលមានទីតាំងស្ថិតនៅភូមិ សង្កាត់ ក្រុង ខេត្ត មកដាក់បញ្ចាំនៅ គ្រឹះស្ថាន ។ តាមកិច្ចសន្យាខាងលើនេះ ឈ្មោះ និងឈ្មោះ បានសន្យាសងបំណុលឲ្យ គ្រឹះស្ថាន ក្នុងរយៈពេល ( ) ខែ ដោយបង់រំលោះក្នុងរយៈពេល ខែម្តង តាមតារាងបង់ប្រាក់គិតពីថ្ងៃទី ខែ ឆ្នាំ រហូតដល់ថ្ងៃដែលសងប្រាក់គ្រប់ចំនួន ។ បន្ទាប់ពីបានទទួលប្រាក់កម្ចីពី គ្រឹះស្ថាន សរុបចំនួន ( ) ដុល្លាអាមេរិក រួចមកឈ្មោះ និងប្រពន្ធឈ្មោះ បានសងប្រាក់ដើមចំនួន ( ) ដុល្លាអាមេរិក តែប៉ុណ្ណោះមកឲ្យ គ្រឹះស្ថាន ហើយក៏ឈប់បង់រហូតដល់ពេលបច្ចុប្បន្ននេះ ។ ទោះបីជាខាងគ្រឹះស្ថាន ព្យាយាមចេញលិខិត អញ្ជើញជាស់តឿនឲ្យសងប្រាក់ជាច្រើនដងក៏ដោយ ក៏ចុងចម្លើយទាំងពីរនាក់ប្តីប្រពន្ធពុំព្រមចូលមកដោះស្រាយ

ជាមួយ គ្រឹះស្ថាន ឡើយ ហេតុដូច្នេះទើបនៅថ្ងៃទី ខែ ឆ្នាំ

ដើមចោទក៏បានដាក់ពាក្យបណ្តឹងមកតុលាការ ប្តឹងសុំទាមទារប្រាក់ពីចុងចម្លើយតែម្តង ។

-ភស្តុតាង

-កិច្ចសន្យាខ្ចីចងការប្រាក់ចុះថ្ងៃទី ខែ ឆ្នាំ រវាងអ្នកខ្ចីឈ្មោះ និងលោកស្រី និងអ្នកឲ្យខ្ចីឈ្មោះ ដែលមានមេធាវី ។

-កិច្ចសន្យាហ៊ីប៉ូតែកថ្ងៃទី ខែ ឆ្នាំ រវាងភាគីអ្នកបង្កើតហ៊ីប៉ូតែកឈ្មោះ និងភាគីម្ចាស់បំណុលហ៊ីប៉ូតែកឈ្មោះ ដែលមានមេធាវី មេភូមិ មេឃុំ ឈ្មោះ និងអភិបាលស្រុក ។

-លិខិតបញ្ជាក់ផ្ទេរសិទ្ធិកាន់កាប់ចុះថ្ងៃទី ខែ ឆ្នាំ របស់អ្នកផ្ទេរលោក និងអ្នកស្រី ដែលមានសាក្សីទី១ ឈ្មោះ សាក្សីទី២ឈ្មោះ បានឃើញចៅសង្កាត់ ឈ្មោះ និងបានឃើញឯកភាពអភិបាលក្រុង ឈ្មោះ ។

-លិខិតរបស់នាយកប្រតិបត្តិនៃ គ្រឹះស្ថាន គោរពជូនលោកចៅសង្កាត់ សំណើសុំទប់ស្កាត់ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ ។

-ពាក្យសុំទប់ស្កាត់ការលក់ដូរ ឬ ផ្ទេរកម្មសិទ្ធិដីនិងផ្ទះ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ ។

-លិខិតជូនដំណឹងពីការបង់ប្រាក់របស់ គ្រឹះស្ថាន ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ និងមេធាវី ។

-លិខិតជូនដំណឹងពីការបង់ប្រាក់របស់ គ្រឹះស្ថាន ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ និងមេធាវី និងស្នាមមេដៃឈ្មោះ ត្រូវជា ។

-សៀវភៅគ្រួសារផ្ទះលេខ ក្រុមទី ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ របស់ឈ្មោះ ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ របស់ឈ្មោះ ។

-តារាងរបាយការណ៍គណនាការប្រាក់ និង ប្រាក់ពិន័យ ( លេខ ) សរុបប្រាក់ត្រូវបង់គិតត្រឹមថ្ងៃទី ខែ ឆ្នាំ ។

## <u>អះអាងរបស់ភាគី</u>

-មេធាវី តំណាងដោយអាណត្តិឲ្យដើមចោទបានថ្លែងការណ៍ថា៖

ខ្ញុំបានរក្សាការទាមទារដូចនៅក្នុងពាក្យបណ្តឹងរបស់ឈ្មោះ និងសុំបញ្ជាក់បន្ថែមថា គ្រឹះស្ថាន បានអញ្ជើញចុងចម្លើយឲ្យមកបង់ប្រាក់ជូន គ្រឹះស្ថាន តាមកិច្ចព្រមព្រៀងតារាងបង់ប្រាក់របស់ គ្រឹះស្ថាន វិញ ប៉ុន្តែចុងចម្លើយមិនបានអនុវត្តទៅតាមការអញ្ជើញរបស់ គ្រឹះស្ថាន នៅឡើយ ។

ខ្ញុំសូមបញ្ជាក់ថា៖

១.ចុងចម្លើយបានខ្ចីប្រាក់ពី គ្រឹះស្ថាន សរុបចំនួន (ពីរម៉ឺនប្រាំពាន់) ដុល្លាអាមេរិច ដោយត្រូវបង់រំលោះរយៈ ( ) ខែទៅ តាមតារាងបង់ប្រាក់ ចុះថ្ងៃទី ខែ រហូតគ្រប់ចំនួន ប៉ុន្តែបានបង់ប្រាក់ដើមមកកូនក្តីខ្លួនចំនួន ( ) ដុល្លាអាមេរិក ប៉ុណ្ណោះ ហើយមិនបានបង់រហូតដល់សព្វថ្ងៃ ។ ប្រាក់ដើមដែលនៅសល់គឺ ( ) ដុល្លាអាមេរិក ។

២.ការប្រាក់ចំនួន ( ) ក្នុងមួយឆ្នាំ គឺទាមទារតាមការព្រមព្រៀងរបស់ភាគី ។ ការប្រាក់សុំគិតចាប់ពីថ្ងៃទី ខែ ឆ្នាំ រហូតអនុវត្តកាតព្វកិច្ចចប់ ។

៣.ប្រាក់ពិន័យចំនួន ( ) គឺគិតចាប់ពីថ្ងៃទី ខែ ឆ្នាំ រហូតបង់អស់ ។

៤-បង្គាប់ឲ្យចុងចម្លើយសងការខូចខាតចំនួន ( ) ដុល្លាអាមេរិក ។

៥.ចុងចម្លើយត្រូវសងសោហ៊ុយសេវាមេធាវីរបស់ដើមចោទ ចំនួន ( ) ដុល្លាអាមេរិក ព្រោះដើមចោទចំណាយសេវាមេធាវីអស់ចំនួន ( ) ដុល្លាអាមេរិក។

៦.ការសុំឲ្យតុលាការប្រកាសសាលក្រមអនុវត្តជាបណ្តោះអាសន្នដោយហេតុថា កូនក្តីខ្លួនខ្ញុំបារម្ភថា ខ្លាចចុងចម្លើយប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដើម្បីអូសបន្លាយពេលវេលាក្នុងការសងប្រាក់ ហើយធ្វើឲ្យខូចប្រយោជន៍កូនក្តីខ្ញុំធ្ងន់ធ្ងរ ជាងនេះទៅទៀត កូនក្តីខ្ញុំមានភស្តុតាងគ្រប់គ្រាន់ ដែលអាចបញ្ជាក់បានថា ចុងចម្លើយពិតជាជំពាក់ប្រាក់តាមការទាមទាររបស់កូនខ្ញុំបាទមែន ។

-មេធាវី តំណាងដោយអាណត្តិឲ្យចុងចម្លើយបានថ្លែងការណ៍ថា៖

១.កូនក្តីខ្លួនពិតជាបានខ្ចីប្រាក់ពីគ្រឹះស្ថាន ប្រាក់ចំនួន ( ) មែនហើយ តែបានសងខ្លះនៅសល់មិនទាន់សង គ្រឹះស្ថាន ប្រាក់ចំនួន ( ) ដុល្លាអាមេរិក ។

២.ចំពោះអត្រាការប្រាក់សូមឲ្យតុលាការអនុវត្តតាមផ្លូវច្បាប់ ក្នុងមួយឆ្នាំ មិនទទួលស្គាល់ ក្នុងមួយឆ្នាំដែលកូនក្តីខ្លួនព្រមព្រៀងជាមួយ គ្រឹះស្ថាន ។

៣.ប្រាក់ពិន័យសូមឲ្យតុលាការសម្រេចតាមការព្រមព្រៀង ដូចមានចែងក្នុងកិច្ចសន្យាខ្ចីចងការប្រាក់ និងអនុវត្តចាប់ពីថ្ងៃទី ខែ ឆ្នាំ ទៅ ។

៤.សូមច្រានចោលនៅការទាមទាររបស់មេធាវីដើមបណ្តឹង

-អត្រាការប្រាក់

-សំណងជំងឺចិត្ត និងថ្លៃសេវាមេធាវី

-ប្រាក់ពន្ធ និងប្រាក់ប្រម៉ាប់ក្តីរបស់ដើមបណ្តឹង

## ចំណុចខខាត និងចំណុចគ្មានខខាត

-ចំណុចវិវាទ

១-អត្រាការប្រាក់ ។

២-ជំងឺចិត្តសងការខូចខាត ជាប្រាក់ចំនួន ( ) ដុល្លារអាមេរិក និង ថ្លៃសេវាមេធាវី ជាប្រាក់ចំនួន ( ) ដុល្លារអាមេរិក ។

៣-ប្រាក់ពន្ធ និង ប្រាក់ប្រដាប់ក្ដីលើពាក្យបណ្ដឹង ។

-ចំណុចគ្មានវិវាទ

១.ចុងចម្លើយបានខ្ចីប្រាក់ពី គ្រឹះស្ថាន សរុបចំនួន ( ) ដុល្លារអាមេរិច ដោយត្រូវបង់រំលោះរយៈ ( ) ខែទៅតាមតារាងបង់ប្រាក់ ចុះថ្ងៃទី ខែ រហូតគ្រប់ចំនួន ប៉ុន្តែបានបង់ប្រាក់ដើមមកកូនក្ដីខ្លួនចំនួន ( ) ដុល្លារអាមេរិក ប៉ុណ្ណោះ ហើយមិនបានបង់រហូតដល់សព្វថ្ងៃ ប្រាក់ដើមដែលនៅសល់ ( ) ដុល្លារអាមេរិក។

២.ប្រាក់ពិន័យចំនួន ( ) គឺគិតចាប់ពីថ្ងៃទី ខែ ឆ្នាំ រហូតបង់អស់ ។

៣.សុំឲ្យតុលាការប្រកាសសាលក្រមអនុវត្តជាបណ្ដោះអាសន្ន ។

## សំអាងហេតុ

តាមលទ្ធផល នៃការសាកសួរសាម័ខ្លួន និងពិនិត្យភស្តុតាង ក្នុងនីតិវិធីសាកសួរចប់សព្វគ្រប់៖

១-ពាក្យបណ្ដឹង ចុះថ្ងៃទី ខែ ឆ្នាំ របស់ដើមចោទឈ្មោះ មានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ ដែលអាចឲ្យតុលាការលើកយកធ្វើការទាញហេតុផលតាមបទបញ្ញត្តមាត្រា៩, មាត្រា ២៣ និងចេញសាលក្រមតាមបទបញ្ញត្តមាត្រា ១៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២-ដើមចោទឈ្មោះ តំណាងឲ្យ គ្រឹះស្ថាន បានទាមទារឲ្យចុងចម្លើយសងប្រាក់ដើមចំនួន ( ) ដុល្លារអាមេរិក យោងភស្តុតាង កិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ កិច្ចសន្យាហ៊ីប៉ូតែក ចុះថ្ងៃទី ខែ ឆ្នាំ , លិខិតបញ្ជាក់ផ្ទេរសិទ្ធិកាន់កាប់លេខ ចុះថ្ងៃទី ខែ ឆ្នាំ និងតារាងរបមន្តគណនាការប្រាក់ និងប្រាក់ពិន័យ កិច្ចសន្យានេះធ្វើឡើងដោយមានការព្រមព្រៀង គ្មានវិការៈ ស្របតាមមាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណី ចំណែកឯចុងចម្លើយក៏បានសារភាពថា ពិតជាបានខ្ចីលុយពី គ្រឹះស្ថាន ដូចការអះអាងរបស់ដើមចោទមែន ។ ការលើកឡើងនេះ ធ្វើឲ្យតុលាការជឿបាន ដោយហេតុថា ដើមចោទមានភស្តុតាងជាឯសារច្បាស់លាស់ អាចឲ្យតុលាការលើកយកពិចារណា និងសម្រេចបាន ។

៣-ការប្រគល់ ឬទទួលប្រាក់នេះ គឺជាការប្រើប្រាស់ក្រោមទម្រង់ជាកិច្ចសន្យាខ្ចីបរិភោគ ដោយអនុលោមតាមមាត្រា ៥៧៨ និងមាត្រា ៥៨៣ នៃក្រមរដ្ឋប្បវេណី ប៉ុន្តែយើងពិនិត្យមើលឃើញថា ចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចតាមការវិភាគសងប្រាក់របស់ គ្រឹះស្ថាន នោះទេ ដែលបានកំណត់ក្នុងកិច្ចព្រមព្រៀង ។

៤-ដើមចោទឈ្មោះ តំណាងឲ្យ គ្រឹះស្ថាន បាន ទាមទារការប្រាក់ ( ) ក្នុងមួយឆ្នាំ គិតចាប់ពីថ្ងៃទី ខែ ឆ្នាំ

ពីចុងចម្លើយឈ្មោះ និងឈ្មោះ យោងកិច្ចសន្យារបស់ភាគីពិតជាបានចែងអំពីការប្រាក់ចុះថ្ងៃទី ខែ ឆ្នាំ ចំណែកឯចុងចម្លើយស្នើសុំ ( ) ក្នុងឆ្នាំ ។ ការទាមទាររបស់ចុងចម្លើយត្រឹមត្រូវតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លេខ ១២៦ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ ត្រង់ប្រការ១ និងប្រការ២ បានកំណត់ជាក់លាក់អំពីការកំណត់ការប្រាក់ថា:

- ប្រការ១ អត្រាការប្រាក់ដែលត្រូវបានកម្រិតដែលបានកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា ១៧ (អត្រាការប្រាក់ដែលត្រូវកម្រិតជាអាទិ៍) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឲ្យលើសពី ១៨% (ដប់ប្រាំបីភាគរយ) ក្នុង ០១ (មួយ) ឆ្នាំ ។

- ប្រការ២ អត្រាការប្រាក់ ដែលព្រមព្រៀងជាមុនក្នុងការសងសំណងក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ ដែលបានកំណត់ក្នុងកថាខណ្ឌទី ៣ នៃមាត្រា ១៧ (អត្រាការប្រាក់ដែលត្រូវបានកម្រិតជាអាទិ៍) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឲ្យលើសពីចំនួន ១,៥ (មួយក្បៀសប្រាំ) ដង នៃអត្រាការប្រាក់ដែលបានកំណត់ក្នុងប្រការ ១ ខាងលើ ។

អនុលោមតាមប្រការខាងលើ ជាពិសេសត្រង់ប្រការ ២ តុលាការឃើញថា អត្រាការប្រាក់ដែលព្រមព្រៀងជាមុន គឺត្រូវកំណត់មិនឲ្យលើសពី ២៧% ក្នុងមួយឆ្នាំឡើយ (១៨% x ១,៥ = ២៧%) ឬស្មើនឹង ២,២៥ ក្នុងមួយខែ ។ ដោយពិនិត្យទៅលើការទាមទារអត្រារបស់ចុងចម្លើយគឺមានចំនួន ១,៥% ក្នុងមួយខែ ស្មើនឹង ១៨% ក្នុងមួយឆ្នាំ ត្រឹមត្រូវនឹងគោលការណ៍ខាងលើ ដូច្នេះតុលាការគប្បីសម្រេចអំពើអត្រាការប្រាក់តាមស្នើសុំរបស់ចុងចម្លើយ ។

៥-គ្រឹះស្ថាន ដោយមានឈ្មោះ ជាអ្នកតំណាងបានទាមទារថ្លៃសេវាមេធាវី ពីចុងចម្លើយឈ្មោះ និងឈ្មោះ សងការខូចខាតចំនួន ( ) ដុល្លាអាមេរិក និងសងថ្លៃសេវាធាវីចំនួន ( ) ដុល្លាអាមេរិក ប៉ុន្តែដោយហេតុថា ដើមចោទមិនបានបង្ហាញភស្តុតាងទាក់ទង ទៅនឹងចំណាយលើសេវាមេធាវី មកតុលាការនោះទេ ដូច្នេះតុលាការនឹងធ្វើការសម្រេចតាមតថភាពជាក់ស្តែង ដោយអនុលោមតាមមាត្រា ៤០០ នៃក្រមរដ្ឋប្បវេណី ។

៦-គ្រឹះស្ថាន តំណាងដោយឈ្មោះ សុំតុលាការអនុវត្តន៍សាលក្រមជាបណ្តោះអាសន្នលើប្រាក់ដើម តុលាការយល់ឃើញផងដែរថា មានភាពចាំបាច់នៅក្នុងការអនុវត្តជាបណ្តោះអាសន្ន យោងតាមមាត្រា ១៩៦ នៃនីតិវិធីក្រមរដ្ឋប្បវេណី ដូច្នេះតុលាការគប្បីសម្រេចអនុវត្តន៍បណ្តោះអាសន្នសាលក្រមនេះជាបណ្តោះអាសន្ន ។

៧-ចំពោះប្រាក់ប្រដាប់ក្តី គប្បីតុលាការសម្រេចតាមមាត្រា ៦៨ កថាខណ្ឌ ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី "ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ភាគីចាញ់ក្តី ។ ក្នុងករណីដែលបានចាញ់ក្តីតែមួយភាគទេ តុលាការត្រូវសម្រេចនូវបន្ទុកដែលភាគីម្នាក់ៗ ត្រូវទទួលដោយផ្អែកលើសិទ្ធិរបស់ខ្លួន " ។

## <u>សេចក្តីសម្រេចបញ្ចាប់</u>

I. ទទួលស្គាល់បណ្តឹងរបស់ដើមចោទទុកជាបានការស្របតាមច្បាប់ ។

II. បង្គាប់ឲ្យចុងចម្លើយឈ្មោះ និងឈ្មោះ សងប្រាក់ដើមចំនួន ( ) ដុល្លារអាមេរិក និងការប្រាក់ ១៨% (ដប់ប្រាំបី) ភាគរយ ក្នុងមួយឆ្នាំ គិតចាប់ពីថ្ងៃទី ខែ ឆ្នាំ រហូតដល់ពេលសងប្រាក់អស់ ទៅ គ្រឹះស្ថាន ។

III. បង្គាប់ឲ្យចុងចម្លើយឈ្មោះ និងឈ្មោះ បង់ប្រាក់ពិន័យ ( ) ក្នុងមួយឆ្នាំ លើចំនួនទឹកប្រាក់ដែលត្រូវបង់ឲ្យដើមចោទ គ្រឹះស្ថាន គិតចាប់ពីថ្ងៃទី ខែ ឆ្នាំ រហូតអនុវត្តកាតព្វកិច្ចចប់ ។

IV. បង្គាប់ឲ្យចុងចម្លើយឈ្មោះ និងឈ្មោះ សងសោហ៊ុយសេវាមេធាវី ចំនួន ( ) ដុល្លារអាមេរិក ឲ្យគ្រឹះស្ថាន ។

V. សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នលើប្រាក់ដើម ។

VI. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

ចៅក្រមជំនុំជម្រះ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យបណ្តឹង

**▪ដើមចោទ:** ឈ្មោះ..........................ភេទ......អាយុ..............ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ:.....................ចុះថ្ងៃទី..................... ដែលមានអាសយដ្ឋានបច្ចុប្បន្ននៅភូមិ...............ឃុំ/សង្កាត់.................ស្រុក/ខណ្ឌ................ខេត្ត/រាជធានី..................លេខទូរស័ព្ទ........................។

**▪ចុងចម្លើយ:** ឈ្មោះ..............................ភេទ......អាយុ..............ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ:........................ចុះថ្ងៃទី............... ដែលមានអាសយដ្ឋានបច្ចុប្បន្ននៅភូមិ...............ឃុំ/សង្កាត់.................ស្រុក/ខណ្ឌ..................ខេត្ត/រាជធានី..................លេខទូរស័ព្ទ..........................។

**សូមគោរពជូន**

**ឯកឧត្តមប្រធានសាលាដំបូងខេត្ត/រាជធានី.....................**

**▪ កម្មវត្ថុ ឬខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ:**

សូមឲ្យតុលាការសម្រេចនូវសាលក្រម ដែលមានខ្លឹមសារដូចខាងក្រោម:

១- ..............................................................................................................

២- ..............................................................................................................

**▪ អង្គហេតុចាំបាច់សម្រាប់បញ្ជាក់ការទាមទារ:**

..............................................................................................................
..............................................................................................................
..............................................................................................................

**▪ អង្គហេតុដែលជាមូលហេតុនៃការទាមទារ និងអង្គហេតុសំខាន់ៗដែលពាក់ព័ន្ធ:**

..............................................................................................................
..............................................................................................................
..............................................................................................................

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវពាក្យបណ្តឹង និងចាត់ការតាមនិតិវិធីច្បាប់ ដោយសម្រេចតាមការទាមទារខាងលើ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំបាទ/នាងខ្ញុំ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

រាជធានី/ខេត្ត............ ថ្ងៃទី.......ខែ............ឆ្នាំ............

ស្នាមមេដៃស្តាំអ្នកប្តឹង

សូមភ្ជាប់មកជាមួយ:

១-...................

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យបណ្តឹង**

**▪ជូនចំពោះ:** **ឯកឧត្តមប្រធានសាលាដំបូងខេត្ត/រាជធានី........................................**

**▪ដើមចោទ:** *ឈ្មោះ.........................ភេទ.....អាយុ.............ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ:...................ចុះថ្ងៃទី................ ដែលមានអាសយដ្ឋានបច្ចុប្បន្ននៅភូមិ...............ឃុំ/សង្កាត់................ស្រុក/ខណ្ឌ................ខេត្ត/រាជធានី..................លេខទូរស័ព្ទ.........................។*

**▪អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ:** *លោកមេធាវី.........................................*
*ការិយាល័យស្ថិតនៅអាគារលេខ...........ផ្លូវលេខ.................ឃុំ/សង្កាត់........ ស្រុក/ខណ្ឌ.........................ខេត្ត/រាជធានី.........................................។*

**▪ចុងចម្លើយ:** *ឈ្មោះ.............................ភេទ......អាយុ..............ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ:........................ចុះថ្ងៃទី............... ដែលមានអាសយដ្ឋានបច្ចុប្បន្ននៅភូមិ...............ឃុំ/សង្កាត់................ស្រុក/ខណ្ឌ..................ខេត្ត/រាជធានី..................លេខទូរស័ព្ទ.........................។*

**▪ កម្មវត្ថុ ឬខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ:**

*សូមឲ្យតុលាការសម្រេចនូវសាលក្រម ដែលមានខ្លឹមសារដូចខាងក្រោម:*

១- ........................................................................................................

២- ........................................................................................................

**▪ អង្គហេតុចាំបាច់សម្រាប់បញ្ជាក់ការទាមទារ:**

........................................................................................................
........................................................................................................
........................................................................................................

**▪អង្គហេតុដែលជាមូលហេតុនៃការទាមទារ និងអង្គហេតុសំខាន់ៗដែលពាក់ព័ន្ធ:**

........................................................................................................
........................................................................................................
........................................................................................................

*អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម* **ឯកឧត្តមប្រធាន** *មេត្តាទទួលនូវពាក្យបណ្តឹង និងចាត់ការតាមនិតិវិធីច្បាប់ ដោយសម្រេចតាមការទាមទារខាងលើ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំបាទ/នាងខ្ញុំ។*

*សូម* **ឯកឧត្តមប្រធាន** *មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។*

*រាជធានី/ខេត្ត............ ថ្ងៃទី......ខែ............ឆ្នាំ...........*

**ស្នាមមេដៃស្តាំអ្នកប្តឹង**

*សូមភ្ជាប់មកជាមួយ:*

១-...................

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យបណ្តឹងឧទ្ធរណ៍

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ........................ ភេទ............. អាយុ.............. ឆ្នាំ.............. ជនជាតិ........... មានអាសយដ្ឋានផ្ទះលេខ......... ផ្លូវ......... ភូមិ................. ឃុំ/សង្កាត់................ ក្រុង/ស្រុក/ខណ្ឌ............. រាជធានី/ខេត្ត..........................។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានី/ខេត្ត**..................

**__កម្មវត្ថុ__**៖ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខ........... ចុះថ្ងៃទី....... ខែ......... ឆ្នាំ.......... របស់សាលាដំបូងរាជធានី/ខេត្ត............. ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល/ចំណុចទី....................។

**យោង**៖ -ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

-សំណុំរឿងរដ្ឋប្បវេណីលេខ.............. ចុះថ្ងៃទី........ ខែ.......... ឆ្នាំ............. របស់សាលាដំបូងរាជធានី/ខេត្ត................។

-សាលក្រមលេខ............................. ចុះថ្ងៃទី........... ខែ.............. ឆ្នាំ............. របស់សាលាដំបូងរាជធានី/ខេត្ត....................។

តបតាមកម្មវត្ថុ និងយោងខាងលើខ្ញុំបាទ/នាងខ្ញុំ សូមជម្រាប **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ កាលពីថ្ងៃទី......... ខែ....... ឆ្នាំ......... សាលាដំបូងរាជធានី/ខេត្ត............ បានចេញសាលក្រមលេខ................ ចុះថ្ងៃទី........... ខែ.............. ឆ្នាំ............. ។ ដោយសាលក្រមខាងលើមានភាពអយុត្តិធ៌ម និង ធ្វើឲ្យបាត់បង់ផលប្រយោជន៏របស់ខ្ញុំបាទ/នាងខ្ញុំ ហេតុនេះហើយបានជាខ្ញុំបាទ/នាងខ្ញុំសុំប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខ................ ចុះថ្ងៃទី......... ខែ........... ឆ្នាំ............... របស់សាលាដំបូងរាជធានី/ខេត្ត............. ត្រង់ចំណុចសេចក្តីសម្រេច....................... អាស្រ័យហេតុដូចបានគោរពជូនខាងលើសូម លោកប្រធាន មេត្តាទទួលនិងបញ្ជូនទៅសាលាឧទ្ធរណ៍ដើម្បីជួយរកយុត្តិធ៌មដោយអនុគ្រោះ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាទទួល និងចុះបញ្ជីបណ្តឹងឧទ្ធរណ៍តាមនីតិវិធីច្បាប់ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី....... ខែ....... ឆ្នាំ............

**ស្នាមមេដៃស្តាំ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# <u>ពាក្យបណ្តឹងឧទ្ធរណ៍</u>

ខ្ញុំមេធាវី.................. ជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ.............. នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ................ ចុះថ្ងៃទី......... ខែ............ ឆ្នាំ............ របស់សាលាដំបូង................ ។

**សូមគោរពជូន**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានី/ខេត្ត**..................

**<u>កម្មវត្ថុ</u>៖** សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខ........... ចុះថ្ងៃទី....... ខែ......... ឆ្នាំ.......... របស់សាលាដំបូងរាជធានី/ខេត្ត.............។

**<u>យោង</u>៖** -ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

-សំណុំរឿងរដ្ឋប្បវេណីលេខ.............. ចុះថ្ងៃទី........ ខែ.......... ឆ្នាំ.............. របស់សាលាដំបូងរាជធានី/ខេត្ត................។

-សាលក្រមលេខ............................. ចុះថ្ងៃទី........... ខែ............. ឆ្នាំ............ របស់សាលាដំបូងរាជធានី/ខេត្ត....................។

-លិខិតតំណាងដោយអាណត្តិចុះថ្ងៃទី.......... ខែ............. ឆ្នាំ............ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ កាលពីថ្ងៃទី.......... ខែ........... ឆ្នាំ........... សាលាដំបូង.............. បានចេញសាលក្រមលេខ............ ដោយបានសម្រេចប្រានចោលការទាមទាររបស់កូនក្តីខ្ញុំចោលទាំងស្រុង។ ការសម្រេចសេចក្តីនេះគឺជាការសម្រេចដ៏អយុត្តិធម៌បំផុតសម្រាប់កូនក្តីខ្ញុំដែលជាជនរងគ្រោះ។ អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាទទួល និងចុះបញ្ជីបណ្តឹងឧទ្ធរណ៍តាមនីតិវិធីច្បាប់ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី....... ខែ....... ឆ្នាំ............

**ស្នាមមេដៃស្តាំ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្តឹងសាទុក្ខ

**ដើមបណ្តឹងសាទុក្ខ ៖** លោក ............ ជាតិ.... កើតឆ្នាំ ............ និងប្រពន្ធឈ្មោះ .............. មានទីលំនៅបច្ចុប្បន្ន .................................................................។

**ចុងបណ្តឹងសាទុក្ខ ៖** - លោក......................ហៅ .............. ជាតិ....... មានទីលំនៅបច្ចុប្បន្ន .................................................................................................។

- លោក ......................ហៅ ........... ជាតិខ្មែរ អាយុ ៤៨ ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ................................................................... ។

- លោក ....................... ហៅ .................... ជាតិ...... អាយុ ..... ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ....................................................................។

**សូមគោរពជូន**

**ឯកឧត្តមប្រធានសាលាឧទ្ធរណ៍**

**កម្មវត្ថុ ៖** ប្តឹងសាទុក្ខនឹងសាលដីកាលេខ .................. ចុះថ្ងៃទី...... ខែ........ ឆ្នាំ............ របស់ .......................... ។

**យោង ៖** - ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

- សំណុំរឿងរដ្ឋប្បវេណីលេខ...........ចុះថ្ងៃទី.....ខែ......ឆ្នាំ..........របស់សាលាឧទ្ធរណ៍

- សាលដីកាលេខ........... ចុះថ្ងៃទី..... ខែ...... ឆ្នាំ.......... របស់សាលាឧទ្ធរណ៍។

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា កាលពីថ្ងៃទី......ខែ..... ឆ្នាំ.......... សាលាឧទ្ធរណ៍បានចេញសាលដីកាលេខ................ ដែលមានខ្លឹមសារដូចខាងក្រោម ៖

- ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ....... ចុះថ្ងៃទី...... ខែ........ ឆ្នាំ............ របស់មេធាវីឈ្មោះ .......................... អ្នកតំណាងដោយអាណត្តិឲ្យសហចុងចម្លើយឈ្មោះ ........................ ឈ្មោះ ................. និងឈ្មោះ .................... ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។
- លុបចោលសាលក្រមរដ្ឋប្បវេណីលេខ ............ ចុះថ្ងៃទី..... ខែ....... ឆ្នាំ........... របស់សាលាដំបូង..................ចោលជាអសារបង់ ។
- ច្រានពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ ........................ ចុះថ្ងៃទី..... ខែ....... ឆ្នាំ........... ចោលជាអសារបង់ ។
- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

ការសម្រេចសេចក្តីខាងលើនេះ គឺពិតជាបានផ្តល់នូវភាពអយុត្តិធម៌ជាទីបំផុតដល់យើងខ្ញុំ ដែលជាជនរងគ្រោះដោយសារការរំលោភបំពានរបស់ភាគីចុងចម្លើយ ដែលយើងខ្ញុំពុំអាចទទួលយកបានទេ ។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលយកបណ្តឹងសាទុក្ខ និងចាត់ការតាមនីតិវិធីច្បាប់ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី.....ខែ...... ឆ្នាំ.........

ស្នាមមេដៃស្តាំ

......................

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យបណ្ដឹងជំទាស់

ខ្ញុំបាទឈ្មោះ............... កើតនៅឆ្នាំ........... ជនជាតិ........... សញ្ជាតិ.......... មានទីលំនៅបច្ចុប្បន្ន ..........................................................................................................................។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធាន**..........................

**<u>កម្មវត្ថុ៖</u>** សុំប្ដឹងជំទាស់លើដីកាសម្រេចលេខ.............. ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ........... របស់ ........................។

**<u>យោង៖</u>** -មាត្រា............. ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

-ដីការសម្រេចលេខ........... ចុះថ្ងៃទី.......... ខែ............. ឆ្នាំ............ ។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជូន **ឯកឧត្តមប្រធាន** អោយបានជ្រាបថា៖ កាលពីថ្ងៃទី......... ខែ......... ឆ្នាំ........... តុលាការឧទ្ធរណ៍បានចេញសេចក្ដីសម្រេចលើសំណុំរឿងលេខ......... ចុះថ្ងៃទី....... ខែ......... ឆ្នាំ...........។ ការសម្រេចសេចក្ដីខាងលើនេះបានធ្វើអោយប៉ះពាល់ដល់ប្រយោជន៍ខ្ញុំបាទ/នាងខ្ញុំយ៉ាងធ្ងន់ធ្ងរ និងផ្ដល់នូវភាពអយុត្តិធម៌ដល់រូបខ្ញុំបាទ/នាងខ្ញុំដែលជាជនរងគ្រោះ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើនេះ ខ្ញុំបាទ/នាងខ្ញុំស្នើសុំ **ឯកឧត្តមប្រធាន** មេត្តាទទួលនិងចាត់ការតាមនីតិវិធីច្បាប់។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទនាងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី....... ខែ....... ឆ្នាំ............

**ស្នាមមេដៃស្ដាំ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំអនុវត្តដោយបណ្តោះអាសន្ន

**ម្ចាស់បំណុលអនុវត្ត៖** ឈ្មោះ........................ តំណាងស្របច្បាប់ដោយលោក........................ តួនាទី ................ អាសយដ្ឋាននៅ..................។

**កូនបំណុលអនុវត្ត៖** ឈ្មោះ............ ភេទ......... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ.................... អាសយដ្ឋាននៅ.................. ភូមិ..................... ។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធាន**..........................

**កម្មវត្ថុ៖** សុំអនុវត្តបណ្តោះអាសន្ន ត្រង់សេចក្តីសម្រេចបញ្ចប់ ចំណុចទី.............. នៃសាលក្រមរដ្ឋប្បវេណីលេខ............ ចុះថ្ងៃទី.......... ខែ....... ឆ្នាំ២០.......... របស់................. លើអចលនវត្ថុដែលជា ............................ មានផ្ទៃក្រឡា............... ម៉ែត្រការ៉េ ជាដីលំនៅដ្ឋាន មានទីតាំងស្ថិតនៅភូមិ ..................... ដើម្បីលក់ឡាយឡុងសងបំណុលមកឲ្យ.......................

**យោង៖** -សាលក្រមរដ្ឋប្បវេណីលេខ ....... ចុះថ្ងៃទី....... ខែ........ ឆ្នាំ២០...... របស់សាលាដំបូងខេត្ត/ក្រុង ............។

-រូបមន្តអនុវត្តសាលក្រមលេខ........... ចុះថ្ងៃទី........ ខែ.......... ឆ្នាំ២០.......។

-វិញ្ញាបនប័ត្រសំគាល់ម្ចាស់ អចលនវត្ថុលេខ ចុះថ្ងៃទី...... ខែ........... ឆ្នាំ២០......។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ កាលពីថ្ងៃទី............ ខែ............ ឆ្នាំ............ របស់.................. បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់លើសំណុំរឿងរដ្ឋប្បវេណីលេខ................ ចុះថ្ងៃទី..... ខែ........ ឆ្នាំ២០...... ដោយបានសម្រេចសេចក្តីតាមសាលក្រមរដ្ឋប្បវេណីលេខ............... ចុះថ្ងៃទី.......... ខែ........... ឆ្នាំ២០..... របស់.................. ត្រង់ចំណុចទី ....... នៃវិនិច្ឆ័យសេចក្តីសម្រេចបញ្ចប់ ដែលមានខ្លឹមសារថា៖ សាលក្រមនេះមានអានុភាពអនុវត្តបណ្តោះអាសន្នបានត្រង់វិនិច្ឆ័យទី............ មានខ្លឹមសារថា៖ បង្គាប់ឲ្យចុងចម្លើយឈ្មោះ............. សងប្រាក់ដើមចំនួន ............ ឲ្យមកដើមចោទ............។

ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់បំណុលអនុវត្ត ស្របតាមខ្លឹមសារ នៃសាលក្រមរដ្ឋប្បវេណីលេខ៖ ............... ចុះថ្ងៃទី........... ខែ........... ឆ្នាំ២០...... របស់................ ខ្ញុំបាទ/នាងខ្ញុំស្នើសុំអនុវត្តជាបណ្តោះ

អាសន្ននូវចំណុចខាងលើ ដោយអនុវត្តដោយបង្ខំលើអចនវត្ថុដូចបានបញ្ជាក់ក្នុងកម្មវត្ថុខាងលើ ដើម្បីលក់ឡាយឡុងសងបំណុលមកម្ចាស់បំណុលអនុវត្ត។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាសម្រេចតាមសំណូមពររបស់ខ្ញុំបាទ/នាងខ្ញុំ ដូចបានបញ្ជាក់ក្នុងកម្មវត្ថុខាងលើដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី....... ខែ....... ឆ្នាំ...........

**ស្នាមមេដៃស្តាំ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>ពាក្យសុំដកពាក្យបណ្តឹង</u>**

ខ្ញុំបាទ/នាងឈ្មោះ.......................... មានអាសយដ្ឋានផ្ទះលេខ................. ផ្លូវលេខ.........ភូមិ ........................ ឃុំ/សង្កាត់........................។

**សូមគោរពជូន**

**ឯកឧត្តមប្រធាន**..........................

**<u>កម្មវត្ថុ</u>៖** សំណើសុំដកពាក្យបណ្តឹងរដ្ឋប្បវេណីលេខ............... ចុះថ្ងៃទី....... ខែ........... ឆ្នាំ២០........។

**<u>យោង</u>៖** សំណុំរឿងរដ្ឋប្បវេណីលេខ ............. ចុះថ្ងៃទី......... ខែ........... ឆ្នាំ.........។

តបតាមកម្មវត្ថុ និងយោងខាងលើ សូម **ឯកឧត្តមប្រធាន** ជ្រាបថា៖ កាលពីថ្ងៃទី......... ខែ........... ឆ្នាំ ..........បានដាក់ពាក្យប្តឹង ឈ្មោះ.............. ភេទ........ អាយុ.......... ឆ្នាំ............ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ................. មានទីលំនៅបច្ចុប្បន្ននៅភូមិ.......... ឃុំ/សង្កាត់............ ស្រុក/ខណ្ឌ.............. ខេត្ត/ក្រុង................។ បន្ទាប់ពីតុលាការចេញដីកាកោះក្នុងនីតិវិធីត្រៀម កូនបំណុលក៍យល់ព្រមសង្គ្រោះតាកព្វកិច្ចតាមកិច្ចសន្យាខ្ចីបរិភោគឡើងវិញបន្ទាប់ពីបានពីឯកភាពគ្នាទាំងស្រុង ហេតុដូច្នេះទើបខ្ញុំបាទ សម្រេចចិត្តសុំដកពាក្យបណ្តឹងដើម្បីបញ្ចប់នីតិវិធី។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម **ឯកឧត្តមប្រធាន** មេត្តាសម្រេចតាមសំណូមពររបស់ខ្ញុំបាទ/នាងដូចមានក្នុងកម្មវត្ថុខាងលើ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី....... ខែ....... ឆ្នាំ............

**ស្នាមមេដៃស្តាំ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

សំណុំរឿងរដ្ឋប្បវេណី
លេខ ...............................
ចុះថ្ងៃទី...... ខែ......., ឆ្នាំ២០

## <u>ដីកាបង្គាប់ឱ្យដាក់លិខិតបញ្ជាក់</u>
## <u>អំពីមូលហេតុ នៃបណ្ដឹងសាទុក្ខ</u>

យើង ........................................ចៅក្រមទទួលបញ្ជារបស់ក្រុមប្រឹក្សាជំនុំជម្រះនៃតុលាការកំពូល បង្គាប់មកលោក-លោកស្រី............................................អាយុ..........ឆ្នាំ មានមុខរបរ.. ,.................. អាសយដ្ឋាន: ផ្ទះលេខ...........ក្រុម/ផ្លូវ.............ភូមិ.......................សង្កាត់/ឃុំ .. ............ ខណ្ឌ/ស្រុក...........................រាជធានី/ខេត្ត......................................................................... ជាដើមបណ្ដឹងសាទុក្ខ ឱ្យធ្វើលិខិតបញ្ជាក់អំពីមូលហេតុនៃ បណ្ដឹងសាទុក្ខ ដែលបានប្ដឹងពីសាលដីការដ្ឋប្បវេណី លេខ.... ,....ចុះថ្ងៃទី..... .....ខែ.................ឆ្នាំ... ,........របស់សាលាឧទ្ធរណ៍ ដាក់ជូនតុលាការកំពូល ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីបានទទួលការបញ្ជូនដីកានេះ។

<u>**សំគាល់:**</u> "បើដើមបណ្ដឹងសាទុក្ខមិនដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ តាមដីកានេះទេ តុលាការកំពូលនឹងលើកបណ្ដឹងសាទុក្ខចោល តាមចំណុចខ មាត្រា ២៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី" ។

ភ្នំពេញ ថ្ងៃទី...... ខែ.......... ឆ្នាំ..........
ចៅក្រម

មហាវិថីសម្ដេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ, កម្ពុជា
Samdech Sothearos Blvd, Sangkat Chatomouk, Khan Daun Penh, Phnom Penh, Cambodia.
ទូរស័ព្ទ/ទូរសារ : (៨៥៥-២៣-) ២១២៨២៦
Phone/fax: (855-23) 212 826

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភារដ្ឋប្បវេណី

# លិខិតជូនដំណឹង
# អំពីការទទួលពាក្យបណ្ដឹងជំទាស់ និង
# ឱ្យដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងជំទាស់

យើង............................ ចៅក្រមទទួលបញ្ជានៃក្រុមប្រឹក្សាជំនុំជម្រះតុលាការកំពូល

## ជូនដំណឹង

ម្ចាស់បណ្ដឹងជំទាស់ឈ្មោះ .................... ភេទ ..... កើតនៅថ្ងៃទី ... ខែ ...... ឆ្នាំ ....... អាយុ .... ឆ្នាំ សញ្ជាតិ ..... អាសយដ្ឋានផ្ទះលេខ .......... ផ្លូវលេខ ......... ភូមិ .................. ឃុំ/សង្កាត់ ...................... ស្រុក/ខណ្ឌ ................................ រាជធានីភ្នំពេញ/ខេត្ត ............................ ដូចខាងក្រោម :

១. តុលាការកំពូលបានទទួលពាក្យបណ្ដឹងជំទាស់ របស់ម្ចាស់បណ្ដឹងជំទាស់ ដោយចុះក្នុងបញ្ជីសំណុំរឿងរដ្ឋប្បវេណីលេខ .............. ចុះថ្ងៃទី ....... ខែ ........... ឆ្នាំ .................. ។

២. ម្ចាស់បណ្ដឹងជំទាស់ត្រូវដាក់លិខិតបញ្ជាក់ អំពីមូលហេតុនៃបណ្ដឹងជំទាស់ ក្នុងអំឡុងពេល **២ សប្ដាហ៍** គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតជូនដំណឹងនេះ ។

បើម្ចាស់បណ្ដឹងជំទាស់ មិនបានដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងជំទាស់ តាមការកំណត់ខាងលើ តុលាការកំពូលត្រូវលើកពាក្យបណ្ដឹងជំទាស់ចោល តាមមាត្រា ៣០៤ និងមាត្រា ២៩០ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ............ ឆ្នាំ ២០១........

ចម្លងជូន :
ចុងបណ្ដឹងជំទាស់ឈ្មោះ ........................
ដោយភ្ជាប់ជាមួយនឹងពាក្យបណ្ដឹងជំទាស់
ចុះថ្ងៃទី ......... ខែ ............ ឆ្នាំ .............

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹង**.................

ខ្ញុំបាទ/នាងខ្ញុំមេធាវីឈ្មោះ ................ ជាមេធាវីតំណាងដោយអាណត្តិអោយឈ្មោះអាយុ ............ ឆ្នាំ ជនជាតិខ្មែរ មុខរបរ......... មានទីលំនៅបច្ចុប្បន្នភូមិ..........................................................................ក្នុងករណី សុំទាមទារដី-ផ្លាកទិន និងម៉ូតូ មានសំណុំរឿងរដ្ឋប្បវេណីលេខ ............ ចុះថ្ងៃទី......... ខែ......... ឆ្នាំ........... របស់.............................។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធាន**..............................

**កម្មវត្ថុ៖** សុំធ្វើលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹង.................. ដើម្បីការពារផលប្រយោជន៍របស់កូនក្តីខ្ញុំបាទ/នាងខ្ញុំក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ............ ចុះថ្ងៃទី......... ខែ.......... ឆ្នាំ............ របស់..............................។

**យោង៖** -ដីកាបង្គាប់អោយដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹង.............. ចុះថ្ងៃទី........... ខែ......... ឆ្នាំ........... របស់.............................។

-សំណុំរឿងរដ្ឋប្បវេណីលេខ ............ ចុះថ្ងៃទី......... ខែ.......... ឆ្នាំ........... របស់..............................។

-ពាក្យតំណាងដោយអាណត្តិចុះថ្ងៃទី............. ខែ.......... ឆ្នាំ...........។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបពីដំណើររឿងដូចខាងក្រោម៖

**១/អំពីអង្គហេតុ៖**.........................................................................................................
..............................................................................................................................
..............................................................................................................................
...................................។

**២/អំពីអង្គច្បាប់៖**........................................................................................................

.............................................................................................................................................

.............................................................................................................................................

...................................។

៣/**<u>អំពីការសម្រេចសេចក្តីរបស់តុលាការ៖</u>**

.........................................................................................................................

.............................................................................................................................................

.............................................................................................................................................

...................................។

៤/**<u>សំណូមពរ៖</u>**............................................................................................................

.............................................................................................................................................

.............................................................................................................................................

...................................។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការស្នើសុំរបស់ខ្ញុំបាទ/នាងខ្ញុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី....... ខែ....... ឆ្នាំ...........

**ស្នាមមេដៃស្តាំ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

## ដីកាបង្គាប់ឲ្យបង់ប្រាក់ប្រដាប់ក្ដី

សំណុំរឿងរដ្ឋប្បវេណី

លេខ ......................

ចុះថ្ងៃទី ..........

យើង .........................................ចៅក្រមទទួលបញ្ជារបស់ក្រុមប្រឹក្សាជំនុំជំរះ នៃតុលាការកំពូល
បង្គាប់មកឈ្មោះ ...... ...............ភេទ .. អាយុ ......ឆ្នាំ
អាសយដ្ឋាន: ផ្ទះលេខ.............ក្រុម/ផ្លូវ..................ភូមិ..... ...........សង្កាត់/ឃុំ.....
ខណ្ឌ/ ស្រុក... រាជធានី/ខេត្ត មុខរបរ..
ឲ្យមកបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធចំនួន ១០០.០០០ (ដប់ម៉ឺន)រៀល ក្នុងអំឡុងពេល.............ថ្ងៃ បន្ទាប់ពីបានទទួលការបញ្ជូនដីកានេះពាក់ព័ន្ធនឹងបណ្ដឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ........ ចុះថ្ងៃទី..........ខែ............ឆ្នាំ.....................របស់សាលាឧទ្ធរណ៍ ទៅសភារដ្ឋប្បវេណីនៃតុលាការកំពូល ។

<u>**សំគាល់:**</u>"បើម្ចាស់បណ្ដឹងសាទុក្ខមិនយកប្រាក់មកបង់តាមដីកានេះទេ តុលាការកំពូលនឹងលើកបណ្ដឹងសាទុក្ខចោល តាមចំណុច ក មាត្រា ២៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី" ។

ភ្នំពេញ, ថ្ងៃទី .......... ខែ ............ ឆ្នាំ

ចៅក្រម